- ពូករបស់ទារកត្រូវរលោង តែមិនទន់ខ្លាំង ក្រៅពីកម្រាលពូកមិនត្រូវមានខ្នើយ ឬភួយនៅក្រោមទារកឡើយ ហើយក៏មិនត្រូវយកតុក្កតាដាក់នៅលើពូកដែរ។
- ប្រសិនបើប្រើភួយ ឬកន្សែង ត្រូវរុំទារកត្រឹមដើមទ្រូងដើម្បីកាត់បន្ថយឱកាសគ្របដល់មុខរបស់ពួកគេ។ ភួយដែលប្រើមិនត្រូវធ្ងន់ពេក ឬទន់ស្រាលពេក
- បរិស្ថានដំណេកមិនត្រូវក្ដៅពេក និងមិនត្រូវឲ្យទារកស្លៀកពាក់ខោអាវច្រើនពេកឬពាក់មួក។
- ទារកមិនត្រូវដាក់ឲ្យដេកជាមួយមនុស្សធំនិងមិនត្រូវដាក់ឲ្យដេកជាមួយកុមារ ដែលរួមមានបងប្អូនភ្លោះច្រើន។ ប្រសិនបើមនុស្សធំផឹកស្រា ប្រើប្រាស់ឱសថដែលប៉ះពាល់ដល់ការដឹងខ្លួន ឬជក់បារី នឹងបណ្ដាលឲ្យគ្រោះថ្នាក់នៃជ មឺ ស្លាប់មួយរំពេចរបស់កុមារកើនឡើង។

### រំលឹក

**បែបនេះគេងកាន់តែស្រួល**

- ដើម្បីជៀសវាងទារកក្បាលផ្អៀងត្រូវប្រុងប្រយ័ត្នកុំឲ្យក្បាលទារកដេកផ្អៀងទៅខាងណាឡើយ។
- ដោយសារតែទារកចូលចិត្ត មើលទៅទិសខាងទ្វារអាចផ្លាស់ប្ដូរទិសនៃក្បាលគ្រែ និងចុងគ្រែ មួយសប្ដាហ៍ម្ដង។
- ពេលទារកភ្ញាក់ដឹងខ្លួន ម្ដាយឪពុកអាចឲ្យគេផ្កាប់លេងជាច្រើនលើកក្នុងរយៈពេលខ្លី ដែលអាចជួយបញ្ចៀសកុំឲ្យលលាដ៍ក្បាលក្រោយត្រូវសង្កត់យូរពេក និងអាចជួយហ្វឹកហាត់ដល់សាច់ដុំផ្នែកកនិងស្មារបស់ពួកគេថែមទៀតផង។

# 副食品添加原則

當寶寶逐漸長大，就必須添加副食品，一方面提供奶類不足的營養，另一方面也能夠訓練咀嚼和吞嚥，為日後的營養攝取作準備。

## 何時開始添加副食品？

- 寶寶出生後4個月（校正年齡）內不建議添加副食品，純母乳哺育到6個月後必須添加副食品，不然會有營養不良危機。
- 若有以下狀況，可以考慮提早在滿4個月後開始添加副食品，包括：
  - 純餵到6個月實在有困難
  - 媽媽奶水量明顯降低
  - 寶寶顯得吃不飽
  - 寶寶出現厭奶但沒生病或其他原因
  - 寶寶有主動要求其他食物的表現（看大人吃其他食物時很有興趣，伸手來抓、抓了放嘴巴）
  - 寶寶的頭是否可以自己抬起來穩住
  - 可以將食物從湯匙移動到自己的喉嚨

## 添加副食品的訣竅

- 每次只添加一種新食物，由少量（1-2湯匙）開始，逐漸增加，觀察4-7天，如無長紅疹、腹瀉、嘔吐等症狀，則可繼續餵食。若出現以上的身體反應，則應暫停該食物1-2個月後再嘗試，或向醫師諮詢。
- 添加副食品建議從單一穀類開始，再依序添加蔬菜類、水果類、肉類，建議由口味淡的食物開始。
- 使用過的食物可重複使用，若寶寶可以接受穀類，添加蔬菜時，可將穀類和蔬菜混合後再添加。
- 請選擇強化鐵質的嬰兒專用米精而非市售米麩，米精應以水或奶調成糊狀餵食。
- 開始餵食糊狀食物（如米糊、果泥等）時，應以湯匙餵食，避免將副食品加入奶瓶內與奶一起餵食，除非醫師指示。
- 選在寶寶較餓的時候餵食（例如吃奶前1小時）較易成功。下一餐何時吃奶可視副食品吃了多少而作彈性調整。
- 餵食時應抱起寶寶，面對面餵食。寶寶會坐了以後，則應讓他坐穩以確保安全，勿追逐餵食。

# វិធាននៃការបន្ថែមម្ហូបអាហាររឹង

ពេលទារកធំធាត់បន្តិចម្តងៗ ចាំបាច់ត្រូវបន្ថែមអាហាររឹង ដែលផ្តល់នូវសារធាតុចិញ្ចឹមដែលមានមិនគ្រប់គ្រាន់ក្នុងទឹកដោះ និងជួយហ្វឹកហាត់ការទំពារ និងលេប ដើម្បីជាការត្រៀមលក្ខណៈក្នុងការស្រូបយកសារធាតុចិញ្ចឹមនៅថ្ងៃក្រោយ។

## ពេលណាចាប់ផ្តើមបន្ថែមអាហាររឹង ?

- ក្នុងរយៈពេល៤ខែក្រោយពេលទារកចាប់កំណើត មិនគួរបន្ថែមអាហាររឹងឡើយ។ ក្រោយពេលបំបៅទឹកដោះម្តាយសុទ្ធរយៈពេល៦ខែ ចាំបាច់ត្រូវបន្ថែមអាហាររឹង មិនពុំនោះទេនឹងបង្កឲ្យកើតគ្រោះថ្នាក់ពីសារធាតុចិញ្ចឹមមិនគ្រប់គ្រាន់។
- ប្រសិនបើមានស្ថានភាពដូចខាងក្រោមនេះ អាចពិចារណាបន្ថែមអាហាររឹងក្រោយពេលអាយុគ្រប់៤ខែៈ
  - ពិបាកបំបៅទឹកដោះសុទ្ធរហូតដល់៦ខែ
  - កម្រិតបរិមាណទឹកដោះម្តាយធ្លាក់ចុះ
  - ទារកញុាំមិនឆ្អែត
  - ទារកធុញទ្រាំនឹងទឹកដោះ ប៉ុន្តែមិនមានជម្ងឺ ឬមូលហេតុដទៃឡើយ
  - ទារកបញ្ចេញនូវអាការៈចង់ញុាំអាហារដទៃដោយខ្លួនឯង (គេចាប់អារម្មណ៍ពេលឃើញមនុស្សធំញុាំអាហារដទៃ ដោយយកដៃចាប់ និងចាប់ដាក់ក្នុងមាត់)
  - តើក្បាលរបស់ទារកអាចងើយនិងនៅនឹងដោយខ្លួនឯងឬទេ
  - អាចនាំអាហារផ្លាស់ទីពីស្លាព្រាទៅក្នុងបំពង់កខ្លួនឯង

## រូបមន្តនៃការបន្ថែមអាហាររឹង

- រាល់លើកបន្ថែមតែអាហារមួយមុខប៉ុណ្ណោះ ចាប់ផ្តើមពីបរិមាណតិចទៅ (១ ទៅ ២ស្លាបព្រា) បន្ទាប់មកបង្កើនបរិមាណបន្តិចម្តងៗ ធ្វើការអង្កេត ៤ ទៅ ៧ថ្ងៃ ប្រសិនបើគ្មានចេញដុំពកក្រហម រាគ ឬក្អួត នោះអាចបន្តឲ្យអាហារនេះបាន។ ប្រសិនបើមានប្រតិកម្មដូចរៀបរាប់ខាងលើ នោះត្រូវបញ្ឈប់ការផ្តល់អាហារទាំងនោះពី ១ ទៅ ២ខែ បន្ទាប់មកចាំសាកល្បងម្តងទៀត ឬទៅពិគ្រោះជាមួយវេជ្ជបណ្ឌិត។
- ការបន្ថែមអាហាររឹងគប្បីចាប់ផ្តើមឡើងពីពពួកអាហារស្បៀងជាមុន បន្ទាប់មកទើបបន្ថែមពពួកបន្លែ ផ្លែឈើ និងសាច់ ដោយគប្បីចាប់ផ្តើមពីអាហារដែលមានរសជាតិសាប។
- អាហារដែលប្រើប្រាស់រួចម្តងហើយ អាចប្រើប្រាស់ជាបន្តបន្ទាប់ទៀតបាន
  ប្រសិនបើទារកទទួលយកអាហារស្បៀងបាន នៅពេលបន្ថែមបន្លែ អាចយកបន្លែលាយជាមួយអាហារស្បៀងជាមុនសិន។
- សូមជ្រើសរើសម្សៅអង្ករសម្រាប់ទារកដែលមានជាតិដែកខ្ពស់ តែមិនមែនជាកន្ទក់នោះឡើយ។ ម្សៅអង្ករត្រូវបញ្ចុកទារកដោយលាយឲ្យខាប់ជាមួយទឹក ឬទឹកដោះ។
- ពេលចាប់ផ្តើមបញ្ចុកទារកអាហារខាប់ (ដូចជា បបរធញ្ញជាតិ ឬបបរផ្លែឈើ) ត្រូវបញ្ចុកដោយស្លាបព្រា ជៀសវាងការច្រកអាហាររឹងចូលក្នុងកំប៉ុងទឹកដោះរួចបញ្ចុកកូនជាមួយទឹកដោះ លុះត្រាតែជាវេជ្ជបញ្ជារបស់គ្រូពេទ្យ។
- បញ្ចុកអាហាររឹងពេលទារកកំពុងឃ្លាន (ឧទាហរណ៍ ១ម៉ោងមុនពេលបៅដោះ) ងាយនឹងបានជោគជ័យ។ ពេលវេលានៃការបៅដោះត្រូវតម្រូវទៅតាមបរិមាណនៃអាហាររឹងដែលបានញុាំ។
- ពេលបញ្ចុកអាហារត្រូវចាប់បីទារកឡើង បញ្ចុកទល់មុខគ្នា។ ក្រោយពេលទារកចេះអង្គុយ ត្រូវឲ្យគេអង្គុយឲ្យបាននឹងដើម្បីរក្សាសុវត្ថិភាព ហាមប្រដេញបញ្ចុកអាហារ។

# 副食品添加原則

- 若寶寶拒絕張口、將頭轉開或哭鬧起來時，勿強迫餵食；可暫停1-2星期後再試。若寶寶僅露出皺眉和嫌惡的表情，並未明顯推拒時，可能只是不習慣新食物，應多嘗試幾次，讓他習慣，勿輕易放棄。
- 餵食時的氣氛應保持輕鬆愉快，如果吃飽了就應該停止，不要強迫寶寶將準備的食物全部吃完。

## 添加副食品應注意什麼？

- 稀飯是很好的半固體食物，但僅用大骨湯煮的稀飯，營養和熱量均不足，必須添加其他食物（如蔬菜、根莖類、蛋黃、肉類等）在內。
- 製作副食品時應注意衛生，毋須添加人工調味品（如鹽、糖），口味儘量清淡為主。
- 市售罐裝嬰兒食品應避免選用添加有澱粉等賦形劑的產品，以免攝取不必要的熱量。購買時應注意有效期限及適用年齡，吃不完的食物應置於冰箱保鮮。
- 寶寶的大便中若出現未消化的食物，如豆子或玉米的皮、蔬菜的纖維等，都是正常的，不必因此停止餵食。
- 寶寶副食品添加應避免提供以下食物：
  - 蜂蜜偶含肉毒桿菌芽孢，1歲以下嬰兒因免疫系統及腸道菌叢未健全，應避免餵食，減少肉毒桿菌中毒的風險。
  - 奶類可提供豐富的鈣質及蛋白質，但一般牛奶含鐵質不足，且容易受到污染或引起過敏，因此建議一歲以下嬰兒不要給予牛奶，可以選擇起司、優格。
  - 避免給予硬且圓的食物，易導致寶寶噎住，如堅果、葡萄或糖果。
  - 不提供八寶粉（散）、退胎水、紅嬰水與偏方給寶寶食用。

# វិធាននៃការបន្ថែមម្ហូបអាហាររង

- ប្រសិនបើទារកមិនបើកមាត់ ងៀកក្បាលចេញ ឬយំ ហាមបញ្ចុកអាហារដោយបង្ខំ អាចបញ្ឈប់ជាបណ្ដោះអាសន្នពី១ ទៅ ២សប្តាហ៍ ទើបសាកល្បងម្តងទៀត។ ប្រសិនបើទារកបញ្ចេញទឹកមុខស្អប់ខ្ពើម ឬជ្រួញចិញ្ចើម តែមិនទាន់បដិសេធ អាចបណ្ដាលមកពីមិនទាន់ទម្លាប់ជាមួយអាហារថ្មី គប្បីសាកល្បងឲ្យបានច្រើនលើក ដើម្បីឲ្យទារកទម្លាប់។ មិនត្រូវបោះបង់ដោយងាយៗនោះឡើយ។
- ត្រូវរក្សាបរិយាកាសក្នុងពេលបញ្ចុកអាហារឲ្យមានភាពសប្បាយរីករាយ។ ប្រសិនបើញ៉ាំឆ្អែតហើយត្រូវឈប់បញ្ចុក កុំបង្ខំឲ្យទារកញ៉ាំអាហារដែលមានទាំងអស់។

## ការបង្កើនអាហាររងត្រូវប្រុងប្រយ័ត្នអ្វីខ្លះ?

- បបរ គឺជាអាហារពាក់កណ្ដាលរឹងដ៏ប្រសើរ ប៉ុន្តែបបរដែលចម្អិនឡើងដោយស៊ុបឆ្អឹង មានសារធាតុចិញ្ចឹមនិងកាឡូរីមិនគ្រប់គ្រាន់ ត្រូវបន្ថែមម្ហូបអាហារដទៃទៀត (ដូចជាបន្លែ បន្លែមើមស៊ុត និងសាច់ជាដើម។)
- ពេលធ្វើម្ហូបអាហាររងត្រូវយកចិត្តទុកដាក់ទៅលើអនាម័យ មិនចាំបាច់បន្ថែមគ្រឿងទេសកែច្នៃ (ដូចជាអំបិល និងស្ករ) ហើយមានរសជាតិសាបជាចម្បង។
- ចំពោះអាហារកំប៉ុងសម្រាប់ទារកនៅលើទីផ្សារ ត្រូវជៀសវាងផលិតផលដែលមានសារធាតុផ្សំដូចជាជាតិម្សៅជាដើម ដើម្បីជៀសវាងការស្រូបយកកាឡូរីដែលមិនចាំបាច់។ ពេលទិញសូមប្រុងប្រយ័ត្នចំពោះកាលកំណត់ និងអាយុប្រើប្រាស់។ អាហារដែលទទួលទានមិនអស់ ត្រូវរក្សាទុកក្នុងទូទឹកកក។
- ក្នុងលាមករបស់ទារក ប្រសិនបើមានអាហារដែលមិនទាន់រំលាយ ដូចជាសម្បកពោតឬសណ្ដែក ឬសសៃបន្លែជាដើម គឺជារឿងប្រក្រតី មិនចាំបាច់បញ្ឈប់ការបញ្ចុកអាហារឡើយ។
- ទារកការបន្ថែមអាហាររងត្រូវជៀសវាងអាហារខាងក្រោមនេះ៖
  - ទឹកឃ្មុំខ្លះមានទណ្ឌាណូក្លស្ទីឌីម ចំណែកឯទារកអាយុក្រោម១ឆ្នាំមានការលូតលាស់ប្រព័ន្ធស៊ាំ និងបាក់តេរីមិនទាន់ពេញលេញ ត្រូវជៀសវាងឲ្យទារកញ៉ាំទឹកឃ្មុំ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការកើតមានទណ្ឌាណូក្លស្ទីឌីម។
  - ប្រភេទទឹកដោះគោអាចផ្ដល់នូវកាល់ស្យូម និងប្រូតេអ៊ីយ៉ាងបរិបូរណ៍ ប៉ុន្តែទឹកដោះគោទូទៅមានជាតិកាល់ស្យូមមិនគ្រប់គ្រាន់ ម្យ៉ាងទៀតងាយនឹងឆ្លងមេរោគ ឬបណ្ដាលឲ្យមានប្រតិកម្ម ហេតុដូចនេះមិនគួរឲ្យទារកអាយុក្រោម១ឆ្នាំញ៉ាំទឹកដោះគោឡើយ អាចយកឈីស និងទឹកដោះគោជូ ជំនួសបាន។
  - ជៀសវាងឲ្យទារកញ៉ាំអាហារដែលរឹងនិងមានរាងមូលងាយបង្កឲ្យទារកឆ្លាក់ ដូចជាគ្រាប់ធញ្ញជាតិ ទំពាំបាយជូ ឬស្ករគ្រាប់ជាដើម។
  - មិនឲ្យទារកញ៉ាំម្សៅប៉ាប៉ារ ទឹកហុងអ៊ឹង និងឱសថប្រជាប្រិយ។

# 副食品添加原則

## 添加副食品的重點時程

- 6個月大以後，開始訓練寶寶使用杯子，以作為日後戒斷奶瓶的準備。6個月前不需要給予果汁，開始給予時須進行稀釋。
- 6-8個月左右，可以讓寶寶練習自己拿著餅乾或烤過的土司吃。
- 9-10個月大時，提供一些約一口大小、較軟的食物，也可讓寶寶用手抓著吃。
- 副食品吃得較多時，奶量自然隨著減少。依照世界衛生組織的建議，喝母乳的寶寶，在6-8個月時，一天至少應吃兩次副食品；9個月以後，則1天至少吃3次副食品；對於沒有喝母奶的寶寶，則6個月後，1天至少要吃4次副食品或配方奶，以維持寶寶足夠的能量攝取。
- 未添加副食品前，除非天氣很熱、流很多汗，一般不需要額外再給予水分，以免影響奶量攝取。

### 小提示

**三心 二意 獻親情**

只要在孩子成長的路上，多付出「三心」與「二意」，您就可以為孩子的健康加分喔！

**健康生活三重心：**

- 飲食多元需用心～從小飲食多樣化，吃得均衡最健康。
- 餐點內容要關心～點心種類要慎選，零食不要隨處放。
- 適度運動有恆心～日常生活多活動，規律運動益成長。

**親職教育二要意：**

- 親子溝通多在意～面對偏食的孩子，鼓勵嘗試勿強迫！
- 親人身教多注意～建立學習好榜樣，良好飲食從己做！

# វិធាននៃការបន្ថែមម្ហូបអាហាររង

## កាលវិភាគសំខាន់នៃការបន្ថែមអាហាររង

- ក្រោយពេលអាយុគ្រប់៦ខែ ចាប់ផ្តើមបង្ហាត់ឲ្យទារកចេះប្រើកែវទឹក ដើម្បីត្រៀមលក្ខណៈក្នុងការផ្តាច់កំប៉ុងទឹកដោះនៅថ្ងៃក្រោយ។ មុនពេលអាយុ៦ខែ មិនចាំបាច់ផ្តល់ឲ្យទឹកផ្លែឈើឡើយ ពេលចាប់ផ្តើមឲ្យទារកញ៉ាំត្រូវបន្សាបជាមុន។
- ៦ ទៅ ៨ខែ អាចបង្ហាត់ឲ្យទារករៀនចេះកាន់នំប៊ីស្គីត ឬនំប៉ុងចំណិតញ៉ាំដោយខ្លួនឯង។
- ៩ ទៅ ១០ខែ ផ្តល់អាហារដែលទន់ និងមានទំហំប្រហាក់ប្រហែលមាត់ទៅដល់ទារក ឬអាចឲ្យពួកគេយកដៃចាប់ញ៉ាំដោយខ្លួនឯង។
- ពេលញ៉ាំអាហាររងកាន់តែច្រើន បរិមាណទឹកដោះដែលត្រូវញ៉ាំនឹងថយចុះដោយខ្លួនឯង។ យោងទៅតាមដំបូន្មានរបស់អង្គការសុខភាពពិភពលោក ទារកដែលបៅទឹកដោះម្តាយ ពេលមានអាយុ៦ ទៅ៨ខែ ត្រូវញ៉ាំអាហាររងចំនួន២ដងក្នុងមួយថ្ងៃយ៉ាងតិច។ ក្រោយពេលអាយុ៩ខែ ក្នុងមួយថ្ងៃយ៉ាងហោចណាស់ញ៉ាំចំនួន៣ដង។ ចំពោះទារកដែលមិនបានបៅទឹកដោះម្តាយ ពេលមានអាយុ៦ខែ ក្នុងមួយថ្ងៃយ៉ាងហោចណាស់ត្រូវញ៉ាំអាហាររង ឬទឹកដោះគោម្សៅផ្សំចំនួន៤លើក ដើម្បីធានាការស្រូបយកថាមពលគ្រប់គ្រាន់របស់ទារក។
- មុនពេលបន្ថែមអាហាររង ជាទូទៅមិនត្រូវការបន្ថែមជាតិទឹកនោះទេ លុះត្រាតែអាកាសធាតុក្តៅខ្លាំង និងហូរញើសច្រើន ដើម្បីកុំឲ្យប៉ះពាល់ដល់ការស្រូបយកបរិមាណទឹកដោះ។

### រំលឹក

**ចំណុចយកចិត្តទុកដាក់៣ ចំណុចប្រុងប្រយ័ត្ន២ បញ្ជាក់ពីទឹកចិត្តឪពុកម្តាយ**

នៅក្នុងការធំធាត់របស់កូន អ្នកមាន “យកចិត្តទុកដាក់៣” និង “បំរុងប្រយ័ត្ន២” អាចជួយឲ្យបុត្រធីតាកាន់តែមានសុខភាពល្អ!

**ចំណុចយកចិត្តទុកដាក់៣ នៃជីវិតប្រកបដោយសុខភាព៖**

- យកចិត្តទុកដាក់ចំពោះភាពចម្រុះនៃម្ហូបអាហារ៖ មានម្ហូបអាហារច្រើនបែបច្រើនយ៉ាងតាំងពីតូច ញ៉ាំដោយត្រឹមត្រូវទើបមានសុខភាពល្អ។
- យកចិត្តទុកដាក់ចំពោះមុខម្ហូប៖ ប្រភេទនៃបង្អែមត្រូវជ្រើសរើសដោយប្រុងប្រយ័ត្ន នំចំណីកុំទុកចោលផ្តេសផ្តាស។
- យកចិត្តទុកដាក់ហាត់ប្រាណឲ្យបានសមល្មម៖ ត្រូវធ្វើចលនាឲ្យបានច្រើនក្នុងជីវភាពប្រចាំថ្ងៃ។ ការហាត់ប្រាណទៀងទាត់មានប្រយោជន៍ទៅដល់ការធំធាត់។

**បំរុងប្រយ័ត្ន២ក្នុងការអប់រំរបស់អាណាព្យាបាល៖**

- ប្រុងប្រយ័ត្នក្នុងការទំនាក់ទំនងរវាងមាតាបិតានិងបុត្រធីតា៖ ប្រឈមមុខនឹងកូនដែលរើសអាហារ គួរលើកទឹកចិត្តឲ្យពួកគេសាកល្បង តែមិនត្រូវបង្ខំឡើយ។
- ប្រុងប្រយ័ត្នក្នុងការធ្វើគំរូ៖ សាងនូវគំរូសិក្សាដ៏ល្អសម្រាប់កុមារ។ ទម្លាប់បរិភោគអាហារល្អធ្វើឡើងចេញពីខ្លួនឯង។

# 培養良好的飲食習慣

高熱量低營養的過度飲食內容及缺乏運動的靜態生活，是造成肥胖的主要原因。良好的飲食習慣，能使孩子攝取充足、均衡的營養。父母以身作則，陪伴孩子養成健康生活型態，透過聰明吃、快樂動，教導孩子學習選擇健康飲食，養成動態生活習慣，可以為國家未來主人翁預約一個健康的未來。

## 養成嬰幼兒良好飲食習慣

- 用餐有一定的地點。餵副食品時讓寶寶坐穩，1歲以後，將高腳椅放在餐桌邊，安排與其他家人一同進食。
- 尊重寶寶的胃口，不強迫餵食。若孩子吃不完，下次可將食物減少。
- 1歲到1歲半之間為黃金訓練期，讓寶寶學習自己用湯匙吃飯。
- 孩子會自己吃飯以後，1次給予他少量的食物；吃完了還要的話，才再給他。
- 維持進餐時的愉悅氣氛，讓孩子參與餐桌上的談話。
- 3歲後可以開始規定一些簡單的餐桌禮節，孩子遵循時應常給予誇獎。
- 規定合理的用餐時間（一般而言約為30分鐘），時間到了或全家人都已經吃完了，就請孩子下桌。
- 三餐之間可提供點心！但宜在正餐前2小時吃完，量不要多，選擇有營養的食物，避免高油、高糖、高鹽及重口味的食物或零食。牛奶、蛋、豆花、蔬果、麵包等都是可以選擇的好點心。
- 引發孩子對食物的興趣！藉著與孩子一起進食、購物、看電視、看書等機會，介紹及討論各類食物。採購與製作準備食物時，也可邀請孩子參與。



# បណ្ដុះទម្លាប់ល្អក្នុងការបរិភោគ

ម្ហូបអាហារដែលមានកាឡូរីខ្ពស់និងគ្មានវីតាមីន និងការរស់នៅដោយកង្វះខាតការហាត់ប្រាណ គឺជាមូលហេតុចម្បងដែលបណ្ដាលឲ្យធាត់។ ទម្លាប់ល្អក្នុងការបរិភោគ ជួយឲ្យកុមារស្រូបយកសារធាតុចិញ្ចឹមបានគ្រប់គ្រាន់ និងមានសមាមាត្រ។ ឪពុកម្ដាយធ្វើខ្លួនជាគំរូ ជួយទម្លាប់ឲ្យកូនមានការរស់នៅប្រកបដោយសុខភាព។ តាមរយៈការបរិភោគប្រកបដោយភាពឆ្លាតវៃ និងការហាត់ប្រាណប្រកបដោយភាពរីករាយ បង្គាប់ឲ្យកូនរៀនចេះជ្រើសរើសមុខម្ហូបអាហារដែលមានសុខភាពនិងមានទម្លាប់សកម្មក្នុងការរស់នៅ ដើម្បីកសាងបេទស្របកបេដាយសុខុមាលភាពនាថ្ងៃអនាគត

## បណ្ដុះទម្លាប់ល្អក្នុងការបរិភោគរបស់ទារក

- បរិភោគអាហារនៅកន្លែងទៀតទាត់  ពេលបញ្ចុកអាហាររងត្រូវឲ្យទារកអង្គុយឲ្យនឹង។ គ្រប់អាយុ១ឆ្នាំ រៀបចំកៅអីជើងខ្ពស់មួយនៅជិតតុបាយ ដើម្បីឲ្យទារកបរិភោគអាហារជាមួយសមាជិកដទៃទៀតក្នុងគ្រួសារ។
- គោរពការញ៉ាំរបស់ទារក មិនត្រូវបញ្ចុកអាហារដោយបង្ខំឡើយ។ ប្រសិនបើកូនញ៉ាំមិនអស់ លើកក្រោយអាចកាត់បន្ថយបរិមាណអាហារ។
- ពីអាយុ១ឆ្នាំ ទៅ ១ឆ្នាំកន្លះ គឺជាដំណាក់កាលហ្វឹកហាត់ដ៏សំខាន់ ដោយបង្រៀនឲ្យកូនចេះប្រើស្លាបព្រាញ៉ាំបាយដោយខ្លួនឯង។
- ក្រោយពេលកូនចេះញ៉ាំបាយដោយខ្លួនឯងញ៉ាំម្ដងឲ្យអាហារក្នុងបរិមាណតិច ប្រសិនបើគេចង់ញ៉ាំទៀតទើបឲ្យបន្ថែម។
- រក្សាបរិយាកាសរីករាយក្នុងការបរិភោគអាហារ ឲ្យទារកចូលរួមក្នុងការជជែកលេងពេលបាយ។
- ក្រោមអាយុ៣ឆ្នាំ អាចចាប់ផ្ដើមកំណត់សីលធម៌មូលដ្ឋានមួយចំនួនក្នុងពេលបរិភោគបាយ។ ពេលកូនគោរពបានតាមសីលធម៌ទាំងនោះ គួរផ្ដល់ការកោតសសើរដល់គេឲ្យបានញឹកញាប់។
- កំណត់ពេលវេលាបរិភោគអាហារសមស្របមួយ (ជាទូទៅប្រហែល៣០នាទី)ពេលដល់ម៉ោងកំណត់ឬសមាជិកគ្រប់គ្នាញ៉ាំរួចរាល់ហើយ អាចឲ្យកូនចេញពីតុបាន។
- ក្នុងចន្លោះអាហារទាំង៣ពេល អាចឲ្យញ៉ាំបង្អែម! ប៉ុន្តែត្រូវញ៉ាំឲ្យអស់មុនពេលបាយ២ម៉ោង ក្នុងបរិមាណតិចដោយជ្រើសរើសយកអាហារដែលមានសារធាតុចិញ្ចឹម ជៀសវាងអាហារឬចំណីដែលមានខ្លាញ់ច្រើន ស្ករច្រើន ប្រៃខ្លាំង និងរសជាតិចាស់។ ទឹកដោះគោ ស៊ុត បង្អែមតៅហ៊ូ បន្លែផ្លែឈើ និងនំប៉័ងគឺជាជម្រើសដ៏ល្អនៃបង្អែម។
- ទាក់ទាញឲ្យកូនមានចំណាប់អារម្មណ៍ចំពោះម្ហូបអាហារ! ពេលញ៉ាំអាហារ ទិញឥវ៉ាន់ មើលទូរទស្សន៍ និងមើលសៀវភៅជាមួយកូននិយាយណែនាំនិងពិភាក្សាអំពីម្ហូបអាហារគ្រប់ប្រភេទ។ ពេលទិញ ឬធ្វើម្ហូបក៏អាចឲ្យកូនមកចូលរួមធ្វើជាមួយ។



# 培養良好的飲食習慣

## 幼兒期營養攝取小叮嚀

- 幼兒的飲食習慣是奠定成人飲食的基礎！您與孩子最親密，不但是孩子飲食的把關者，更是行為模仿的對象。請多關心孩子吃些什麼、怎麼吃，作孩子的好榜樣。
- 均衡飲食從小做起！幼兒期是飲食行為養成的關鍵期，在飲食上，除了補充熱量以外，更要重視均衡性，使孩子攝取到多種營養素，幫助孩子建立均衡飲食習慣。
- 6個月大以後的寶寶光喝奶是不夠的，寶寶需要攝取各種食物、練習咀嚼與進食，主食應增加肉末、果泥、粥等的食物。
- 儘量讓孩子嘗試各種食物！孩子此時期的飲食選擇，可能會影響一生的飲食喜好及健康。
- 不要強迫孩子一定要清空盤子，避免日後是為了吃而吃，而不是因為餓了。

## 培養一生適用的飲食習慣

- 孩子不再以母奶或嬰兒奶粉為主要食物了，但每天還是可以喝牛奶，供應足夠蛋白質、鈣質、維生素A及B2。
- 牛奶的選擇未必要使用特殊成長奶粉，2歲以前可使用一般全脂鮮奶及奶製品，2-5歲可以使用低脂鮮奶及製品，5歲以上才可以使用脫脂鮮奶，最重要是，不要再將牛奶當主食，而忽略其他食物的攝取。
- 多吃富含鐵的食物！ 1-2歲的孩子比較容易缺乏鐵質，可多吃紅色肉類、蛋黃及深色蔬菜。
- 蔬菜及水果不可少！蔬果中含有豐富維生素、礦物質及膳食纖維，都是孩子生長所需營養。
- 少喝含糖飲料！補充水分以白開水為宜。
- 不在孩子面前批評或不吃某種食物，讓孩子有樣學樣。
- 多變換烹煮方式，讓孩子少量多嘗試。
- 提供孩子多元多樣的食物選擇，不要侷限在父母的好惡。

## 創意美食「新煮張」

- 加點巧思，創造千變萬化的美味健康餐食！重視食物的顏色搭配，嘗試變化外型，如利用食物本身的顏色、餐盤擺飾及壓模等。
- 選擇新鮮、當季的天然食物！少吃罐頭、醃漬物等加工食品。

# បណ្តុះទម្លាប់ល្អក្នុងការបរិភោគ

## ដំបូន្មាននៃការស្រូបយកសារធាតុចិញ្ចឹមក្នុងវ័យកុមារ

- ទម្លាប់ក្នុងការបរិភោគរបស់កុមារ គឺជាមូលដ្ឋានគ្រឹះនៃការបរិភោគរបស់មនុស្សពេលពេញវ័យ! អ្នកជិតស្និទ្ធជាងគេជាមួយកូន ដូចនេះអ្នកគឺជាអ្នកឃ្លាំមើលការបរិភោគរបស់កូន និងជាគំរូរបស់គេផងដែរ។ សូមយកចិត្តទុកដាក់ថាតើកូនញ៉ាំអ្វីខ្លះ និងញ៉ាំដោយរបៀបណា និង ធ្វើជាគំរូរបស់កូន។
- ទម្លាប់ក្នុងការបរិភោគរបស់កុមារ គឺជាមូលដ្ឋានគ្រឹះនៃការបរិភោគរបស់មនុស្សពេលពេញវ័យ! អ្នកជិតស្និទ្ធជាងគេជាមួយកូន ដូចនេះអ្នកគឺជាអ្នកឃ្លាំមើលការបរិភោគរបស់កូន និងជាគំរូរបស់គេផងដែរ។ សូមយកចិត្តទុកដាក់ថាតើកូនញ៉ាំអ្វីខ្លះ និងញ៉ាំដោយរបៀបណា និង ធ្វើជាគំរូរបស់កូន។
- ក្រោយទារកអាយុ៦ខែ ការបំបៅដោះតែមួយមុខមិនគ្រប់គ្រាន់នោះទេ ទារកត្រូវការស្រូបយកអាហារគ្រប់ប្រភេទ រៀនទំពារ និងលេបអាហារអាហារចម្បងត្រូវបន្ថែមសាច់ចិញ្ច្រាំ បបរផ្លែឈើ និងបបរជាដើម។
- ឲ្យកូនសាកល្បងអាហារគ្រប់ប្រភេទតាមលទ្ធភាព! ជម្រើសក្នុងការបរិភោគរបស់កុមារក្នុងវ័យនេះ អាចជះឥទ្ធិពលទៅលើចំណង់ចំណូលចិត្តក្នុងការបរិភោគ និងសុខភាពរបស់ពួកគេពេញមួយជីវិត។
- កុំបង្ខំឲ្យកូនញ៉ាំអាហារឲ្យអស់ពីចាន ដើម្បីជៀសវាងកុំឲ្យថ្ងៃក្រោយញ៉ាំដើម្បីញ៉ាំ មិនមែនញ៉ាំព្រោះឃ្លាន។

## បណ្តុះទម្លាប់បរិភោគអាហារដែលសាកសមប្រើក្នុងមួយជីវិត

- ពេលកូនមិនមែនញ៉ាំទឹកដោះម្តាយ ឬម្សៅទឹកដោះគោជាអាហារចម្បង គេនៅតែអាចឲ្យពួកគេផឹកទឹកដោះគោជារៀងរាល់ថ្ងៃ ដើម្បីផ្គត់ផ្គង់ប្រូតេអ៊ីន កាល់ស្យូម វីតាមីនA និងវីតាមីនB2។
- ការជ្រើសរើសទឹកដោះគោ មិនចាំបាច់ជ្រើសយកតែម្សៅទឹកដោះគោពិសេសនោះទេ មុនអាយុ២ឆ្នាំអាចញ៉ាំទឹកដោះគោស្រស់ឬផលិតផលទឹកដោះគោខ្លាញ់ពេញលេញ ទូទៅបាន។ អាយុ២ ទៅ៥ឆ្នាំ អាចញ៉ាំទឹកដោះគោស្រស់ឬផលិតផលទឹកដោះគោខ្លាញ់ទាប។ អាយុ៥ឆ្នាំឡើង ទើបអាចញ៉ាំទឹកដោះគោគ្មានខ្លាញ់បាន។ អ្វីដែលសំខាន់នោះគឺ មិនត្រូវយកទឹកដោះគោធ្វើជាអាហារចម្បង ហើយបំភ្លេចពីម្ហូបអាហារដទៃនោះទេ។
- ញ៉ាំអាហារដែលមានជាតិដែកច្រើនឲ្យបានច្រើន! កុមារពីអាយុ១ ទៅ២ឆ្នាំ តែងតែងាយខ្វះជាតិដែក អាចញ៉ាំប្រភេទសាច់ក្រហម ស៊ុតលឿង និងបន្លែពណ៌ចាស់ឲ្យបានច្រើន។
- បន្លែ និងផ្លែឈើមិនអាចខ្វះបាន! ក្នុងបន្លែផ្លែឈើ សម្បូរទៅដោយវីតាមីន សារជាតិរ៉ែ និងអាហារសសៃ ដែលសុទ្ធតែជាសារធាតុចិញ្ចឹមដែលកុមារត្រូវការសម្រាប់ការលូតលាស់។
- កុំញ៉ាំភេសជ្ជៈមានជាតិស្ករច្រើន! បំពេញជាតិទឹកដោយទឹកដាំពុះ។
- កុំធ្វើការរិះគន់ឬមិនញ៉ាំអាហារប្រភេទណាមួយនៅមុខកូនឡើយ ព្រោះកូនអាចរៀនតាម។
- ផ្លាស់ប្តូរវិធីចម្អិនម្ហូបឲ្យបានច្រើន ដើម្បីឲ្យកូនសាកល្បងបានច្រើន។
- ផ្តល់ឲ្យកូននូវជម្រើសម្ហូបអាហារច្រើនបែបច្រើនយ៉ាងពុំមែនមានត្រឹមតែម្ហូបអាហារណាដែលម្តាយឪពុកចូលចិត្តឬស្អប់នោះទេ។

## កំណែច្នៃម្ហូបអាហារដ៏ឈ្ងុយឆ្ងាញ់

- បន្ថែមនូវរូបមន្តខ្លះៗ កែច្នៃម្ហូបអាហារប្រកបដោយសុខភាពឲ្យបានច្រើនបែបយ៉ាង! យកចិត្តទុកដាក់ចំពោះការផ្សំពណ៌របស់ម្ហូបសាកល្បងផ្លាស់ប្តូររូបរាងឧទាហរណ៍ប្រើប្រាស់ពណ៌របស់ម្ហូប ក្បាច់ចាន និងពុម្ពជាដើម។
- ជ្រើសរើសម្ហូបធម្មជាតិដែលស្រស់ និងក្នុងរដូវ។ កុំញ៉ាំអាហារកែច្នៃដូចជា អាហារកំប៉ុង ឬអាហារផ្អាប់ច្រើនពេក។

# 培養良好的飲食習慣

- 製備食物的過程中，不宜添加過多的鹽、味精等調味料，以及辣椒、咖哩等味道較刺激的香辛料。
- 改以蒸、燉、煮的方式，取代煎、炸。因為油炸食物油膩不易消化，也有更高的致病風險。
- 切生食、熟食的砧板要分開！製作餐點時要注意衛生，避免食物被污染。
- 烹煮蛋類前，應先將蛋殼洗淨，擦乾再打蛋，並須完全煮熟，勿食用蛋殼破損的蛋。

## 孩子飲食偏差怎麼辦？

- 偏食：照顧者以身作則，不要在孩子面前批評或不吃某種食物。烹煮時需要耐心多變換方式，並且讓孩子少量多嘗試幾次。採購與製備食物時也可以邀請孩子一起參與。
- 愛吃零食、甜點：家中不要存放太多零食讓孩子隨手可拿。當然也不要用零食、甜點當作獎勵或要求孩子的條件。
- 吃飯不專心：吃飯時不要開電視，並遠離玩具，堅持固定在餐桌上用餐。

### 小提示

用餐時儘量避免以下情形：

- 不要限定孩子一定要吃多少份量的食物。
- 不要利用進餐時批評、教訓或責罵孩子。
- 不要家中存放許多零食，讓孩子隨手可拿。
- 不要以食物作為孩子行為表現良好的獎勵品。
- 不要在遊戲、看電視或聽故事時，讓孩子一面吃東西。

# បណ្ដុះទម្លាប់ល្អក្នុងការបរិភោគ

- ក្នុងពេលធ្វើម្ហូប មិនត្រូវប្រើអំបិលឬប៊ីចេង និងម្ទេសឬគ្រឿងការីច្រើនពេកនោះទេ។
- ចម្អិនដោយចំហុយ រងាស់ និងស្ងរ ជំនួសការចម្អិនដោយចៀន និងបំពង។ ព្រោះអាហារបំពងពិបាកក្នុងការរំលាយ និងមានគ្រោះថ្នាក់ដល់សុខភាពកាន់តែខ្ពស់។
- ជ្រុញហាន់អាហារស្រស់ និងជ្រុញហាន់អាហារឆ្អិន ត្រូវប្រើផ្សេងគ្នា។ ពេលធ្វើបង្អែមត្រូវប្រុងប្រយ័ត្នចំពោះអនាម័យ ជៀសវាងធ្វើឲ្យអាហារកខ្វក់។
- មុនពេលចម្អិនឬស្ងរស៊ុត ត្រូវលាងសម្បកស៊ុតឲ្យបានស្អាតជាមុននិងជូតឲ្យស្អាតចាំវាយបំបែក និងត្រូវចម្អិនឲ្យឆ្អិន។ ហាមទទួលទានស៊ុតណាដែលមានស្នាមបែកស្រាំ។
- 

## កូនមានការបរិភោគអាហារមិនល្អ តើត្រូវធ្វើដូចម្ដេច?

- រើសអាហារ៖ អ្នកមើលថែទាំកុមារត្រូវតាំងខ្លួនជាគំរូ មិនត្រូវរិះគន់ ឬមិនញ៉ាំអាហារមួយប្រភេទណានៅមុខកុមារឡើយ។ ពេលចម្អិនអាហារត្រូវមានភាពអំណត់ និងផ្លាស់ប្ដូរវិធីឲ្យបានច្រើន ព្រមទាំងឲ្យកុមារសាកល្បងឲ្យបានច្រើនក្នុងបរិមាណតិច។ ពេលទិញនិងធ្វើម្ហូប អាចឲ្យកូនចូលរួមជាមួយ។
- ចូលចិត្តញ៉ាំចំណី និងបង្អែម៖ ក្នុងផ្ទះមិនត្រូវរក្សាទុកចំណីច្រើន ដែលអាចឲ្យកុមារយកញ៉ាំបានគ្រប់ពេលនោះទេ។ ក៏មិនត្រូវយកចំណី និងបង្អែម ធ្វើជារង្វាន់លើកទឹកចិត្ត ឬលក្ខខណ្ឌក្នុងការសំណូមពរកូននោះទេ។
- ញ៉ាំបាយមិនយកចិត្តទុកដាក់៖ ពេលញ៉ាំបាយមិនត្រូវមើលទូរទស្សន៍ និងត្រូវញ៉ាំឲ្យឆ្ងាយពីរបស់លេង។ រក្សាទម្លាប់ញ៉ាំបាយនៅតុបាយ។

### រំលឹក

ពេលញ៉ាំបាយ ត្រូវជៀសវាងស្ថានការណ៍ទាំងនេះ៖

- កុំកំណត់ឲ្យកូនថាត្រូវញ៉ាំអាហារឲ្យអស់ក្នុងបរិមាណប៉ុណ្ណា។
- កុំស្ដោរវាយតែម្ល ប្រៀនប្រដៅ ឬស្ដីបន្ទោសកូនក្នុងពេលបាយ។
- កុំរក្សាទុកចំណីច្រើនក្នុងផ្ទះដែលអាចឲ្យកូនយកញ៉ាំគ្រប់ពេល។
- កុំយកអាហារមកធ្វើរង្វាន់លើកទឹកចិត្ត ទៅដល់លទ្ធផលល្អនៃសកម្មភាពរបស់កូន។
- កុំឲ្យកូនញ៉ាំអាហារ ពេល លេង មើលទូរទស្សន៍ ឬស្ដាប់រឿងនិទាន។

# 培養動態生活習慣

## 養成孩子動態生活習慣

- 盡量培養幼兒及學齡前兒童從事中等費力的身體活動如丟球遊戲、帶動唱等。另每天應安排約1小時(可分段)中等費力至費力的活動如跳舞、玩球比賽、爬上爬下、跑來跑去的活動。
- 六個月以下的嬰兒每天應有身體俯臥活動的親子遊戲時間，但睡眠時則不可俯臥以避免增加嬰兒猝死機率。
- 不要限制孩子身體活動的機會，例如，非用餐時間，不要將孩子固定在餐椅上，在安全範圍內，盡量讓孩子增加身體活動量。
- 孩子2歲以前不要觀看電視或電子用品螢幕，2歲以後要限制每日注視螢幕時間不可超過2小時，切勿在幼兒房放置電視，避免長期久坐增加肥胖的風險，且易受電視食品廣告影響。
- 依孩子不同年齡，每天早睡早起的習慣，維持充分的睡眠時間。

## 避免兒童肥胖

- 根據研究指出，肥胖兒童有二分之一的機率變成肥胖成人，肥胖青少年變成肥胖成年人的機率更高，達三分之二，未來都是血管疾病、糖尿病等慢性疾病的潛在病患。
- 了解嬰幼兒體重及身高生長情形，於每次健康檢查時，應計算身體質量指數(Body Mass Index，簡稱BMI)，並與醫師討論。
- 當孩子身體質量指數被定義為"體重過重或肥胖"時，(請參閱第126頁)，應尋求醫師或營養師建議，儘速調整生活作息，避免增加相關慢性疾病的風險。

**小提示**

BMI的計算方式：
BMI＝體重(公斤)／身高$^2$(公尺)
例如：
3歲孩子體重為18公斤
身高為100公分
BMI：18(公斤)/ $1^2$(公尺)= 18(肥胖)

# បណ្តុះទម្លាប់រស់នៅប្រកបដោយភាពសកម្ម

## បង្រៀនកូនឲ្យមានទម្លាប់រស់នៅប្រកបដោយភាពសកម្ម

- បង្រៀនឲ្យកុមារមុនវ័យសិក្សាធ្វើចលនាដោយប្រើកម្លាំងរាងកាយក្នុងកម្រិតមធ្យមដូចជា លេងបះបាល់ និងច្រៀងជាដើម។ រៀបចំឲ្យមានការធ្វើចលនារាងកាយដោយប្រើកម្លាំងមធ្យមនិងប្រើកម្លាំងពេញលេញ មានដូចជា រាំ ប្រកួតបាល់ វារឡើងវារចុះ និងរត់ឡើងរត់ចុះ រយៈពេល១ម៉ោង (អាចចែកជាដំណាក់កាល) ជារៀងរាល់ថ្ងៃ។
- ជារៀងរាល់ថ្ងៃ ទារកអាយុក្រោម៦ខែត្រូវធ្វើចលនាដេកផ្កាប់ប៉ុន្តែពេលចូលដំណេក មិនត្រូវដេកផ្កាប់ឡើយ ដើម្បីជៀសវាងកុំឲ្យកើតមានជម្ងឺទារកស្លាប់មួយរំពេច។
- កុំបង្ខាត់បង្ខាំងឱកាសនៃការធ្វើចលនារាងកាយរបស់កូន ឧទាហរណ៍ មិនមែនពេលបាយ កុំឲ្យកូនអង្គុយមួយកន្លែងនៅលើកៅអីតុបាយក្នុងបរិវេណដែលមានសុវត្ថិភាព ត្រូវឲ្យកូនបង្កើនបរិមាណនៃការធ្វើចលនារាងកាយ។
- មុនពេលកូនមានអាយុ២ឆ្នាំ មិនត្រូវឲ្យពួកគេមើលអេក្រង់ទូរទស្សន៍ ឬអេក្រង់នៃផលិតផលអេឡិចត្រូនិចផ្សេងៗនោះឡើយ។ក្រោយពេលអាយុ២ឆ្នាំជារៀងរាល់ថ្ងៃត្រូវកំណត់ពេលវេលាមើលអេក្រង់មិនឲ្យលើសពី២ម៉ោងមិនត្រូវដាក់ទូរទស្សន៍នៅក្នុងបន្ទប់កូនឡើយ ជៀសវាងបង្កឲ្យធាត់ដោយសារតែអង្គុយយូរ ម្យ៉ាងទៀតងាយនឹងទទួលឥទ្ធិពលពីពាណិជ្ជកម្មម្ហូបអាហារនៅលើទូរទស្សន៍។
- ឲ្យកូនទម្លាប់ឆាប់ចូលដំណេក និងឆាប់ក្រោកពីដំណេក និង រក្សាពេលវេលាដេកឲ្យបានគ្រប់គ្រាន់ដោយយោងទៅតាមអាយុរបស់កូន។

## ជៀសវាងជម្ងឺធាត់របស់កុមារ

- តាមការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា កុមារធាត់មានឱកាស១ភាគ២ក្លាយទៅជាមនុស្សពេញវ័យធាត់ ចំណែកឯក្មេងជំទន់ធាត់ក៏មានឱកាសក្លាយទៅជាមនុស្សមនុស្សពេញវ័យធាត់កាន់តែខ្ពស់ ដែលមានរហូតដល់២ភាគ៣ ដែលអាចក្លាយជាអ្នកជម្ងឺសសៃឈាម និងជម្ងឺទឹកនោមផ្អែមជាដើមនៅថ្ងៃអនាគត។
- ស្វែងយល់ពីទម្ងន់ និងកម្ពស់របស់កុមារ និងត្រូវគណនាសន្ទស្សន៍គុណភាពរាងកាយ (Body Mass Index ហៅកាត់ថា BMI) នៅរៀងរាល់ពេលពិនិត្យសុខភាពនិងធ្វើកាពិគ្រោះជាមួយវេជ្ជបណ្ឌិត។
- ពេលសន្ទស្សន៍គុណភាពរាងកាយកុមារត្រូវបានគេកំណត់ថា "មានទម្ងន់ធ្ងន់ពេក ឬធាត់" (សូមអានទំព័រទី 127)ត្រូវស្វែងរកដំបូន្មានរបស់វេជ្ជបណ្ឌិត ឬអ្នកជំនាញផ្នែកម្ហូបអាហារ និងធ្វើការកែប្រែទម្លាប់ក្នុងការរស់នៅ ដើម្បីជៀសវាងកំណើនឡើងនៃគ្រោះថ្នាក់បណ្តាលមកពីជម្ងឺរ៉ាំរ៉ៃ។

### រំលឹក

វិធីគណនា BMI៖

BMI = ទម្ងន់ (គីឡូក្រាម) / កម្ពស់$^2$ (ម៉ែត្រ)

ឧទាហរណ៍៖

កុមារអាយុ៣ឆ្នាំ មានទម្ងន់ 18 គីឡូក្រាម មានកម្ពស់ 100 សង់ទីម៉ែត្រ

BMI = 18 (គីឡូក្រាម) / $1^2$ (ម៉ែត្រ) = 18 (ធាត់)

# 嬰幼、兒童期每日膳食營養素

有關副食品添加原則，可參閱本手冊第140頁建議，如對嬰幼、兒童期營養有問題，請洽詢醫師或營養師提供諮詢協助。營養素足夠攝取量及建議量可至國民健康署網站（首頁/健康主題/體重管理、飲食、運動/飲食/食物營養與熱量/主題文章）查詢「國人膳食營養素參考攝取量」。飲食建議可至國民健康署健康九九網站搜尋「嬰兒期營養」、「幼兒期營養」及「學童期營養」。

## 蛋白質

依據第七版國人膳食營養素參考攝取量(DRIs)建議，動物性蛋白佔總蛋白質中的比例，1歲以下的嬰兒以佔2/3以上為宜。

## 礦物質

- **碘：**人體所需的碘大部分來自飲食，諸如：海苔、海帶、貝類、綠色蔬菜、蛋類、乳類、穀類等，其中以海帶、海藻等食物含碘量最為豐富。
- **鐵：**鐵質豐富的食物，如：深色蔬菜、紅肉、肝腎內臟、貝類等。
- **鈣：**含鈣質豐富的食物，除了鮮乳和乳製品之外，中式的傳統豆腐與豆乾所含的鈣亦是不錯的來源。
- 磷：主要來源為五穀根莖類、乳類、蛋、豆、魚、肉類、蔬菜類。
- 鎂：因為鎂為葉綠素組成份之一，因此鎂多存在於富含葉綠素的蔬菜中，如：菠菜、莧菜及甘藍菜。而胚芽、全穀類之麩皮、核果類、種子類及香蕉亦為鎂之豐富飲食來源。
- 鋅：動物性來源如肝臟、魚貝類及瘦肉的鋅含量高。

### 嬰幼兒膳食營養素參考攝取量

| 營養素 | 碘 | 鐵 | AI<br>鈣 | AI<br>磷 | 鎂 | AI<br>鋅 |
|---|---|---|---|---|---|---|
| 單位 / 年齡 | 微克 | 毫克 | 毫克 | 毫克 | 毫克 | 毫克 |
| 0 - 6月 | AI=110 | 7 | 300 | 200 | AI=25 | 5 |
| 7 - 12月 | AI=130 | 10 | 400 | 300 | AI=70 | 5 |
| 1 - 3歲 | 65 | 10 | 500 | 400 | 80 | 5 |
| 4 - 6歲 | 90 | 10 | 600 | 500 | 120 | 5 |
| 7 - 9歲 | 100 | 10 | 800 | 600 | 170 | 8 |

＊本表摘錄自依據第七版國人膳食營養素參考攝取量(DRIs)建議

＊表中未標明AI (足夠攝取量Adequate Intakes)值者，即為RDA (建議量Recommended Dietary allowance)值。

＊年齡係以足歲計算

小提示：

1. 建議攝取量(RDA)：是指可滿足97-98% 的健康人群一日所需要的營養素量
2. 足夠攝取量(AI)：當研究數據不足，無法訂出RDA，因而無法求出建議攝取量時，則以能滿足健康人群中每一個人為原則，以實驗或觀察(流行病學的)數據估算出的攝取量。

# សារធាតុចិញ្ចឹមក្នុងម្ហូបអាហារដែលវ័យទារក និងវ័យកុមារត្រូវស្រូបយកជារៀងរាល់ថ្ងៃ

ទាក់ទងនឹងវិធានក្នុងការបែន្ថមម្ហូបអាហាររង អាចអានដំបូន្មានទំព័រទី 141 នៃសៀវភៅនេះ។ ប្រសិនបើមានបញ្ហាទាក់ទងនឹងសារធាតុចិញ្ចឹមចំពោះទារកនិងកុមារ សូមធ្វើការប្រឹក្សាជាមួយវេជ្ជបណ្ឌិត ឬអ្នកជំនាញផ្នែកម្ហូបអាហារ។ បរិមាណសារធាតុចិញ្ចឹម និងដំបូន្មាន សូមចូលទៅកាន់គេហទំព័រទីស្នាក់ការសុខាភិបាលជាតិ ( ទំព័រដើម/សុខភាព/ការគ្រប់គងទម្ងន់ ការបរិភោគអាហារ និងការហាត់ប្រាណ/ការបរិភោគអាហារ/សារធាតុចិញ្ចឹមក្នុងអាហារនិងការឡូរី/អត្ថបទ ) ស្វែងរក "សេចក្តីយោងនៃការស្រូបយកសារធាតុចិញ្ចឹមក្នុងរបបអាហារស្រមាប្រ់បជាជន" ដំបូន្មានក្នុងការបរិភោគអាចចូលទៅកាន់គេហទំព័រសុខភាព៩៩នៃទីស្នាក់ការសុខាភិបាលជាតិស្វែងរក "សារធាតុចិញ្ចឹមក្នុងវ័យទារក" "សារធាតុចិញ្ចឹមក្នុងវ័យកុមារ" និង "សារធាតុចិញ្ចឹមកុមារវ័យសិក្សា" ។

## ប្រូតេអ៊ីន

យោងទៅតាម សេចក្តីយោងនៃការស្រូបយកសារធាតុចិញ្ចឹមក្នុងរបបអាហារស្រមាប្រ់បជាជន (DRIs0 បោះពុម្ពលើកទី៧ចំនួនសមាមាត្រនៃប្រូតេអ៊ីនសត្វធៀបទៅនឹងប្រូតេអ៊ីនសរុប ត្រូវមានឲ្យលើសពី2/3ចំពោះទារកអាយុក្រោម១ឆ្នាំ។

## សារជាតិរ៉ែ

- **អ៊ីយ៉ូត ៖** ជាតិអ៊ីយ៉ូតដែលសារពាង្គកាយមនុស្សត្រូវការ ភាគច្រើនបានមកពីអាហារ មានដូចជា៖ សារាយសមុទ្រ បន្លែសមុទ្រ សត្វមានសម្បក បន្លែបៃតង ស៊ុត ទឹកដោះ និងអាហារស្បៀង ដោយក្នុងនោះ សារាយសុមុទ្រ និងបន្លែសមុទ្រមានជាតិអ៊ីយ៉ូតខ្ពស់ជាងគេ។
- **ជាតិដែក ៖** អាហារដែលសម្បូរទៅដោយជាតិដែកមាន៖បន្លែពណ៌ចាស់សាច់ក្រហម គ្រឿងក្នុង និងសត្វមានសម្បក។
- **ជាតិកាល់ស្យូម ៖** អាហារដែលសម្បូរជាតិកាល់ស្យូម ក្រៅពីទឹកដោះគោស្រស់និងផលិតផលទឹកដោះគោ នៅមានតៅហ៊ូនិងតៅគួក៏ជាប្រភពនៃកាល់ស្យូមដែរ។
- ជាតិផូស្វរ៖ មានប្រភពចម្បងពី ធញ្ញជាតិ បន្លែមើម ទឹកដោះ ស៊ុត សណ្តែក ត្រី សាច់ និងបន្លែ។
- ជាតិម៉ាញ៉េស្យូម៖ ម៉ាញ៉េស្យូមគឺជាធាតុផ្សំនៃក្លូរ៉ូភីល ហេតុនេះវាសម្បូរនៅក្នុងបន្លែដែលមានជាតិក្លូរ៉ូភីល ដូចជា៖ ស្ពៃចង្កឹះ ផ្ទី និងស្ពៃក្តោប។ ចំណែកឯ ពន្លកបន្លែ កន្ទក់នៃអាហារស្បៀង ពពួកផ្លៃឈើមានគ្រាប់ ពពួកបន្លែផ្លៃឈើមានគ្រាប់ពូជ និងចេក គឺជាប្រភពដ៏សម្បូរនៃម៉ាញ៉េស្យូម។
- ជាតិស័ង្កសី៖ មានប្រភពមកពីសត្វ មាន ថ្លើម ត្រី សត្វមានសម្បក និងសាច់សុទ្ធ។

### សេចក្តីយោងនៃការស្រូបយកសារធាតុចិញ្ចឹមក្នុងរបបអាហារសម្រាប់ទារកនិងកុមារ

| សារធាតុចិញ្ចឹម | អ៊ីយ៉ូត | ដែក | AI កាល់ស្យូម | AI ផូស្វរ | ម៉ាញ៉េស្យូម | AI ស័ង្កសី |
|---|---|---|---|---|---|---|
| ឯកតា / អាយុ | ម្រ៊ីក្រូក្រាម | មីលីក្រាម | មីលីក្រាម | មីលីក្រាម | មីលីក្រាម | មីលីក្រាម |
| ០ ទៅ ៦ខែ | AI=110 | 7 | 300 | 200 | AI=25 | 5 |
| ៧ ទៅ ១២ខែ | AI=130 | 10 | 400 | 300 | AI=70 | 5 |
| ១ ទៅ ៣ឆ្នាំ | 65 | 10 | 500 | 400 | 80 | 5 |
| ៤ ទៅ ៦ឆ្នាំ | 90 | 10 | 600 | 500 | 120 | 5 |
| ៧ ទៅ ៩ឆ្នាំ | 100 | 10 | 800 | 600 | 170 | 8 |

* តារាងនេះដក្រសង់មកពី សេចក្តីយោងនៃការស្រូបយកសារធាតុចិញ្ចឹមក្នុងរបបអាហារស្រមាប្រ់បជាជន បោះពុម្ពលើកទី៧ (DRIs)

* អ្វីដែលក្នុងតារាងមិនបានបញ្ជាក់ថា ក្រមិត AI( បរិមាណសារធាតុចិញ្ចឹម្រគប់គាន់Adequate Intakes )គឺជាក្រមិត RDA( បរិមាណសារធាតុចិញ្ចឹមស្មើ Recommended Dietary allowance )។

* អាយុគណនាតាមអាយុពិត្របាកដ

រំលឹក៖

1. បរិមាណសារធាតុចិញ្ចឹមស្មើ (RDA)៖ សំដៅលើបរិមាណដែលអាចបំពេញត្រម្ងវការបរិមាណសារធាតុចិញ្ចឹមពី ៩៧ ទៅ ៩៨% ស្រមាប្រ់ក្រុមមនុស្សមានសុខភាពល្អក្នុងមួយថ្ងៃ។
2. បរិមាណសារធាតុចិញ្ចឹម្រគប់គាន់(AI)៖ខណៈទិន្នន័យស្រាវជ្រាវមិន្រគប់គាន់ មិនអាចកំណត់ RDA បាន នាំឲ្យមិនអាចគណនាបរិមាណសារធាតុចិញ្ចឹមស្មើ នោះគេចាត់ទុកថាអាចបំពេញត្រម្ងវការរបស់មនុស្សរាល់គ្នាក្នុងក្រុមមនុស្សសុខភាពល្អ បន្ទាប់មកគណនាបរិមាណសារធាតុចិញ្ចឹមតាមរយៈការធ្វើពិសោធឬការអង្កេត (ជម្ងឺឆ្លង)។

# 嬰幼、兒童期每日膳食營養素

## 維生素

- 維生素A：動物肝臟、蛋黃為富含維生素A之食物。深綠色與深橙黃色蔬菜水果為富含維生素A先質之食物。
- 維生素D：皮膚經陽光照射之合成是人類主要維生素D的來源，天然界含維生素D的食物種類不多，如：魚肝油、高油脂魚類的肉(如鮭魚、鮪魚及沙丁魚等)、海洋動物的肝臟、餵予維生素D的雞所產的蛋黃。
- 維生素E：穀類胚芽、植物油、深綠色蔬菜、蛋黃、堅果為含量較高的食物。
- 維生素K：肝臟類、綠色葉菜類。
- 維生素C：大部分新鮮的蔬菜、水果含量都很豐富。
- 維生素B1：全穀類及小麥胚芽含量最豐富。另外，瘦豬肉、肝臟、大豆及其製品、花生、葵花子、豌豆、酵母以及牛奶等都是維生素 B1的主要食物來源。
- 維生素B2：大部分的植物及動物組織皆含有維生素B2，其中牛奶、乳製品及強化穀類含量豐富。肉類、動物之內臟及綠色蔬菜亦是維生素B2之良好來源。
- 菸鹼素：富含菸鹼素的食物包含動物肝臟、牛肉、豬肉、雞肉、魚貝類、蛋奶類、乳酪、糙米、胚芽米、酵母菌、香菇、紫菜等。攝取足夠的蛋白質也是菸鹼素的來源，而體內若缺乏維生素B1、B2及B6亦會影響菸鹼素的製造，所以飲食中也要注意這些營養素的適宜攝取量。
- 維生素B6：動物性食品是維生素B6的良好飲食來源。植物中，全麥、糙米、豆類及堅果類均是維生素B6的良好食物來源；除此之外，馬鈴薯、青花菜、白花菜和水果中的香蕉、酪梨等也含有豐富的維生素B6。
- 維生素B12：主要來源為動物性食品，主要以肝臟、肉類等含量較豐，乳品類亦含少量，另外人體腸內細菌所合成之維生素B12可能有少許被吸收利用。
- 葉酸：葉酸主要的食物來源為，肝臟、酵母、綠葉蔬菜、豆類及一些水果都是其豐富的食物來源。

### 嬰幼兒膳食營養素參考攝取量

| 單位 | | AI | AI | AI | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 營養素 | 維生素A | 維生素D | 維生素E | 維生素K | 維生素C | 維生素B1 | | 維生素B2 | | 菸鹼素 | | 維生素B6 | 維生素B12 | 葉酸 |
| 單位 / 年齡 | 微克 | 微克 | 毫克 | 微克 | 毫克 | 毫克 | | 毫克 | | 毫克 | | 毫克 | 微克 | 微克 |
| 0-6月 | AI=400 | 10 | 3 | 2.0 | AI=40 | AI=0.3 | | AI=0.3 | | AI=2 | | AI=0.1 | AI=0.4 | AI=70 |
| 7-12月 | AI=400 | 10 | 4 | 2.5 | AI=50 | AI=0.3 | | AI=0.4 | | | | AI=0.3 | AI=0.6 | AI=85 |
| 1-3歲 | 400 | 5 | 5 | 30 | 40 | 0.6 | | 0.7 | | 9 | | 0.5 | 0.9 | 170 |
| | | | | | | 男 | 女 | 男 | 女 | 男 | 女 | | | |
| 4-6歲 | 400 | 5 | 6 | 55 | 50 | 0.9 | 0.8 | 1 | 0.9 | 12 | 11 | 0.6 | 1.2 | 200 |
| 7-9歲 | 400 | 5 | 8 | 55 | 60 | 1.0 | 0.9 | 1.2 | 1.0 | 14 | 12 | 0.8 | 1.5 | 250 |

＊本表摘錄自依據第七版國人膳食營養素參考攝取量(DRIS)建議

＊表中未標明AI(足夠攝取量Adequate Intakes)值者，及為RDA(建議量Recommended Dietary allowance)值。

＊年齡係以足歲計算

# សារធាតុចិញ្ចឹមក្នុងម្ហូបអាហារដែលវ័យទារក និងវ័យកុមារត្រូវស្រូបយកជារៀងរាល់ថ្ងៃ

## វីតាមីន

- វីតាមីន A៖ ថ្លើមសត្វ និងស៊ុតលឿង សម្បូរទៅដោយវីតាមីន A។ បន្លែផ្លែឈើពណ៌បៃតងចាស់និងពណ៌ទឹកក្រូចចាស់ សម្បូរទៅដោយវីតាមីនA។
- វីតាមីន D៖ ការសំយោគនៃស្បែកជាមួយពន្លឺព្រះអាទិត្យ គឺជាប្រភពវីតាមីន D ចម្បងរបស់មនុស្ស។ អាហារធម្មជាតិដែលមានវីតាមីន D មិនមានច្រើនឡើយ៖ ប្រេងថ្លើមត្រី សាច់ត្រីពពួកមានខ្លាញ់ច្រើន (ត្រីសាលម៉ុង ត្រីធូណា និងត្រីសាឌីន) ថ្លើមសត្វសមុទ្រ និង ស៊ុតលឿងកើតមកពីមាន់ចិញ្ចឹមឲ្យចំណីដោយវីតាមីន D។
- វីតាមីន E៖ ពន្លកនៃអាហារស្បៀង ប្រេងរុក្ខជាតិ បន្លែពណ៌បៃតងចាស់ ស៊ុតលឿង និងគ្រាប់ធញ្ញជាតិ។
- វីតាមីន K៖ ថ្លើម និងបន្លែស្លឹកពណ៌បៃតង។
- វីតាមីន C៖ សម្បូរក្នុង បន្លែ និងផ្លែឈើស្រស់ភាគច្រើន។
- វីតាមីន B1៖ សម្បូរក្នុងអាហារស្បៀង និងពន្លកស្រូវសាលី។ ក្រៅពីនេះសាច់សុទ្ធ ថ្លើម សណ្តែកនិងផលិតផលសណ្តែក សណ្តែកដី គ្រាប់ផ្កាឈូករ័ត្ន សណ្តែកក្រាម មេដំបែ និងទឹកដោះគោសុទ្ធតែជាប្រភេទអាហារសម្បូរទៅដោយវីតាមីន B1។
- វីតាមីន B2៖ កោសិកាសត្វនិងរុក្ខជាតិភាគច្រើនមានផ្ទុកនូវវីតាមីន B2 ក្នុងនោះ ទឹកដោះគោ ផលិតផលទឹកដោះគោ និងអាហារស្បៀង សម្បូរវីតាមីន B2 ជាងគេ។ ប្រភេទសាច់ គ្រឿងក្នុងសត្វ និងបន្លែពណ៌បៃតង ក៏ជាប្រភពនៃវីតាមីន B2 ដែរ។
- នេស៊ិន (Niacin)៖អាហារដែលសម្បូរនេស៊ិនរួមមាន ថ្លើមសត្វ សាច់គោ សាច់ជ្រូក សាច់មាន់ ត្រីសត្វមានសម្បក ទឹកដោះ ស៊ុត ឈីស អង្ករសំរូប អង្ករមានពន្លក មេដំបែ ផ្សិត និងជីឆាយ។ ការស្រូបយកប្រូតេអ៊ីនគ្រប់គ្រាន់ ក៏ជាប្រភពនៃនេស៊ិនដែរ។ ក្នុងខ្លួនប្រាណមនុស្ស ប្រសិនបើមានកង្វះវីតាមីន B1 B2 និង B6 នោះក៏ប៉ះពាល់ទៅដល់ការបង្កើតនេស៊ិនដែរ។ ហេតុដូចនេះក្នុងការបរិភោគអាហារ ត្រូវយកចិត្តទុកដាក់ទៅលើការស្រូបយកសារធាតុចិញ្ចឹមទាំងនេះឲ្យបានត្រឹមត្រូវ។
- វីតាមីន B6៖ អាហារប្រភេទសត្វ គឺជាប្រភពអាហារដែលមានវីតាមីន B6។ ស្រូវសាលី អង្ករសំរូប សណ្តែក និងគ្រាប់ធញ្ញជាតិ សុទ្ធតែជាប្រភពអាហារនៃវីតាមីន B6។ ក្រៅពីនេះ ដំឡូងបារាំង ផ្កាខាត់ណាខៀវ ផ្កាខាត់ណាស និងពពួកផ្លែឈើរួមមាន ចេក និងផ្លែបឺរ ក៏សម្បូរទៅដោយវីតាមីន B6 ដែរ។
- វីតាមីន B12៖ មានប្រភពចម្បងមកពីអាហារប្រភេទសត្វ ក្នុងនោះសម្បូរជាងគេក្នុងថ្លើម និងសាច់។ ផលិតផលទឹកដោះគោក៏មានចំនួនតិចតួចផងដែរ។ ក្រៅពីនេះ វីតាមីន B12 ដែលធ្វើសំយោគដោយបាក់តេរីក្នុងពោះវៀន អាចនឹងមានមួយចំនួនតូចត្រូវបានស្រូបយកទៅប្រើប្រាស់។
- ហ្វូលីកអាស៊ីត (folic acid)៖ មានប្រភពចម្បងមកពី ថ្លើម មេដំបែ បន្លែស្លឹកបៃតង សណ្តែក និងផ្លែឈើមួយចំនួន។

### សេចក្តីយោងនៃការស្រូបយកសារធាតុចិញ្ចឹមក្នុងរបបអាហារសម្រាប់ទារកនិងកុមារ

| ឯកតា | | AI | AI | AI | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សារធាតុចិញ្ចឹម | វីតាមីន A | វីតាមីន D | វីតាមីន E | វីតាមីន K | វីតាមីន C | វីតាមីន B1 | | វីតាមីន B2 | | នេស៊ិន (Niacin) | | វីតាមីន B6 | វីតាមីន B12 | ហ្វូលីកអាស៊ីត (folic acid) |
| ឯកតា / អាយុ | មីក្រូក្រាម | ម្រីកូក្រាម | មីលីក្រាម | មីក្រូក្រាម | មីលីក្រាម | មីលីក្រាម | | មីលីក្រាម | | មីលីក្រាម | | មីលីក្រាម | មីក្រូក្រាម | ម្រីកូក្រាម |
| ០ ទៅ ៦ខែ | AI=400 | 10 | 3 | 2,0 | AI=40 | AI=0,3 | | AI=0,3 | | AI=2 | | AI=0,1 | AI=0,4 | AI=70 |
| ៧ ទៅ ១២ខែ | AI=400 | 10 | 4 | 2,5 | AI=50 | AI=0,3 | | AI=0,4 | | | | AI=0,3 | AI=0,6 | AI=85 |
| ១ ទៅ ៣ឆ្នាំ | 400 | 5 | 5 | 30 | 40 | 0,6 | | 0,7 | | 9 | | 0,5 | 0,9 | 170 |
| | | | | | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| ៤ ទៅ ៦ឆ្នាំ | 400 | 5 | 6 | 55 | 50 | 0,9 | 0,8 | 1 | 0,9 | 12 | 11 | 0,6 | 1,2 | 200 |
| ៧ ទៅ ៩ឆ្នាំ | 400 | 5 | 8 | 55 | 60 | 1,0 | 0,9 | 1,2 | 1,0 | 14 | 12 | 0,8 | 1,5 | 250 |

* តារាងនេះដកស្រង់មកពី សេចក្តីយោងនៃការស្រូបយកសារធាតុចិញ្ចឹមក្នុងរបបអាហារស្រមាប់ប្រជាជន បោះពុម្ពលើកទី៧ (DRIs)
* អ្នកែដលក្នុងតារាងមិនបានបញ្ជាក់ថា ក្រមិត AI(បរិមាណសារធាតុចិញ្ចឹម្រគប់គ្រាន់Adequate Intakes)គឺជាក្រមិត RDA(បរិមាណសារធាតុចិញ្ចឹមស្មើ Recommended Dietary allowance)។
* អាយុគណនាតាមអាយុពិត្រប្រាកដ

# 嬰幼兒聽力自我評估

## 嬰幼兒聽力簡易居家行為量表

本量表的指標僅供家長參考，並不能取代專業的聽力檢查。除了新生兒聽力篩檢，我們也鼓勵孩子上幼稚園之前先至相關聽力單位進行學前聽力篩檢。若發現任何聽力上的問題，及時治療可避免孩子日後因聽力損失而在生活上有所不便。

**出生-2個月大**

□是，□否　1. 有無接受聽力篩檢？

□是，□否　2. 巨大的聲響會使孩子有驚嚇的反應。（如：用力關門聲、拍手聲）

□是，□否　3. 淺睡時會被大的說話聲或噪音干擾而扭動身體。

**3個月-6個月大**

□是，□否　4. 對著他說話時，他會偶爾發出咿咿唔唔的聲音或是有眼神的接觸。

□是，□否　5. 餵奶時，會因突發的聲音而停止吸奶。

□是，□否　6. 哭鬧時，聽見媽媽的聲音會安靜下來。

□是，□否　7. 會對一些環境中的聲音表現出興趣。（如：電鈴聲、狗叫聲、電視聲等）

**7個月至-12個月大**

□是，□否　8. 開始牙牙學語，例如ㄇㄚ、ㄅㄚ、ㄉㄚ等，並自得其樂。

□是，□否　9. 喜歡玩會發出聲音的玩具。

□是，□否　10. 開始對自己的名字會有回應，並了解「不可以」和「掰掰」的意思。

□是，□否　11. 當你從背後叫他，他會轉向你或者發出咿咿唔唔的聲音。

**1歲-2歲大**

□是，□否　12. 可以說簡單的單字。（如：爸爸、媽媽）

□是，□否　13. 可以了解簡單的指示。（如：給我）

□是，□否　14. 兩歲左右時，能夠重複你所說的話、片語（如：不要、沒有了），或是短句子（如：爸爸去上班）。

以上項目，在您對孩子持續觀察之後，若每個階段的答案為「否」者多於3項以上，建議讓您的孩子立即接受聽力檢查。

（本量表由雅文兒童聽語文教基金會　整理）

# រង្វាយតម្លៃខ្លួនឯងទៅលើសោតវិញ្ញាណរបស់ទារកនិងកុមារ

## តារាងរង្វាស់ការស្តាប់របស់ទារកនិងកុមារក្នុងការរស់នៅ

សន្ទស្សន៍ក្នុងតារាងនេះស្រមាប់តែជាឯកសារយោងតែប៉ុណ្ណោះ មិនអាចជំនួសការពិនិត្យសោតវិញ្ញាណជំនាញបានទេ។ ក្រៅពីសោតវិញ្ញាណរបស់ទារកទើបកើត ការពិនិត្យ យើងលើកទឹកចិត្តឲ្យកុមារធ្វើការពិនិត្យសោតវិញ្ញាណមុនពេលសិក្សានៅស្ថាប័នដែលពាក់ព័ន្ធនៅមុនពេលពួកគេចូលសាលាមត្តេយ្យ។ប្រសិនបើប្រទះឃើញថាមានបញ្ហាសោតវិញ្ញាណ ត្រូវធ្វើការព្យាបាលជាបន្ទាន់ ដើម្បីជៀសវាងផលវិបាកផ្សេងៗដែលបង្កឡើងនៅថ្ងៃក្រោយដោយសារការខូចខាតសោតវិញ្ញាណ។

### កើតបានអាយុ២ខែ

☐ មែន ☐ ទេ 1. មានធ្វើការពិនិត្យសោតវិញ្ញាណដែរឬទេ?

☐ មែន ☐ ទេ 2. សម្លេងខ្លាំង អាចធ្វើឲ្យកូនភ័យ។ (ឧទាហរណ៍៖ បិទទ្វារខ្លាំងៗ និងទះដៃ)

☐ មែន ☐ ទេ 3. ពេលមិនទាន់ដេកស្កប់ អាចនឹងរមួលខ្លួនប្រាណដោយសារការរំខានពីសម្លេងនិយាយខ្លាំងៗ ឬសម្លេងរំខានដទៃ។

### អាយុ ៣ ទៅ ៦ខែ

☐ មែន ☐ ទេ 4. ពេលនិយាយជាមួយកូន គេបញ្ចេញសម្លេង "អ៊ីអ៊ីអ៊ូអ៊ូ" ម្តងម្កាល ឬសម្លឹងមើលអ្នក។

☐ មែន ☐ ទេ 5. ពេលបញ្ចុកទឹកដោះ អាចនឹងឈប់បៅដោយសារសម្លេងចម្លែក។

☐ មែន ☐ ទេ 6. បាត់យំពេលលឺសម្លេងម្តាយ។

☐ មែន ☐ ទេ 7. មានចំណាប់អារម្មណ៍ចំពោះសម្លេងក្នុងមជ្ឈដ្ឋានខ្លះ។ (ដូចជា៖ សម្លេងកន្តឹង សម្លេងផ្គរលាន់ សម្លេងទូរទស្សន៍)

### អាយុ ៧ ទៅ១២ខែ

☐ មែន ☐ ទេ 8. ចាប់ផ្តើមរៀននិយាយ ឧទាហរណ៍ ㄇY, ㄅY, ㄉY ជាដើម ហើយសប្បាយចិត្តចំពោះរឿងនេះ។

☐ មែន ☐ ទេ 9. ចូលចិត្តលេងរបស់លេងដែលចេះបញ្ចេញសម្លេង។

☐ មែន ☐ ទេ 10. ចាប់ផ្តើមមានប្រតិកម្មជាមួយឈ្មោះខ្លួនឯង និងយល់ពីពាក្យ "អត់ទេ" និង "Byebye" ។

☐ មែន ☐ ទេ 11. ពេលអ្នកហៅគេពីក្រោយខ្នង គេនឹងបែរមករកអ្នក ឬបញ្ចេញសម្លេង "អ៊ីអ៊ីអ៊ូអ៊ូ" ។

### អាយុ ១ ទៅ ២ឆ្នាំ

☐ មែន ☐ ទេ 12. ចេះនិយាយពាក្យងាយៗ។ (ដូចជា៖ ប៉ា ម៉ាក់...)

☐ មែន ☐ ទេ 13. យល់ពីបញ្ជាងាយៗ។ (ដូចជា៖ ឲ្យខ្ញុំ)

☐ មែន ☐ ទេ 14. ពេលអាយុ២ឆ្នាំ ចេះស្រាប់តាមពាក្យ ឬឃ្លាដែលអ្នកនិយាយ (ដូចជា៖ កុំធ្វើអញ្ចឹង អស់ហើយ...) ឃ្លាខ្លី (ដូចជា៖ ប៉ាទៅធ្វើការ)។

ជម្រើសខាងលើ ធ្វើឡើងក្រោយពេលអ្នកធ្វើការសង្កេតទៅលើកូនរបស់អ្នក ប្រសិនបើដំណាក់កាលនីមួយៗមានចម្លើយ "ទេ" លើសពី៣ យើងណែនាំឲ្យកូនរបស់អ្នកធ្វើការពិនិត្យសោតវិញ្ញាណ។

(តារាងនេះរៀបចំឡើងដោយ មូលនិធិអប់រំនិងវប្បធម៌កុមារយ៉ាវិន)

# 兒童常見疾病及處理

小兒腹瀉及嘔吐、呼吸道感染、上呼吸道感染、哮吼、中耳感染、細支氣管炎、肺炎、腦膜炎及敗血症等是兒童常見疾病，以下提供一些預防警訊，供家長參考。

## 小兒腹瀉及嘔吐

- 腹瀉對寶寶而言是嚴重的疾病，如果腹瀉帶走體內大量的水份，就會脫水、電解質不平衡，嚴重的話會危及寶寶生命。因此，適時地補充水份非常重要！
- 如果寶寶出現下列情形之一，請儘速帶寶寶就醫：
  - 食慾不振
  - 在1-2小時內就解了數次水樣便，換了數次尿布
  - 頻繁嘔吐
  - 發燒
  - 非常口渴
  - 換下來的尿布帶血
  - 不尋常地躁動不安
  - 眼窩或是前囟門凹陷以及口乾
  - 持續腹瀉超過24小時
- 注意！寶寶腹瀉時請務必這樣做
  - 在腹瀉狀一開始，就必須給予足夠的水份，來補充流失的水份；先給予清淡的食物，等到狀況穩定下來再給予營養的食物。

  - 母乳寶寶，請增加母乳哺餵次數；若是以配方奶哺餵的寶寶，可如同往常給予補充液體，例如：煮沸過且已快速冷卻的水。
  - 除非有醫師的建議，否則小兒腹瀉時萬萬不可自行投予任何藥物。
  - 只要寶寶因為拉肚子而更換尿布，就替寶寶補充水分，可使用奶瓶、杯子或湯匙等工具給予。

  - 假如寶寶嘔吐，請勿馬上餵食，需等候10分鐘再替寶寶潤濕嘴唇。
  - 補充額外的水份，需持續至止瀉，期間通常是3-5天。
  - 請勿給寶寶飲用含糖飲料，例如果汁或碳酸飲料（包含檸檬水），因為這些飲料可能會使寶寶的腹瀉情形變得更嚴重。

  - 6個月以上的寶寶腹瀉時，仍可以給予食物，因為食物可以減緩腹瀉情形，並增強寶寶體力。

# ជម្ងឺកុមារទូទៅ និងដំណោះស្រាយ

ជម្ងឺកុមារទូទៅមានដូចជា រាគនិងក្អួត ផ្លូវដង្ហើមឆ្លងមេរោគ ផ្លូវដង្ហើមខាងលើឆ្លងមេរោគ រលាកស្ទះបំពង់ដង្ហើម ត្រចៀកផ្នែកកណ្តាលឆ្លងមេរោគ រលាកទងសួត រលាកសួត រលាកស្រោមខួរ និងជម្ងឺsepticemia។ ខាងក្រោមនេះយើងផ្តល់ឲ្យនូវវិធានការការពារ និងសញ្ញានៃជម្ងឺ ដែលអាណាព្យាបាលអាចយកជាសេក្តីយោងបាន។

## រាគនិងក្អួត

- រាគរូស គឺជាជម្ងឺដ៏ធ្ងន់ធ្ងរចំពោះទារក។ ប្រសិនបើរាគរូសនាំឲ្យបាត់បង់ជាតិទឹកច្រើន នោះនឹងបណ្តាលឲ្យខ្សោះជាតិទឹក និងអេឡិចត្រូលីតគ្មានសមាមាត្រ។ វាអាចមានគ្រោះថ្នាក់ដល់ជីវិតទារក ប្រសិនបើធ្ងន់ធ្ងរ។ ហេតុដូចនេះ ការប៉ូវជាតិទឹកឲ្យបានទៀងទាត់មានសារៈសំខាន់ណាស់!

- ប្រសិនបើទារកមានអាការៈខាងក្រោមនេះ សូមនាំទារកទៅមន្ទីរពេទ្យជាបន្ទាន់៖
  - មិនចង់ញុំាអាហារ
  - ក្នុងពេល ១ ទៅ ២ម៉ោង
    ជុះជាលាមករាវច្រើនដង ឬរកន្ទបច្រើនដង
  - ក្អួតញឹកញាប់
  - គ្រុនក្តៅ
  - ស្រេកទឹកខ្លាំង
  - កន្ទបដែលប្តូរចេញមានឈាម
  - អន្ទះសារមិនប្រក្រតី
  - ភ្នែកឬបង្ហើយផត និងស្ងួតមាត់
  - រាគលើសពី២៤ម៉ោង

- ប្រុងប្រយ័ត្ន! ពេលទារករាគ ចាំបាច់សូមធ្វើដូចនេះ
  - ពេលចាប់ផ្តើមមានរោគសញ្ញារាគ ចាំបាច់ត្រូវផ្តល់ជាតិទឹកឲ្យបានគ្រប់គ្រាន់ ដើម្បីប៉ះប៉ូវជាតិទឹកដែលបាត់បង់។ ឲ្យអាហារសាមញ្ញជាមុន រហូតអាការៈនេះគ្រាន់បើ ចាំឲ្យអាហារមានសារធាតុចិញ្ចឹមជាក្រោយ។

  - ទារកបៅទឹកដោះម្តាយ សូមបង្កើនចំនួនដងនៃការបំបៅ។ ប្រសិនបើទារកបៅម្សៅទឹកដោះគោ អាចប៉ះប៉ូវជាតិរាវដូចធម្មតា ឧទាហរណ៍៖ ទឹកដាំពុះនិងចុះត្រជាក់រួច។
  - លុះត្រាតែមានដំបូន្មានពីវេជ្ជបណ្ឌិត ពុំនោះទេពេលទារករាគមិនត្រូវឲ្យទារកលេបថ្នាំអ្វីជាដាច់ខាត។
  - ឲ្យតែទារកប្តូរកន្ទបដោយសារតែរាគ ត្រូវជួយបំពេញជាតិទឹកដល់ពួកគេ ដោយប្រើប្រាស់កំប៉ុងទឹកដោះគោ កែវទឹក ឬស្លាបព្រា។

  - ឧបមាថាទារកក្អួត ហាមបញ្ចុកអាហារភ្លាមៗ ត្រូវចាំប្រមាណ១០នាទី ទើបជួយផ្សើមមាត់ឲ្យទារក។
  - ការប៉ះប៉ូវជាតិទឹកបន្ថែម ត្រូវបន្តធ្វើរហូតដល់ឈប់រាគ ដែលជាទូទៅមានរយៈពេលពី ៣ ទៅ ៥ថ្ងៃ។
  - ហាមឲ្យទារកញុំាភេសជ្ជៈមានជាតិស្ករ ដូចជា ទឹកផ្លែឈើ ឬទឹកសូដា (រួមមានទឹកក្រូចឆ្មា) ព្រោះភេសជ្ជៈទាំងនេះអាចបណ្តាលឲ្យអាការៈរាគរូសរបស់ទារកកាន់តែធ្ងន់ធ្ងរ។

  - ពេលទារកអាយុលើសពី៦ខែរាគ នៅតែអាចឲ្យអាហារដល់ពួកគេ ព្រោះអាហារជួយកាត់បន្ថយអាការៈរាគ និងជួយពង្រឹងកម្លាំងទារក។

# 兒童常見疾病及處理

- 腹瀉的預防
  - 餵哺母乳，母乳是無菌且安全無虞的。
  - 烹調食物至滾熱，保存食物時器皿要保持清潔且加蓋，並冷藏保存。
  - 每個人如廁後及接觸寶寶前都必須先洗手，換尿布後也必須清潔雙手。
  - 如果寶寶使用配方奶，在開封後要儘快食用。
  - 詢問您的醫師關於奶瓶及奶嘴消毒方式的建議，所有用來泡奶粉的器具都必須保持清潔，哺餵的器具必須洗淨消毒（包含母乳哺餵的任何器具），奶瓶及奶嘴外的器具每使用3個月就須徹底清潔及沖洗1次。

## 呼吸道感染

呼吸道感染是孩童就醫最常見的問題，多數為病毒感染所致。最重要的預防之道就是多洗手、減少出入人多的公共場所或與病人接觸的機會。並且讓孩子多運動、吃飽、睡足，身體保持良好狀況。

## 上呼道感染

- 一般俗稱的『感冒』，由病毒感染引起的，主要症狀就是咳嗽、鼻塞、流鼻水、發燒、食慾不佳，有時伴有有嘔吐、拉肚子。
- 通常症狀在3、5天後就改善，就醫的主要目的是確定是否為單純的感冒，檢查有無併發症。

## 哮吼

- 哮吼是指喉部會厭下與氣管出現發炎腫脹，並且併發呼吸窘迫。
- 哮吼發生時，孩子的咳嗽聲會變得嘶啞，嚴重時伴隨呼吸困難。

### 小提示

**孩子哮吼發生時 ：**

- 讓他的身體保持溫暖。
- 多補充水分，可以從飲水或奶類中補充。
- 若出現呼吸困難，請立即就醫。
- 若是哮吼情況沒有改善，也請您向醫師求助。

# ជម្ងឺកុមារទូទៅ និងដំណោះស្រាយ

- ការបង្ការជម្ងឺរាគរូស
  - បញ្ចុកទឹកដោះម្តាយ។ ទឹកដោះម្តាយគ្មានបាក់តេរី និងមានសុវត្ថិភាព។
  - ចម្អិនអាហារឲ្យបានឆ្អិនល្អ ពេលរក្សាម្ហូបអហារទុកត្រូវធានាថាវត្ថុដែលវិចខ្ចប់ស្អាតមានអនាម័យ មានគម្រប និងរក្សានៅកន្លែងត្រជាក់។
  - ពេលចូលបង្គន់រួច បើចង់ប៉ះពាល់ទារកត្រូវលាងដៃឲ្យបានស្អាតជាមុន។ ពេលប្តូរកន្ទបទឹកនោមរួចក៏ត្រូវលាងសម្អាតដៃដែរ។
  - ប្រសិនបើទារកញ៉ាំទឹកដោះគោម្សៅ ពេលបើកគំរបហើយត្រូវញ៉ាំឲ្យបានឆាប់។
  - សាកសួរជាមួយវេជ្ជបណ្ឌិតរបស់អ្នកពីវិធីកម្ចាត់មេរោគនៅក្នុងកំប៉ុងទឹកដោះគោ និងក្បាលកំប៉ុងទឹកដោះគោ។ សម្ភារៈដែលយកមកឆុងម្សៅទឹកដោះគោ ត្រូវរក្សាអនាម័យជានិច្ច ចំណែកឯសម្ភារៈដែលយកមកបញ្ចុកត្រូវកម្ចាត់មេរោគជាមុន (រួមបញ្ចូលទាំងសម្ភារៈបញ្ចុកទឹកដោះម្តាយទាំងឡាយ)។ សម្ភារៈក្រៅពីកំប៉ុងទឹកដោះគោ និងក្បាលកំប៉ុងទឹកដោះគោ ត្រូវធ្វើការសម្អាតនិងលាងជម្រះម្តងរៀងរាល់រយៈពេល៣ខែ។

## ផ្លូវដង្ហើមឆ្លងមេរោគ

ផ្លូវដង្ហើមឆ្លងមេរោគ គឺជាជម្ងឺដែលតែងតែកើតមានចំពោះកុមារ។ ភាគច្រើនកើតឡើងដោយសារឆ្លងមេរោគ។ វិធីបង្ការដែលល្អជាងគេគឺ លាងដៃឲ្យបានញឹកញាប់ ជៀសវាងកន្លែងសាធារណៈដែលមានមនុស្សចេញចូលច្រើនឬជួបជាមួយអ្នកជម្ងឺ។ ម្យ៉ាងទៀតត្រូវឲ្យកូនធ្វើលំហាត់ប្រាណឲ្យបានច្រើន ញ៉ាំឲ្យបានឆ្អែត ដេកឲ្យបានគ្រប់គ្រាន់ ដើម្បីរក្សាលក្ខខណ្ឌល្អរបស់រាងកាយ។

## ផ្លូវដង្ហើមខាងលើឆ្លងមេរោគ

- "ផ្តាសសាយ" ដែលគេតែងតែហៅនេះ បណ្តាលមកពីការឆ្លងវីរ៉ុស។ អាការៈចម្បងគឺ ក្អក តឹងច្រមុះ ហៀរសំបោរ គ្រុនក្តៅ ញ៉ាំអាហារមិនបាន ពេលខ្លះអាចក្អួត និងរាគ។
- ជាធម្មតាអាការៈទាំងនេះនឹងប្រសើរឡើងវិញក្រោយរយៈពេល ៣ ទៅ ៥ថ្ងៃ។ ការពិនិត្យព្យាបាលជម្ងឺនេះ គឺធ្វើឡើងដើម្បីបញ្ជាក់ឲ្យដឹងថាតើវាជាជម្ងឺផ្តាសសាយធម្មតាឬយ៉ាងណា និងពិនិត្យថាតើមានអាការៈជម្ងឺដទៃទៀតឬទេ។

## ជម្ងឺស្ទះផ្លូវដង្ហើម

- ជម្ងឺស្ទះបំពង់ដង្ហើម សម្តៅទៅលើការរលាកនិងឡើងហើមនៃកន្លើតនិងបំពង់ខ្យល់ បណ្តាលឲ្យពិបាកដកដង្ហើម។
- ពេលកើតជម្ងឺស្ទះផ្លូវដង្ហើម សម្លេងក្អករបស់កូននឹងឡើងស្អក ពេលធ្ងន់ធ្ងរនាំឲ្យពិបាកដកដង្ហើម។

### រំលឹក

**ពេលកូនមានជម្ងឺស្ទះផ្លូវដង្ហើម៖**

- រក្សាកម្តៅខ្លួនរបស់គេ។
- បំពេញជាតិទឹកឲ្យបានច្រើន តាមរយៈផឹកទឹកឬទឹកដោះ។
- ប្រសិនបើពិបាកដកដង្ហើម ត្រូវទៅព្យាបាលនៅមន្ទីរពេទ្យជាបន្ទាន់។
- ប្រសិនបើជម្ងឺស្ទះផ្លូវដង្ហើមនៅតែមិនប្រសើរឡើង សូមសុំជំនួយពីវេជ្ជបណ្ឌិត។

# 兒童常見疾病及處理

## 中耳感染

- 中耳感染通常是病毒感染的細菌合併症，會造成中耳不適。
- 中耳感染的孩子，可能會有以下特徵：
  - 觸摸或拉耳朵，且煩躁哭鬧
  - 單邊耳朵看起來紅紅的，而且發熱發燒
  - 食慾不振嘔吐、腹瀉，或者上吐下瀉

### 小提示

**孩子罹患中耳炎時 ：**

- 不要用棉花棒清潔耳道，這可能會造成傷害或疼痛。
- 帶孩子尋求醫療協助。

## 細支氣管炎

- 多發生於兩歲以下的幼兒，為病毒感染引起細小氣管發炎阻塞所導致的症狀。主要的病毒之一為呼吸道融合病毒。
- 症狀開始像一般的感冒，隨後出現呼吸急促、哮喘、厭食等現象，有些會有嘔吐、腹瀉，大多數約一週左右會改善。
- 若出現呼吸變快、合併胸部凹陷、鼻孔隨著呼吸而搧動、無法進食時，有必要安排住院，給予氧氣和點滴注射。

## 肺炎

- 初期與感冒的症狀相似，不過肺炎可能會出現較嚴重的症狀，像是發燒較高、較多天，呼吸急促、疲倦、胸痛、胸凹等。
- 若判斷為細菌性肺炎，應接受適當的抗生素治療。

# ជម្ងឺកុមារទូទៅ និងដំណោះស្រាយ

## ត្រចៀកកណ្តាលឆ្លងមេរោគ

- ត្រចៀកកណ្តាលឆ្លងមេរោគ ជាទូទៅជាជម្ងឺកើតឡើងពីការឆ្លងបាក់តេរី នាំឲ្យត្រចៀកកណ្តាលមិនស្រួល។
- កុមារដែលត្រចៀកកណ្តាលឆ្លងមេរោគ នឹងមានអាការៈដូចខាងក្រោមនេះ៖
  - ប៉ះ ឬទាញត្រចៀក និង អន្ទះសារយំស្រែក
  - ត្រចៀកម្ខាងមើលទៅឡើងក្រហម និងគ្រុនក្តៅ
  - មិនចង់ញ៉ាំអាហារ ក្អួត រាគ ឬក្អួតលើរាគក្រោម

### រំលឹក

**ពេលកូនកើតជម្ងឺរលាកត្រចៀកកណ្តាល៖**

- មិនត្រូវយកសំឡីត្បាល់ត្រចៀកឡើយ វាអាចបណ្តាលឲ្យឈឺ ឬរបួស។
- នាំកូនទៅពិគ្រោះជាមួយវេជ្ជបណ្ឌិត។

## ជម្ងឺរលាកទងសួត

- ច្រើនកើតមានចំពោះកុមារអាយុក្រោម២ឆ្នាំ បណ្តាលមកពីឆ្លងមេរោគដែលបង្កឲ្យរលាកនិងស្ទះបំពង់ដង្ហើម។ មេរោគចម្បងជាងគេគឺ មេរោគលាយផ្លូវដង្ហើម។
- អាការៈដំបូងដូចកើតជម្ងឺផ្តាសសាយធម្មតា បន្ទាប់មកដកដង្ហើមញាប់ ដង្ហក់ និងខ្ពើមអាហារ មានខ្លះក្អួត និងរាគ ដែលភាគច្រើននឹងប្រសើរឡើងវិញក្នុងរយៈពេលប្រហែល១សប្តាហ៍។
- ប្រសិនបើដកដង្ហើមលឿន ដើមទ្រូងផត រន្ធច្រមុះកម្រើកតាមដំណាកដង្ហើម និងញ៉ាំអាហារមិនបាន ចាំបាច់ត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដោយដាក់អុកស៊ីសែន និងសារ៉ូម។

## ជម្ងឺរលាកសួត

- ដំណាក់កាលដំបូងមានអាការៈប្រហាក់ប្រហែលនឹងជម្ងឺផ្តាសសាយ ប៉ុន្តែជម្ងឺរលាកសួតអាចនឹងមានអាការៈធ្ងន់ធ្ងរជាង ដូចជា គ្រុនក្តៅខ្លាំងជាងនិងច្រើនថ្ងៃជាង ដកដង្ហើមញាប់ ហត់ ឈឺដើមទ្រូង និងផតទ្រូង។
- ប្រសិនបើពិនិត្យឃើញថាជាជម្ងឺរលាកសួតដោយបាក់តេរី នោះត្រូវធ្វើការព្យាបាលដោយអង់ទីប៊ីយ៉ូទិកឲ្យបានត្រឹមត្រូវ។

# 兒童常見疾病及處理

## 腦膜炎及敗血症

- 腦膜炎：發生在覆蓋腦及脊髓襯膜的感染或發炎，感染可來自細菌或病毒。敗血症：細菌進入血液系統所引起的嚴重感染。嬰幼兒的腦膜炎常合併敗血症發生，而敗血症可能會伴隨腦膜炎一起出現或者單獨出現。
- 腦膜炎及敗血症可能出現以下症狀，但不是每個患者都會同時出現所有的症狀，而且症狀發生的順序沒有一定的規律：
  - 活動力下降
  - 情緒變得焦躁，被抱起時會尖叫或呻吟
  - 頭上前囟門出現緊繃膨出
  - 頸部僵硬
  - 皮膚蒼白或出現紫斑
  - 手腳發冷並顫抖
  - 發高燒
  - 痙攣或抽搐
  - 劇烈頭痛
  - 嘔吐或拒絕進食
  - 身體僵硬、抽搐動作或癱軟，無精神
  - 出現紅色、棕色或紫色皮疹，或是皮膚上有黑色斑塊

## 川崎症

- 是一種多系統血管發炎的症候群，目前原因仍不清楚，好發於五歲以下的孩子。若無適當治療可能有20~25%會合併心血管併發症，是導致兒童後天性心臟病的主因。川崎症的診斷主要是依據病人的臨床症狀，且必須排除其他已知的疾病。
- **若孩子連續高燒5天以上**，請留意以下徵象並就醫，包括：
  - 紅眼睛
  - 嘴唇乾裂及草莓舌
  - 皮膚出現紅疹
  - 手掌手指、腳掌腳趾發紅腫脹或脫皮。
  - 頸部淋巴腺腫大

# ជម្ងឺកុមារទូទៅ និងដំណោះស្រាយ

## ជម្ងឺរលាកស្រោមខួរក្បាល និងជម្ងឺsepticemia

- ជម្ងឺរលាកស្រោមខួរក្បាល៖ ស្រោមស្រោបខួរក្បាលនិងខួរឆ្អឹងខ្នងឆ្លងមេរោគ ឬរលាក។ ការឆ្លងអាចបណ្តាលមកពីបាក់តេរី និងវីរុស។ ជម្ងឺsepticemia៖ បាក់តេរីមេរោគចូលក្នុងប្រព័ន្ធឈាម បណ្តាលឲ្យមានជម្ងឺឆ្លងធ្ងន់ធ្ងរ។ ជម្ងឺរលាកស្រោមខួរក្បាលរបស់ទារកច្រើនកើតមានជាមួយជម្ងឺsepticemia។ ចំណែកឯជម្ងឺsepticemia អាចកើតមានស្របគ្នាជាមួយជម្ងឺរលាកស្រោមខួរក្បាល ឬកើតមានដោយឡែកតែឯង។
- ជម្ងឺរលាកស្រោមខួរក្បាល និងជម្ងឺsepticemia អាចមានអាការៈដូចខាងក្រោម ប៉ុន្តែមិនមែនអ្នកជម្ងឺគ្រប់រូបសុទ្ធតែកើតមានអាការៈទាំងនេះស្របពេលគ្នាទាំងអស់នោះទេ ម្យ៉ាងទៀតអាការៈទាំងនេះកើតឡើងគ្មានលំដាប់ត្រឹមត្រូវឡើយ៖
  - ភាពរស់រវើកថយចុះ
  - ប្រែជាឆេវឆាវ ពេលត្រូវគេចាប់បីនឹងស្រែកឬថ្ងូរ
  - បង្ហើយលើក្បាលឡើងប៉ោង
  - កឡើងរឹង
  - ស្បែកសស្លេក ឬមានកន្ទួលពណ៌ស្វាយ
  - ដៃជើងត្រជាក់ និងញ័រ
  - គ្រុនក្តៅខ្លាំង
  - ប្រគៀវកាច់
  - ឈឺក្បាលខ្លាំងក្លា
  - ក្អួត ឬមិនចង់ញ៉ាំអាហារ
  - ខ្លួនប្រាណឡើងរឹង ប្រគៀវកាច់ ឬទន់ដៃទន់ជើង គ្មានស្មារតី
  - មានកន្ទួលពណ៌ក្រហម ពណ៌ត្នោត ឬពណ៌ស្វាយ ឬនៅលើស្បែកមានដុំស្នាមពណ៌ខ្មៅ

## ជម្ងឺវ៉ាកាសាគី

- ជាប្រជុំជម្ងឺរលាកសសៃឈាមច្រើនប្រព័ន្ធម្យ៉ាង ដែលបច្ចុប្បន្ននៅមិនទាន់រកឃើញមូលហេតុ។ តែងកើតមានចំពោះកុមារក្រោម៥ឆ្នាំ។ ប្រសិនបើមិនធ្វើការព្យាបាលឲ្យបានត្រឹមត្រូវនឹងបណ្តាលឲ្យឱកាស ២០% ទៅ ២៥% កើតមានជម្ងឺសសៃឈាមបេះដូង ដែលជាមូលហេតុចម្បងបណ្តាលឲ្យកុមារមានជម្ងឺបេះដូងនេះថ្ងៃក្រោយ។ ជម្ងឺវ៉ាកាសាគី ពិនិត្យឃើញបានតាមអាការៈរបស់អ្នកជម្ងឺ និងត្រូវដកចេញជម្ងឺដែលដឹងរួច។
- **ប្រសិនបើកុមារគ្រុនក្តៅ៥ថ្ងៃជាប់គ្នា**សូមយកចិត្តទុកដាក់ទៅលើអាការខាងក្រោម និងប្រញាប់ទៅធ្វើការព្យាបាល៖
  - ភ្នែកក្រហម
  - មាត់និងបបូរមាត់ស្ងួតប្រេះ និងជ្រាំងអណ្តែត
  - ស្បែកឡើងកន្ទួលក្រហម
  - បាតដៃម្រាមដៃបាតជើងម្រាមជើងឡើងហើមក្រហម ឬរបកស្បែក
  - ក្រពេញទឹករងៃផ្នែកកឡើងហើម

# 腸絞痛

有些寶寶在10天到3個月大時會在傍晚或半夜的時候哭鬧，令父母手足無措且神經緊張，腸絞痛是可能的原因之一。目前腸絞痛發生的原因尚不清楚，每個寶寶發生的情況也有所不同，以下幾個處理原則供父母參考。

## 腸絞痛最常發生在何時

- 腸絞痛通常發生在10天至3個月大的寶寶。約20%的寶寶在第2週至第4週大時開始出現腸絞痛狀況，高峰期大約在6週大時。
- 腸絞痛的寶寶會在傍晚或半夜的時候哭鬧，雖然感覺有餓卻拒絕吸奶，因為哭鬧而臉部漲紅，並高舉他的大腿或脹氣放屁。
- 腸絞痛寶寶的哭鬧很難安撫，一天可能出現3個小時，之後慢慢降低至一天約1-2個小時，直到3-4個月大時狀況開始消失，最晚持續到6個月大。

## 腸絞痛發生的原因

- 寶寶腸絞痛發生原因不明，有可能是寶寶受到某種刺激、情緒無法得到安撫，也可能是寶寶神經系統尚未發育成熟。
- 少數的腸絞痛是牛奶蛋白過敏所造成。
- 重要的是，腸絞痛需要和疝氣等急症鑑別。當寶寶發生腸絞痛時，兒科醫師會先判斷寶寶哭鬧的原因是不是因為其他需治療的疾病所引起。

## 如何改善腸絞痛

腸絞痛發生原因未明，每個寶寶發生的情況亦有不同，沒有一種方法可以適用所有寶寶，下列方法父母可多管齊下，以便改善寶寶的症狀：

- 關於哺餵，母乳媽媽自己可嘗試減少食用乳製品、咖啡因、洋蔥、甘藍菜（包心菜），和其他可能引起腸絞痛的食物；配方奶寶寶則可和醫師討論是否需要改變餵食種類。
- 不要過量哺餵寶寶，嘗試將餵奶的間隔拉長至少兩個至兩個半小時。
- 帶寶寶散步來安撫他。
- 輕搖寶寶，帶他到另一個沒人的房間或可以聽到烘衣機／洗衣機、電風扇等會發出規律低沉聲音的家電旁邊。穩定節奏的輕搖及聲音可以幫助寶寶入睡，但不可以直接把寶寶放在洗衣機或烘衣機上面。
- 奶嘴有安撫作用，如果寶寶願意吃奶嘴，可以嘗試給予寶寶吸吮奶嘴。
- 讓寶寶趴著，橫跨在大人雙腿上，並輕輕拍撫他的背。這樣可以讓寶寶腹部受壓力，幫助他舒服點。
- 將寶寶裹在大的薄毯裡，讓他感覺到安全感及溫暖；但一定要注意避免呼吸道阻塞，或是造成體溫過高。

# ចុកឈឺពោះវៀន

មានទារកអាយុពី ១០ថ្ងៃ ទៅ ៣ខែ ខ្លះស្រែកយំពេលល្ងាច ឬពាក់កណ្ដាលយប់ តែងធ្វើឲ្យម្ដាយឪពុកភិតភ័យនៅមិនសុខ មូលហេតុអាចបណ្ដាលមកពីឈឺចុកពោះវៀន។ បច្ចុប្បន្នេគមិនទាន់ដឹងច្បាស់ពីមូលហេតុនៃការឈឺចុកពោះវៀននៅឡើយ។ ទារកម្នាក់ៗមានស្ថានភាពឈឺខុសៗគ្នា។ សូមម្ដាយឪពុកអាននូវដំណោះស្រាយមួយចំនួនខាងក្រោម។

## តើការឈឺចុកពោះវៀនតែងកើតមាននៅពេលណា

- ជម្ងឺឈឺចុកពោះវៀនច្រើនកើតមានចំពោះទារកអាយុ ១០ថ្ងៃ ទៅ ៣ខែ។ មានទារក ២០% ចាប់ផ្ដើមកើតមានអាការៈឈឺចុកពោះវៀនក្នុងអាយុ២សប្ដាហ៍ ទៅ ៤សប្ដាហ៍ និង កើតឡើងខ្ពស់ពេលអាយុ៦សប្ដាហ៍។
- ទារកដែលឈឺចុកពោះវៀននឹងស្រែកយំពេលល្ងាច ឬពេលកណ្ដាលអធ្រាត ថ្វីត្បិតតែឃ្លាតែមិនព្រមបៅទឹកដោះដោយសារតែស្រែកយំ នាំឲ្យមុខឡើងក្រហម ព្រមទាំងលើកជើង ឬហើមពោះដោម។
- ទារកដែលឈឺចុកពោះវៀនពិបាកនឹងលួងលោមមួយថ្ងៃអាចកើតឡើងរយៈពេល៣ម៉ោង បន្ទាប់មកកាត់បន្ថយបន្តិចម្ដងៗរហូតដល់មួយថ្ងៃកើតឡើងរយៈពេល១ ទៅ ២ម៉ោង-ពេលអាយុ៤ខែ អាការៈទាំងនេះនឹងចាប់ផ្ដើមបាត់ ដែលយូរបំផុតនឹងមានរហូតដល់អាយុ៦ខែ។

## មូលហេតុដែលបណ្ដាលឲ្យកើតមានការឈឺចុកពោះវៀន

- មូលហេតុនៃការឈឺចុកពោះវៀនរបស់ទារកមិនច្បាស់លាស់ឡើយ វាអាចបណ្ដាលមកពីទារកទទួលរងការភ្ញោចអ្វីម្យ៉ាង នាំឲ្យអារម្មណ៍មិនស្ងប់ ហើយក៏អាចបណ្ដាលមកពីប្រព័ន្ធប្រសាទរបស់ទារកមិនទាន់លូតលាស់ពេញលេញ។
- មានការឈឺចុកពោះវៀនមួយចំនួនតូចបណ្ដាលមកពីប្រតិកម្មជាមួយនឹងប្រូតេអ៊ីនទឹកដោះគោ។
- អ្វីដែលសំខាន់នោះគឺ ការឈឺចុកពោះវៀន ត្រូវធ្វើការពិនិត្យជាមួយប្រភេទជម្ងឺសង្គ្រោះបន្ទាន់ដទៃ ដូចជា ជម្ងឺក្លូនជាដើម។ ពេលទារកឈឺចុកពោះវៀនវេជ្ជបណ្ឌិតនឹងពិនិត្យជាមុនថាតើមូលហេតុនៃការយំរបស់ទារកអាចបណ្ដាលមកពីជម្ងឺដទៃដែលត្រូវព្យាបាលដែរឬទេ។

## តើកែខៃការឈឺចុកពោះវៀនដោយវិធីណា

ជម្ងឺឈឺចុកពោះវៀនមានមូលហេតុមិនច្បាស់លាស់ ទារកម្នាក់មានស្ថានភាពខុសៗគ្នា ដូចេនះគ្មានវិធីណាមួយដែលសាកសមនឹងប្រើចំពោះទារគ្រប់រូបឡើយ។ វិធីខាងក្រោមនេះ ម្ដាយឪពុកអាចអនុវត្តទាំងស្រុងដើម្បីកែខអាការៈជម្ងឺរបស់ទារក៖

- ទាក់ទងនឹងការបំបៅទឹកដោះនិងអាហារ ម្ដាយខ្លួនឯងអាចសាកល្បងកាត់បន្ថយការទទួលទានផលិតផលទឹកដោះគោ កាហ្វេអ៊ីន ខ្ទឹមបារាំង ស្ពៃក្ដោប នឹងអាហារដទៃដែលអាចបណ្ដាលឲ្យឈឺចុកពោះវៀន។ ចំពោះម្សៅទឹកដោះគោរបស់ទារក អាចធ្វើការពិគ្រោះជាមួយគ្រូពេទ្យថាតើគួរផ្លាស់ប្ដូរប្រភេទឬទេ។
- កុំផ្ដល់អាហារឲ្យទារកច្រើនហួសកម្រិត សាកល្បងពន្យាចន្លោះពេលបំបៅទឹកដោះយ៉ាងហោចពី ២ម៉ោង ទៅ ២ម៉ោងកន្លះ។
- លួងលោមទារកដោយនាំគេដើរលំហែ។
- អង្រួនទារកថ្នមៗ នាំគេទៅបន្ទប់ដែលគ្មានមនុស្ស ឬនាំទៅក្បែរគ្រឿងអគ្គិសនីដែលបញ្ចេញសម្លេងតិចៗនិងមានសម្លេងទៀតទាត់ ដូចជា ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនកម្ដៅខោអាវ និងកង្ហាជាដើម។ ការអង្រួនថ្នមៗនិងសម្លេងដែលមានចង្វាក់ថេរ ជួយឲ្យកុមារដេកលង់លក់ ប៉ុន្ដែមិនអាចយកទារកដាក់លើម៉ាស៊ីនបោកខោអាវ ឬម៉ាស៊ីនកម្ដៅខោអាវនោះទេ។
- ក្បាលកំប៉ុងទឹកដោះគោអាចជួយលួងលោមទារក ប្រសិនបើទារកព្រមបៀម អាចសាកល្បងឲ្យគេបៀមបាន។
- ឲ្យទារកក្រាបលើជើងទាំងសងខាងរបស់មនុស្សធំ ព្រមទាំងវាយខ្នងរបស់គេថ្នមៗ។ ធ្វើដូចនេះជួយឲ្យផ្ទៃកពោះរបស់ទារករងនូវសម្ពាធ ជួយឲ្យគេស្រួលខ្លួនបន្តិច។
- រុំទារកក្នុងភួយស្ដើង ឲ្យគេមានអារម្មណ៍សុវត្ថិភាព និងកក់ក្ដៅប៉ុន្ដែត្រូវប្រុងប្រយ័ត្នកុំឲ្យស្ទះផ្លូវដង្ហើម ឬកម្ដៅខ្លួនឡើងខ្លាំង។

# 不和腸病毒打交道

腸病毒感染症是臺灣的季節性流行疾病，但全年都有感染個案發生，患者以5歲以下幼兒為主，尤其以3歲以下幼兒為腸病毒感染併發重症的高危險群。

## 腸病毒感染途徑

- 腸病毒的傳染性極強，可經由腸胃道（糞-口、水或食物污染）、呼吸道(飛沫、咳嗽或打噴嚏)，也可經由接觸病人的皮膚水泡潰瘍液體而感染。
- 新生兒在生產過程中接觸到母親產道分泌物，或是接觸母親的血液及呼吸道分泌物，也可能感染。出生後的感染源可能來自母親及其他人。

## 感染腸病毒常見症狀

- 大多數腸病毒感染沒有症狀，或類似一般感冒。有時會引起較特殊的臨床表現，常見的有手足口病、疱疹性咽峽炎等，可以至疾病管制署網站（http://www.cdc.gov.tw）點選傳染病介紹中有關腸病毒的說明。
- 大部分新生兒感染後症狀都不嚴重，但少數會出現心肌炎、肝炎、腦炎、血小板下降、多發性器官衰竭等敗血症徵候，甚至死亡。

**小提示**

**腸病毒重症前表現病徵**

在發病後7天內，出現下列病徵，應及早就醫，包括：持續發燒、嗜睡、意識不清、活動力降低、手腳無力、肌躍型抽搐(有如受到驚嚇的肢體抽動)、持續嘔吐、不發燒時心跳加快等症狀。

## 預防腸病毒的方法

- 勤於正確洗手，保持良好個人衛生習慣。
- 注意環境衛生及居家環境良好通風。
- 儘量避免出入擁擠之公共場所，或與疑似病患接觸。
- 注意營養、均衡飲食、運動及充足的睡眠，都可以增強免疫力。餵食母乳，也可提高嬰兒抵抗力。
- 在摟抱、親吻或餵食幼兒前，務必更衣洗手。
- 若幼童經診斷感染腸病毒時，最好讓病童請假在家休息至少一星期，以避免傳給他人。
- 孕婦在生產前後有疑似腸病毒感染症狀時，產後要加強在接觸嬰兒前後的洗手、戴口罩及個人衛生，也要注意觀察新生兒的體溫及活力表現。
- 當嬰兒有不明原因的發燒、精神活力變差時，應立即就醫，如曾有接觸到發燒或腸病毒感染的患者，也應主動告知醫師。

# មិនប៉ះពាល់វីរុសពោះវៀន

ជម្ងឺឆ្លងមេរោគពោះវៀន គឺជាជម្ងឺឆ្លងតាមរដូវនៅតៃវ៉ាន់ ប៉ុន្តែជារៀងរាល់ឆ្នាំតែងមានករណីឆ្លង ដែលអ្នកជម្ងឺជាកុមារអាយុក្រោម៥ឆ្នាំជាចម្បង ជាពិសេសកុមារអាយុក្រោម៣ឆ្នាំគឺជាក្រុមគ្រោះថ្នាក់ខ្ពស់នៃជម្ងឺឆ្លងមេរោគពោះវៀននិងជម្ងឺដៃទៃដែលបណ្តាលមកពីជម្ងឺនេះ។

## មធ្យោបាយឆ្លងនៃមេរោគពោះវៀន

- មេរោគពោះវៀនមានការរាតត្បាតខ្លាំង អាចឆ្លងតាមរយៈផ្លូវអាហារ (មាត់ ទឹក ឬអាហារ) ផ្លូវដង្ហើម (ក្អក ឬកណ្តាស់) ហើយក៏អាចឆ្លងតាមរយៈការប៉ះពាល់ទឹករងៃឬទឹកខ្ទុះនៅលើស្បែកអ្នកជម្ងឺ។
- ក្នុងពេលសម្រាល ទារកក៏អាចឆ្លងដោយប៉ះពាល់វត្ថុធាតុរាវក្នុងទ្វារមាសរបស់ម្តាយ ឬប៉ះពាល់ឈាមឬវត្ថុធាតុនៃផ្លូវដង្ហើមម្តាយ។ ប្រភពចម្លងក្រោយពេលកើត អាចមកពីម្តាយ ឬអ្នកដទៃ។

## អាការៈទូទៅនៃជម្ងឺឆ្លងមេរោគពោះវៀន

- ជម្ងឺឆ្លងមេរោគពោះវៀនភាគច្រើនគ្មានអាការៈជាក់ស្តែងឡើយ ឬមានអាការៈប្រហាក់នឹងជម្ងឺផ្តាសសាយ។ ពេលខ្លះក៏បណ្តាលឲ្យមានអាការៈជម្ងឺពិសេស ដែលជាទូទៅជា ជម្ងឺដៃជើងមាត់ ឬឡើងពងដើមកជាដើម។ អាចអានសេចក្តីបញ្ជាក់អំពីជម្ងឺឆ្លងមេរោគពោះវៀន ក្នុងគេហទំព័រនៃទីស្នាក់ការគ្រប់គ្រងជម្ងឺ (http://www.cdc.gov.tw)។
- ទារកទើបកើតភាគច្រើនដែលឆ្លងជម្ងឺនេះរួចមិនមានអាការៈធ្ងន់ធ្ងរនោះទេ ប៉ុន្តែភាគតិចអាចមានសញ្ញានៃជម្ងឺsepticemia ដូចជា រលាកសាច់ដុំបេះដូង រលាកថ្លើម រលាកខួរក្បាល ថយចុះប្លាកែតក្នុងឈាម និងសរីរាង្គចុះខ្សោយជាដើម និង រហូតអាចស្លាប់បាត់បង់ជីវិត។

> **រំលឹក**
>
> **អាការៈនៃជម្ងឺឆ្លងមេរោគពោះវៀនធ្ងន់ធ្ងរ**
>
> ក្នុងរយៈពេល៧ថ្ងៃក្រោយកើតជម្ងឺ និងមានអាការៈដូចខាងក្រោម ត្រូវតែនាំទៅព្យាបាលឲ្យបានឆាប់រហ័ស៖ គ្រុនក្តៅមិនបាត់ ងងុយដេក ស្មារតីមិនភ្លឺស្វាង ភាពរស់រវើកថយចុះ ដៃជើងគាំងកម្លាំង កន្ទាក់សាច់ដុំ(កន្ទាក់ពេលភ័យភ្ញាក់) ក្អួតមិនឈប់ និងពេលមិនគ្រុនក្តៅបេះដូងលោតញាប់។

## វិធីបង្ការមេរោគពោះវៀន

- លាងដៃឲ្យបានត្រឹមត្រូវ និងឲ្យបានញឹកញាប់ រក្សាទម្លាប់អនាម័យល្អ។
- ប្រុងប្រយ័ត្នចំពោះអនាម័យនៃបរិស្ថាន និងមានខ្យល់ចេញចូលគ្រប់គ្រាន់។
- ជៀសវាងចេញចូលកន្លែងសាធារណៈដែលមានមនុស្សច្រើនកុះករ ឬប៉ះពាល់អ្នកដែលសង្ស័យថាមានជម្ងឺ។
- ប្រុងប្រយ័ត្នចំពោះសារធាតុចិញ្ចឹម បរិភោគអាហារឲ្យមានសមាមាត្រត្រឹមត្រូវ ហាត់ប្រាណនិងដេកឲ្យបានគ្រប់គ្រាន់ ដែលវាជួយពង្រឹងប្រព័ន្ធស៊ាំនៃរាងកាយ។ បំបៅទឹកដោះម្តាយ ក៏អាចជួយពង្រឹងប្រព័ន្ធស៊ាំរបស់ទារកដែរ។
- មុនពេលឱប ថើប និងបញ្ចុកអាហារដល់ទារក ត្រូវផ្លាស់ខោអាវនិងលាងដៃ។
- ប្រសិនបើកុមារកើតជម្ងឺឆ្លងមេរោគពោះវៀន យល់ល្អសុំច្បាប់ឲ្យគេសម្រាកនៅផ្ទះយ៉ាងហោចណាស់១សប្តាហ៍ ជៀសវាងកុំឲ្យចម្លងដល់អ្នកដទៃ។
- មុននិងក្រោយពេលសម្រាលកូន ប្រសិនបើស្ត្រីសង្ស័យថាមានអាការៈជម្ងឺឆ្លងមេរោគពោះវៀន នោះក្រោយពេលសម្រាលត្រូវយកចិត្តទុកដាក់ខ្លាំងទៅលើ ការលាងដៃមុននិងក្រោយពេលប៉ះពាល់ទារក ពាក់ម៉ាសមាត់ និងអនាម័យផ្ទាល់ខ្លួន ហើយក៏ត្រូវយកចិត្តទុកដាក់ចំពោះកម្តៅខ្លួន និងភាពរស់រវើករបស់ទារកដែរ។
- ពេលទារកគ្រុនក្តៅ ឬភាពរស់រវើកនិងស្មារតីមិនល្អ ដោយមិនដឹងមូលហេតុ ត្រូវទៅពិនិត្យនៅមន្ទីរពេទ្យជាបន្ទាន់។ ប្រសិនបើធ្លាប់ប៉ះពាល់អ្នកជម្ងឺគ្រុនក្តៅ ឬអ្នកជម្ងឺឆ្លងមេរោគពោះវៀន ត្រូវប្រាប់ទៅដល់វេជ្ជបណ្ឌិត។

# 發燒的正確處置

發燒是兒童生病最常見的症狀表現之一，但發燒未必就是疾病引起。發燒可以促進免疫功能，貿然退燒未必有助孩子的健康，應把握正確處理原則，避免不當的退燒方法，才能夠協助孩子康復。

## 關於發燒現象

- 發燒的定義為身體內部中心體溫 ≥ 38°C。
- 人體生病引起的發炎反應會讓體溫的定位點提高，所以造成發燒現象。
- 開始發燒時，身體會感到發寒、四肢冰冷，這是體溫定位點上升的結果。
- 一旦體溫提高到定位點之後，四肢會變溫熱，也不會有明顯怕冷的感覺。
- 發燒一段時間或使用退燒藥以後，體溫定位點下降，身體可能會覺得熱，並開始流汗退燒。

## 測量體溫

- 肛溫最接近身體內部的中心體溫，耳溫與肛溫的相關性很高，但三個月以下嬰兒的耳溫與中心體溫的相關性較差。
- 口溫平均比肛溫低，腋溫平均比肛溫低。
- 一個月以下或體重很低的新生兒，不適合量肛溫與耳溫，可考慮量腋溫或背溫。

## 重新認識發燒的影響

- 適度發燒可以提升免疫系統的效能，有研究顯示退燒藥會壓抑身體免疫反應，反而可能延緩疾病的康復。
- 人體對發炎反應引起的發燒有調控機制，所以一般不會超過 41°C。
- 有些家長擔心如果不積極退燒，孩子的體溫可能一直往上飆高，其實人體的體溫調控機制不會讓體溫無限上升。坊間孩子腦子燒壞的傳說，其實是孩子罹患腦炎、腦膜炎等疾病而留下神經後遺症，與發燒無直接因果關係。

## 必須注意的危險病徵

有無發燒和體溫高低都不一定能代表疾病嚴重程度。兒童生病時，重要的是觀察有無重症危險病徵，如果有下列情形就必須儘速至醫師處診治。

- 三個月以下嬰兒出現發燒症狀
- 尿量大幅減少
- 哭泣時沒有眼淚
- 痙攣、肌抽躍（肌肉不自主快速抽動，像觸電一樣）、肢體麻痺、感覺異常
- 咳痰有血絲
- 呼吸暫停

# ដំណោះស្រាយត្រឹមត្រូវពេលគ្រុនក្តៅ

គ្រុនក្តៅគឺជាអាការៈទូទៅជាងគេពេលកុមារមានជម្ងឺ ប៉ុន្តែគ្រុនក្តៅមិនមែនសុទ្ធតែកើតឡើងដោយសារជម្ងឺនោះទេ។ គ្រុនក្តៅអាចជួយព្រងឹងមុខងារប្រព័ន្ធស៊ាំ ហេតុនេះការបញ្ចុះកម្តៅខ្លួនផ្តេសផ្តាសមិនសុទ្ធតែជួយឲ្យកុមារមានសុខភាពល្អនោះទេ គប្បីក្តោបក្តាប់នូវវិធានៃដំណោះស្រាយដែលត្រឹមត្រូវ ជៀសវាងវិធីបញ្ចុះកម្តៅមិនត្រឹមត្រូវ ទើបអាចជួយឲ្យកុមារជាសះស្បើយ។

## ទាក់ទងនឹងអាការៈគ្រុនក្តៅ

- គ្រុនក្តៅ មានន័យថា ចំនុចកណ្តាលខាងក្នុងរាងកាយមានកម្តៅ ⩾ 38ºC។
- ប្រតិកម្មនៃការរលាកដែលបណ្តាលមកពីរាងកាយមានជម្ងឺ បង្កឲ្យចំណុចកម្តៅខ្លួនកើនឡើង បង្កើតបានជាអាការៈគ្រុនក្តៅ។
- ពេលចាប់ផ្តើមគ្រុនក្តៅ រាងកាយនឹងមានអារម្មណ៍រងារ និងត្រជាក់ដៃជើង នេះជាលទ្ធផលដែលបណ្តាលមកពីកំណើនឡើងនៃចំណុចកម្តៅខ្លួន។
- ពេលដែលកម្តៅខ្លួនឡើងដល់ចំណុចនេះ ដៃជើងចាប់ផ្តើមប្រែជាក្តៅ និងមិនសូវមានអារម្មណ៍ថារងារទៀតឡើយ។
- ក្រោយពេលគ្រុនក្តៅមួយរយៈ ឬប្រើឱសថបញ្ចុះកម្តៅរួច ចំណុចកម្តៅខ្លួននឹងធ្លាក់ចុះ ខ្លួនប្រាណអាចនឹងឡើងក្តៅ បន្ទាប់មកចាប់ផ្តើមហូរញើសនិងធ្លាក់កម្តៅ។

## វាស់កម្តៅខ្លួន

- កម្តៅទ្វារធំ វាមានកម្តៅប្រហាក់ប្រហែលជាងគេទៅនឹងកម្តៅចំណុចកណ្តាលខាងក្នុងរាងកាយ។ កម្តៅទ្វារធំ និងកម្តៅត្រចៀក មានទំនាក់ទំនងគ្នាខ្លាំង ប៉ុន្តែកម្តៅត្រចៀកទារកអាយុក្រោម៣ខែមានទំនាក់ទំនងខ្សោយទៅនឹងកម្តៅចំណុចកណ្តាលខាងក្នុងរាងកាយ។
- កម្តៅមាត់ជាមធ្យមទាបជាងកម្តៅទ្វារធំ។ កម្តៅក្លៀកជាមធ្យមទាបជាងកម្តៅទ្វារធំ។
- ទារកទើបកើតក្រោម១ខែ ឬទារកទើបកើតដែលមានទម្ងន់ស្រាល មិនសាកសមក្នុងការវាស់កម្តៅតាមទ្វារធំ និងតាមត្រចៀកឡើយ អាចពិចារណាវាស់កម្តៅក្លៀក ឬកម្តៅខ្នង។

## ស្គាល់ពីផលប៉ះពាល់នៃគ្រុនក្តៅជាថ្មី

- គ្រុនក្តៅក្នុងសីតុណ្ហភាពល្មម អាចជួយលើកកម្ពស់ប្រសិទ្ធិភាពនៃប្រព័ន្ធស៊ាំ។ មានការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា ថ្នាំបញ្ចុះកម្តៅអាចបង្ក្រាបប្រតិកម្មនៃប្រព័ន្ធស៊ាំរបស់រាងកាយ ដែលអាចនឹងបណ្តាលឲ្យពន្យាពេលការជាសះស្បើយពីជម្ងឺ។
- សារពាង្គកាយមនុស្សមានប្រព័ន្ធគ្រប់គ្រងចំពោះគ្រុនក្តៅដែលបង្កមកពីប្រតិកម្មរលាក ហេតុនេះជាទូទៅកម្តៅមិនលើសពី 41ºC ឡើយ។
- មានអាណាព្យាបាលខ្លះព្រួយបារម្ភថា ប្រសិនបើមិនបញ្ចុះកម្តៅទេ នោះកម្តៅខ្លួនរបស់កូននឹងកើនឡើងបន្តទៀតតាមពិតទៅ ប្រព័ន្ធគ្រប់គ្រងកម្តៅខ្លួន មិនអាចឲ្យកម្តៅខ្លួនកើនឡើងឥតដែនកំណត់នោះទេ។ ពាក្យចចាមអារាមដែលថាកូនអ្នកជិតខាងគ្រុនក្តៅដល់ខូចខួរក្បាលនោះ តាមពិតទៅដោយសារតែកុមារនោះមានជម្ងឺរលាកខួរក្បាល ឬជម្ងឺរលាកស្រោមខួរ ដែលវាអាចបន្សល់ទុកនូវជម្ងឺប្រព័ន្ធប្រសាទនៅថ្ងៃក្រោយ ដែលវាគ្មានទំនាក់ទំនងផ្ទាល់ទៅនឹងគ្រុនក្តៅឡើយ។

## សញ្ញាណគ្រោះថ្នាក់ដែលត្រូវប្រុងប្រយ័ត្នចំពោះ

គ្រុនក្តៅឬអត់ ឬកម្តៅខ្លួនទាបឬខ្ពស់ មិនអាចតំណាងឲ្យកម្រិតធ្ងន់ធ្ងរនៃជម្ងឺបាននៅឡើយ។ ពេលកុមារឈឺ អ្វីដែលសំខាន់នោះគឺត្រូវសង្កេតមើលថាតើមានសញ្ញាណគ្រោះថ្នាក់នៃជម្ងឺធ្ងន់ធ្ងរដែរឬទេ ប្រសិនបើមានស្ថានភាពដូចខាងក្រោម ត្រូវប្រញាប់ទៅព្យាបាលជាបន្ទាន់។

# 發燒的正確處置

- 頸部僵硬
- 未發燒時呼吸急促、呼吸困難、吸氣時胸壁凹陷
- 心跳速度太慢、心跳不規則
- 意識不清、持續昏睡、未發燒時燥動不安、眼神呆滯
- 持續頭痛與嘔吐
- 皮膚出現紫斑

## 退燒的時機

- 如果體溫並未太高也未引起特殊不舒服，尤其體溫並未超過39°C的時候，不需要積極退燒。
- 要注意的是，發燒對下列病人會產生較大的不良影響，所以當體溫超過38°C，就可考慮積極退燒：
  - 慢性肺病
  - 併發心臟衰竭之心臟病或發紺性心臟病
  - 曾有熱性痙攣或癲癇發作
  - 嚴重的神經肌肉疾病
  - 慢性貧血
  - 糖尿病與其他代謝異常（例如先天酵素缺乏）
  - 孕婦
  - 其他因為發燒而有特殊不適症狀

## 認識正確的退燒方法

- 各種退燒藥物中，除了阿斯匹靈不可用於18歲以下兒童，其他口服與塞劑之退燒藥均可於必要時適量使用。
- 單純注射點滴並沒有退燒效果。
- 冰枕、溫水拭浴等物理退燒法，並不會改變發炎反應引起體溫定位點的異常上升現象，所以不會有退燒效果，反而可能造成發燒兒童額外的代謝負擔。
- 衣服穿太多、中暑等產熱與散熱失調的情形也會造成發燒現象，但此時身體的體溫定位點其實是正常的，在這種情況下使用物理退燒法才會有些幫助。

## 發燒的後續照顧

- 部分家長認為吃退燒藥以後如果又燒起來，就表示醫生開的藥沒有效，所以會去找其他醫師。事實上，各種退燒藥的效果都只能維持幾個小時，目的在暫時緩解病人的不適。如果疾病的過程還沒有結束，退燒以後又燒起來是很常見的現象。
- 常見的呼吸道或腸胃道病毒感染，有些可能持續發燒達7天或甚至更久。家長必須注意孩子有無出現上述所列的危險病徵，並持續遵從醫囑追蹤治療。

# ដំណោះស្រាយត្រឹមត្រូវពេលគ្រុនក្តៅ

- អាការៈគ្រុនក្តៅរបស់ទារកអាយុក្រោម៣ខែ
- បរិមាណទឹកនោមតិចជាងមុន
- ពេលយំគ្មានទឹកភ្នែក
- កឡើងរឹង
- មិនគ្រុនក្តៅតែដកដង្ហើមញាប់ ពិបាកដកដង្ហើម និងពេលដកដង្ហើមចូលដើមទ្រូងផតចុះ
- ចង្វាក់បេះដូងលោតយឺត និងចង្វាក់បេះដូងលោតមិនទៀតទាត់
- ប្រគៀវកាច់ កន្ត្រាក់សាច់ដុំ (សាច់ដុំកន្ត្រាក់ញាប់ដោយខ្លួនឯង ដូចឆក់ខ្សែភ្លើង) ស្ពឹកខ្លួន និងមានអារម្មណ៍មិនប្រក្រតី
- ស្លេសមានឈាម
- បង្អក់ដង្ហើម
- ស្មារតីមិនស្វាង ងងុយដេក មិនគ្រុនក្តៅតែអន្ទះសារនៅមិនសុខ និងក្រសែភ្នែកភ្លឹក
- ឈឺក្បាលនិងក្អួតមិនឈប់
- ស្បែកឡើងកន្ទួល

## ពេលត្រូវបញ្ចុះកម្តៅ

- ប្រសិនបើកម្តៅខ្លួនមិនខ្ពស់ខ្លាំង ហើយក៏មិនបណ្តាលឲ្យមិនស្រួលខ្លួន ជាពិសេសកម្តៅខ្លួនមិនលើពី 39°C នោះមិនចាំបាច់ប្រញាប់បញ្ចុះកម្តៅទេ។
- អ្វីដែលត្រូវប្រុងប្រយ័ត្ននោះគឺ គ្រុនក្តៅអាចបង្កឲ្យមានផលប៉ះពាល់ខ្លាំងជាងចំពោះអ្នកជម្ងឺខាងក្រោមហេតុនេះពេលកម្តៅខ្លួនលើសពី38℃ ត្រូវបញ្ចុះកម្តៅឲ្យបានឆាប់៖
    - ជម្ងឺស្ទួតពុំរ៉ៃ
    - ជម្ងឺបេះដូង ឬជម្ងឺបេះដូងស្យាណូស៊ីស
    - ធ្លាប់រមួលក្រពើ ឬប្រគៀវកាច់
    - ជម្ងឺសាច់ដុំនិងសសៃប្រសាទធ្ងន់ធ្ងរ
    - ជម្ងឺខ្វះឈាមក្រហមរ៉ាំរ៉ៃ
    - ជម្ងឺទឹកនោមផ្អែម និង ការបំលែងថាមពលខុសប្រក្រតី (កង្វះអង់ស៊ីមពីកំណើត)
    - ស្រ្តីមានគភ៌
    - អាការៈដទៃទៀតដែលបណ្តាលមកពីគ្រុនក្តៅ

## ស្គាល់ពីវិធីបញ្ចុះកម្តៅត្រឹមត្រូវ

- នៅក្នុងថ្នាំបញ្ចុះកម្តៅគ្រប់ប្រភេទ ក្រៅពីអាស់ស្ពីរីនដែលមិនអាចប្រើចំពោះកុមារអាយុក្រោម១៨ឆ្នាំ ថ្នាំបញ្ចុះកម្តៅប្រភេទលេបនិងសុលដទៃទៀតសុទ្ធតែអាចប្រើបានពេលចាំបាច់ក្នុងបរិមាណសមរម្យ។
- ការព្យួរសេរ៉ូមធម្មតាមិនមានប្រសិទ្ធិភាពបញ្ចុះកម្តៅឡើយ។
- វិធីបញ្ចុះកម្តៅបែបរូបវិទ្យាដូចជា ខ្មើយទឹក ឬជូតខ្លួនដោយទឹកក្តៅឧ្មនៗ មិនអាចកែប្រែចំណុចកម្តៅខ្លួនឡើងខ្ពស់ខុសប្រក្រតីដែលបណ្តាលមកពីការរលាកឡើយហេតុនេះវាគ្មានប្រសិទ្ធិភាពបញ្ចុះកម្តៅទេ ម្យ៉ាងទៀតអាចនឹងបណ្តាលឲ្យប៉ះពាល់បន្ថែមទៀតដល់ការបំលែងថាមពលរបស់កុមារគ្រុនក្តៅ។
- ស្ថានភាពដែលបង្កឲ្យមានកម្តៅ ឬបង្កឲ្យបាត់បង់កម្តៅ ដូចជា ស្លៀកពាក់ខោអាវច្រើនពេក ឬខ្យល់គជាដើម ក៏អាចបណ្តាលឲ្យកើតគ្រុនក្តៅបានដែរប៉ុន្តែពេលនេះចំណុចកម្តៅខ្លួនស្ថិតក្នុងកម្រិតធម្មតា។ ក្នុងស្ថានភាពបែបនេះ ប្រើវិធីបញ្ចុះកម្តៅបែបរូបវិទ្យាទើបអាចជួយបានខ្លះៗ។

## ការមើលថែទាំក្រោយពេលគ្រុនក្តៅ

- អាណាព្យាបាលមួយចំនួនយល់ថា ក្រោយពេលញុាំថ្នាំបញ្ចុះកម្តៅរួចហើយ ប្រសិនបើគ្រុនក្តៅម្តងទៀត នោះមានន័យថាថ្នាំដែលគ្រូពេទ្យឲ្យគ្មានប្រសិទ្ធិភាព ហេតុដូចនេះក៏ទៅរកគ្រូពេទ្យដទៃ។ តាមការពិត ប្រសិទ្ធិភាពរបស់ថ្នាំបញ្ចុះកម្តៅគ្រប់ប្រភេទអាចរក្សាបានតែប៉ុន្មានម៉ោងតែប៉ុណ្ណោះ ក្នុងគោលបំណងកាត់បន្ថយអាការៈមិនស្រួលខ្លួនរបស់អ្នកជម្ងឺជាបណ្តោះអាសន្ន។ ប្រសិនបើដំណាក់កាលជម្ងឺមិនទាន់បញ្ចប់ ក្រោយពេលថយកម្តៅហើយគ្រុនក្តៅសារជាថ្មីម្តងទៀតគឺជារឿងធម្មតា។
- ជម្ងឺឆ្លងមេរោគពោះវៀន និងជម្ងឺឆ្លងមេរោគផ្លូវដង្ហើម មានករណីខ្លះអាចបណ្តាលឲ្យគ្រុនក្តៅរហូតដល់៧ថ្ងៃ ឬយូរជាងនេះ។ អាណាព្យាបាលត្រូវបុង្រប្រយ័ត្នថាតើកូនមានសញ្ញាណគ្រោះថ្នាក់ខាងលើឬទេ ព្រមទាំងប្រតិបត្តិទៅតាមដំបូន្មានរបស់វេជ្ជបណ្ឌិតឲ្យបានខ្ជាប់ខ្ជួន។

# 口腔保健知多少

## 口腔保健知多少～小測驗提醒您！

( ) 1. 超過1歲半後仍有吸奶嘴、吸手指的習慣容易造成寶寶咬合不正。
( ) 2. 寶寶10~12個月還未長牙時，應該去看診向牙醫師詢問。
( ) 3. 寶寶萌發第一顆乳牙後應該去做第1次口腔定期檢查。
( ) 4. 父母親餵食幼兒時，先幫忙吹涼熱食或預先咀嚼食物，並不容易造成幼兒的蛀牙。
( ) 5. 如果寶寶已長出牙齒，但經常吃完食物後又沒馬上潔牙，就容易形成蛀牙。
( ) 6. 牙齒還沒萌發前，寶寶喝奶、用餐後及睡前，可以用溼的紗布包住手指，替寶寶進行牙齦、舌頭、口腔黏膜的清潔。
( ) 7. 當發現2顆乳牙相鄰時，即可開始使用牙線幫幼兒潔牙。
( ) 8. 幼兒使用含氟牙膏的含氟量一般為1,000 ppm左右。
( ) 9. 使用含氟牙膏幫幼兒潔牙，必須要注意牙膏量的多少。對3歲以下兒童，可將薄薄一層的牙膏塗在牙刷上，由照顧者幫忙刷牙；對3-6歲兒童，使用豌豆般大小的牙膏量，由照顧者幫忙或監督刷牙。
( ) 10. 一般而言，建議幼兒每6個月請牙醫師幫忙塗氟1次。



☆ 答案在這裡 ☆

| 1. | 2. | 3. | 4. | 5. | 6. | 7. | 8. | 9. | 10. |
|---|---|---|---|---|---|---|---|---|---|
| O | O | O | X | O | O | O | O | O | O |

☆ 您答對幾題呢？☆
答對8題以上：恭喜您-您的觀念很正確！
答對6-7題：還不錯喔！不過有些觀念並不清楚呢？
答對4-5題：還要再加油喔-請仔細檢討答錯題目的正確觀念吧！
答對3題以下：請趕快把每題的詳細解說看清楚喔！

# តើអ្នកដឹងអ្វីខ្លះអំពីសុខភាពមាត់ធ្មេញ

## តើអ្នកដឹងអ្វីខ្លះអំពីសុខភាពមាត់ធ្មេញ? សំណួរខ្លីៗរំលឹកដល់អ្នក!

( ) 1. ក្រោយអាយុ១ឆ្នាំកន្លះនៅតែមានទម្លាប់បៀមក្បាលកំប៉ុងទឹកដោះគោ និងបៀម្រមាមៃដ ងាយនឹងបណ្តាលឲ្យកុមារមានធ្មេញមិនស្មើ។

( ) 2. ទារកអាយុ១០ ទៅ១២ខែ នៅមិនទាន់ដុះធ្មេញ គប្បីទៅពិគ្រោះជាមួយទន្តពេទ្យ។

( ) 3. ទារកដុះធ្មេញទឹកដោះគ្រាប់ទី១ គប្បីទៅធ្វើការពិនិត្យមាត់ធ្មេញលើកទី១។

( ) 4. ពេលម្តាយឪពុកបញ្ចុកអាហារដល់កូន ត្រូវផ្លុំអាហារក្តៅឲ្យត្រជាក់ឬទំពារជាមុននឹងជួយកុំឲ្យងាយមានដង្កូវស៊ីធ្មេញ។

( ) 5. ប្រសិនបើទារកដុះធ្មេញហើយ ប៉ុន្តែពេលញ៉ាំអាហាររួចតែងតែមិនសម្អាតធ្មេញ នឹងងាយធ្វើឲ្យមានដង្កូវស៊ីធ្មេញ។

( ) 6. មុនពេលមានធ្មេញ ពេលទារកបៅទឹកដោះនិងញ៉ាំអាហាររួច និង មុនពេលចូលដេក អាចយកស្បៃសើមមករុំម្រាមដៃ ជួយសម្អាតអញ្ចាញធ្មេញ អណ្តាត និងភ្នាសរំអិលមាត់។

( ) 7. ពេលប្រទះឃើញធ្មេញទឹកដោះ២គ្រាប់ដុះជិតគ្នា នោះអាចចាប់ផ្តើមប្រើខ្សែសេធ្មេញជួយសម្អាតធ្មេញឲ្យទារក។

( ) 8. ជាតិភ្លុយអរីនក្នុងថ្នាំដុសធ្មេញភ្លុយអរីនដែលទារកប្រើជាទូទៅប្រហែល ១.០០០ppm។

( ) 9. ប្រើថ្នាំដុសធ្មេញមានជាតិភ្លុយអរីនជួយសម្អាតធ្មេញទារក ត្រូវប្រុងប្រយ័ត្នពីបរិមាណថ្នាំដុសធ្មេញ។ ចំពោះកុមារអាយុក្រោម៣ឆ្នាំអាចប្រើថ្នាំដុសធ្មេញបន្តិច និងជួយដុសដោយអ្នកមើលថែទាំ។ ចំពោះកុមារអាយុ៣ ទៅ ៦ឆ្នាំ អាចប្រើថ្នាំដុសធ្មព្រាបមាណប៉ុនសណ្តែកក្រហម ជួយដុសដោយឬមើលខុសត្រូវដោយអ្នកមើលថែទាំ។

( ) 10. ជាទូទៅ កុមារគួរឲ្យទន្តពេទ្យលាបភ្លុយអរីន៦ខែម្តង។



☆ ចម្លើយនៅទីនេះ ☆

| 1. | 2. | 3. | 4. | 5. | 6. | 7. | 8. | 9. | 10. |
|---|---|---|---|---|---|---|---|---|---|
| O | O | O | X | O | O | O | O | O | O |

☆ តើអ្នកឆ្លើយត្រូវប៉ុន្មានសំណួរ? ☆

ឆ្លើយត្រូវលើសពី៨សំណួរ៖ សូមជួយអបអរ ទស្សនៈរបស់អ្នកត្រឹមត្រូវ!
ឆ្លើយត្រូវ ៦ ទៅ ៧សំណួរ៖ ល្អ! ប៉ុន្តែមានទស្សនៈខ្លះមិនច្បាស់លាស់!
ឆ្លើយត្រូវ ៤ ទៅ ៥សំណួរ៖ សូមខិតខំប្រឹងប្រែងបន្ថែមទៀត សូមពិនិត្យមើលទស្សនៈត្រឹមត្រូវរបស់សំណួរដែលអ្នកឆ្លើយខុស!
ឆ្លើយត្រូវ៣សំណួរចុះក្រោម: សូមមើលការពន្យល់លំអិតនៃសំណួរនីមួយៗឲ្យបានច្បាស់!

# 口腔保健知多少

## 兒童口腔衛生清潔

- 兒童在起床後、三餐飯後或吃完東西後（如：喝完母乳或牛奶、飲料及果汁、麥片及果泥、其它副食品等），以及晚上睡覺前都應該要清潔口腔。
- 在寶寶零到6個月大時，進食後應該用紗布擦拭口腔(包括牙床、黏膜及舌頭)。6個月到1歲半時（乳臼齒萌發前），可用矽膠指套刷清潔前牙。待乳臼齒長出後，就應該用牙刷潔牙了。
- 幫孩子刷牙時，一定要讓寶寶的頭部有所倚靠，並選在安全明亮的地方，例如坐在沙發、地毯或床上等地方並讓寶寶枕在家長的大腿上。且因寶寶的牙齦脆弱，所以刷牙的力量要輕柔。
- 固定刷牙的方法、時間、順序，讓孩子習慣固定的潔牙方式。此外，可搭配遊戲、音樂等來增加潔牙樂趣。

## 牙刷的使用方法

- 牙刷應選擇軟毛小頭的牙刷，且每3個月至半年更換1次。
- 刷牙時，牙刷刷毛朝向牙齦約45度，且要同時涵蓋牙齒與一些牙齦。刷上排牙齒時刷毛朝上，刷下排牙齒時刷毛朝下。每次以2顆牙齒為單位來回輕刷至少10次，並清潔到牙齒的每一面。
- 兒童刷牙順序：先刷右邊的頰側面→咬合面→舌側面，接著刷上下門牙的唇側面→舌側面，最後刷左邊的頰側面→咬合面→舌側面。

## 牙線的使用方法

- 牙線主要是輔助牙刷的功能，可以去除牙縫中的食物殘渣與牙菌斑。因此，當孩子長出較多顆乳牙時，最好能夠每天至少使用1次牙線清潔齒列。
- 牙線使用時，先拉出約45公分的牙線（長如手臂），纏繞在雙手中指第2指節，比出手槍姿勢，以雙手姆指及食指打直撐住牙線，約留下1公分牙線，並將牙線拉成C字型，使牙線緊貼牙面上下刮。

# តើអ្នកដឹងអ្វីខ្លះអំពីសុខភាពមាត់ធ្មេញ

## អនាម័យមាត់ធ្មេញកុមារ

- ក្រោយពេលទារកក្រោកពីដំណេក ក្រោយពេលបាយ ឬក្រោយពេលញុំាអាហាររួច (ដូចជា៖ បៅទឹកដោះម្តាយឬទឹកដោះគោ ភេសជ្ជៈនិងទឹកផ្លែឈើ បបរស្រូវសាលីនិងបបរផ្លែឈើ និងអាហាររឹងដទៃទៀត) និងមុនពេលចូលដំណេកពេលយប់ ត្រូវសម្អាតមាត់ជានិច្ច។
- ទារកអាយុពី០ ទៅ ៦ខែ ត្រូវយកស្បៃជូតក្នុងមាត់ (អញ្ចាញធ្មេញ អណ្តាត និងភ្នាសទឹករំអិល) ក្រោយពេលញុំាអាហាររួច។ អាយុពី៦ខែ ទៅ ១ឆ្នាំ (មុនពេលថ្គាមទឹកដោះដុះ) អាចដុសសម្អាតធ្មេញដោយច្រាសដុះធ្មេញម្រាមដៃស៊ីលីខន។ ក្រោយពេលធ្មេញថ្គាមទឹកដោះដុះចេញមក អាចដុសបានដោយច្រាសដុសធ្មេញ។
- ពេលជួយកូនដុសធ្មេញ ត្រូវឲ្យក្បាលកូនមានកន្លែងផ្អែក និងត្រូវដុសនៅកន្លែងដែលមានសុវត្ថិភាពនិងមានពន្លឺគ្រប់គ្រាន់ឧទាហរណ៍ អង្គុយនៅលើសាឡុង លើកម្រាល ឬលើគ្រែ និង ត្រូវឲ្យក្បាលរបស់កូនផ្អែកនឹងភ្លៅរបស់មនុស្សធំ។ ម្យ៉ាងទៀតដោយសារតែអញ្ចាញធ្មេញរបសទារកទន់ខ្សោយ ហេតុនេះដុសធ្មេញត្រូវប្រើកម្លាំងថ្នមៗ។
- វិធី ពេលវេលា និងលំដាប់លំដោយដុសធ្មេញទៀតទាត់ ជួយឲ្យទារកទម្លាប់ទៅនឹងវិធីសម្អាតធ្មេញបែបនេះ។ ក្រៅពីនេះអាចធ្វើឡើងដោយលាយលំជាមួយល្បែងកម្សាន្ត និងតន្ត្រី ដើម្បីបង្កើនភាពរីករាយក្នុងពេលដុសធ្មេញ។

## វិធីប្រើប្រាស់ច្រាសដុសធ្មេញ

- ច្រាសដុសធ្មេញគប្បីជ្រើសរើស សសៃច្រាសទន់និងល្អិត និង ត្រូវផ្លាស់ប្តូរច្រាសដុសធ្មេញ៣ខែ ទៅ ៦ខែម្តង។
- ពេលដុសធ្មេញ សសៃច្រាសត្រូវទ្រេតទៅអញ្ចាញធ្មេញក្នុងរង្វាស់៤៥ដឺក្រេ និង ត្រូវស្រោបលើគ្រាប់ធ្មេញនឹងផ្នែកខ្លះនៃអញ្ចាញ។ ពេលដុសធ្មេញក្រាស់ខាងលើ សសៃច្រាសត្រូវឡើងលើ ពេលដុសធ្មេញក្រាស់ខាងក្រោម សសៃច្រាសត្រូវចុះក្រោម។ ដុះធ្មេញម្តង២គ្រាប់ទៅវិញទៅមកចំនួន១០ដងដោយថ្នមៗ និងសម្អាតគ្រប់បរិវេណរបស់ធ្មេញ។
- លំដាប់លំដោយនៃការដុសធ្មេញរបស់កុមារ៖ដុសផ្ទៃធ្មេញចំហៀងថ្ពាល់ខាងស្តាំមុន -> ផ្ទៃទំពារ -> ផ្ទៃខាងអណ្តាត បន្ទាប់មកដុសផ្ទៃធ្មេញមុខលើក្រោមខាងបបូរមាត់ -> ផ្ទៃទំពារ -> ផ្ទៃខាងអណ្តាត និងចុងក្រោយដុសផ្ទៃធ្មេញចំហៀងថ្ពាល់ខាងឆ្វេង -> ផ្ទៃទំពារ -> ផ្ទៃខាងអណ្តាត

## វិធីប្រើប្រាស់ខ្សែរូសធ្មេញ

- ខ្សែរូសធ្មេញ មានមុខងារជំនួយដល់ច្រាសដុសធ្មេញ អាចជម្រុះកម្ទេចអាហារនិងកំណកបាក់តេរីធ្មេញដែលនៅស្អិតចន្លោះធ្មេញ។ ដូចនេះ ពេលកុមារដុះធ្មេញទឹកដោះច្រើនជាងមុន យ៉ាងហោចណាស់ត្រូវប្រើខ្សែរូសធ្មេញធ្វើការសម្អាតមួយថ្ងៃម្តង
- ពេលប្រើប្រាស់ខ្សែរូសធ្មេញ ដំបូងទាញខ្សែឲ្យបាន៤៥សង់ទីម៉ែត្រ (ប្រវែងដើមដៃ)រុំជុំវិញថ្នាំងទី២ម្រាមដៃកណ្តាលទាំងសងខាង ផ្ញើដៃរាងកាំភ្លើងមេដៃនិងចង្អុលដៃលាត្រង់ទ្រខ្សែ បន្សល់ខ្សែទុកប្រវែង១សង់ទីម៉ែត្រ និងទាញខ្សែរូសធ្មេញឲ្យចេញជារាងអក្សរC ផ្អិបទៅនឹងផ្ទៃធ្មេញ រូសចុះរូសឡើង។

# 視力保健基本功

幼兒常見的視力問題有弱視、斜視及屈光不正(即近視、遠視、散光)等，六歲前是斜、弱視治療的關鍵期，錯過了治療效果變差；愈早近視，度數增加愈快，變成高度近視(大於600度)機會愈大，而高度近視易產生青光眼、網膜周邊變性、視網膜剝離、黃斑出血及黃斑退化、後極部退化、提早發生白內障，可能導致失明。研究顯示：戶外活動是近視發病和惡化的保護因素，長時間近距離用眼是近視的危險因素。

## 護眼運動從小開始

隨時觀察幼兒，下列疑似視力不良的症狀，請儘早至眼科就診。

□是，□否 1. 瞇著眼睛看東西。

□是，□否 2. 常常揉眼睛。

□是，□否 3. 慣於歪頭、仰頭或低頭去看東西。

□是，□否 4. 反覆側視看物體，表現出想要看得更清楚的模樣。

□是，□否 5. 參加遊戲時，行動不靈活、不敏捷。

□是，□否 6. 看書或寫字時，眼睛與紙面的距離太近。

□是，□否 7. 學習進度減慢或退步。

□是，□否 8. 常抱怨看不清楚黑板上的字、眼睛疲勞、眼痛、頭痛。

□是，□否 9. 眼位外觀異常(如鬥雞眼)。

□是，□否 10. 眼球震顫(眼球不自主的規律性轉動)，或黑眼珠內出現反光等現象。

## 幼兒接受視力檢查前的預備工作

- 3-4歲：某些視力問題(如單眼弱視)並無明顯症狀。一般而言，3歲半至4歲是視力檢查的理想時機，家長應先在家中教會孩子辨認、並以手勢比劃或言語說出「E」或「C」字視標之缺口方向，再帶至眼科接受視力檢查。
- 3-6歲：「亂點立體圖」可有效檢查出立體感不良的患童，也可以避免測試單眼視力時用正常眼偷看的弊病。除了教會孩童比出視力表之缺口方向外，也要請家長先教導孩童認識說(指)出亂點立體圖上之●、■、▲、◆四種圖形。

# មូលដ្ឋានគ្រឹះនៃសុខភាពភ្នែក

បញ្ហាភ្នែកដែលតែងកើតមានចំពោះកុមារមាន ភ្នែកខ្សោយ ភ្នែកកែក ជម្ងឺអាម្រេត្រូហ្វី(មីញ៉ូបជិត មីញ៉ូបឆ្ងាយ និងអាស្ទីម៉ាធីម)។ មុនអាយុ៦ឆ្នាំ គឺជាដំណាក់កាលសំខាន់ក្នុងការព្យាបាលជម្ងឺភ្នែកខ្សោយនិងភ្នែកកែក ប្រសិនបើផុតដំណាក់កាលនេះ នោះប្រសិទ្ធិភាពនៃការព្យាបាលនឹងធ្លាក់ចុះ។ ភ្នែកមីញ៉ូបកាន់តែឆាប់ ចំនួនដឺក្រេនឹងកើនឡើងកាន់តែរហ័ស នោះឱកាសក្លាយជាមីញ៉ូបធ្ងន់ធ្ងរ(ខ្ពស់ជាង ៦០០ដឺក្រេ) នឹងកាន់តែខ្ពស់។ ឯភ្នែកមីញ៉ូបធ្ងន់ធ្ងរងាយនឹងបណ្ដាលឲ្យកើតមានជម្ងឺគ្លោកូម ប៉េរបំរួលបរិវេណស្រទាប់រ៉េទីន របក្រុសទាប៉េរ៉េទីន ម៉ាយ្យូឡាចេញឈាមនិងម៉ាយ្យូឡាចុះខ្សោយ និងប៉ូលក្រោយចុះខ្សោយ កើតមានជម្ងឺភ្នែកឡើងបាយឆាប់ និងអាចបណ្ដាលឲ្យខ្វាក់ភ្នែក។ ការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា៖ ការធ្វើសកម្មភាពខាងក្រៅផ្ទះ គឺជាកត្តាការពារការកើតឡើងនិងការវត្តន៍កាន់តែអាក្រក់នៃជម្ងឺមីញ៉ូប។ ការប្រើភ្នែកសម្លឹងមើលទីជិតរយៈពេលវែង គឺជាកត្តាគ្រោះថ្នាក់ដែលបង្កឲ្យកើតជម្ងឺមីញ៉ូប។

## លំហាត់ប្រាណការពារភ្នែកចាប់ផ្ដើមធ្វើពីតូច

សង្កេតទារកគប់ពេលវេលា អាការៈខាងក្រោមនេះបញ្ជាក់ថាភ្នែកចុះខ្សោយ សូមទៅពិនិត្យចក្ខុពេទ្យឲ្យបានឆាប់។

☐ មែន ☐ ទេ 1. មើលវត្ថុដោយព្រិមែភ្នែក

☐ មែន ☐ ទេ 2. ឧស្សាហ៍ញើភ្នែក

☐ មែន ☐ ទេ 3. ទម្លាប់មើលវត្ថុដោយវៀចក្បាល ងើយក្បាល ឬឱនក្បាល

☐ មែន ☐ ទេ 4. មើលវត្ថុដោយចំហៀងភ្នែកម្ដងហើយម្ដងទៀត បញ្ចេញទឹកមុខដែលបញ្ជាក់ថាចង់មើលឲ្យកាន់តែច្បាស់។

☐ មែន ☐ ទេ 5. ពេលលេងល្បែងកម្សាន្ដ ចលនាមិនរស់រវើក មិនរវៀសវៃ។

☐ មែន ☐ ទេ 6. ពេលមើលសៀវភៅ ឬសរសេរអក្សរ ចម្ងាយរវាងភ្នែកនិងក្រដាសជិតពេក។

☐ មែន ☐ ទេ 7. ការសិក្សាមានការរីកចម្រើនយឺត ឬថយចុះ។

☐ មែន ☐ ទេ 8. តែងតែរអ៊ូថាមើលអក្សរនៅលើក្ដារខៀនមិនឃើញ នឿយភ្នែក ឈឺភ្នែក និងឈឺក្បាល។

☐ មែន ☐ ទេ 9. ទីតាំងភ្នែកខុសប្រក្រតី (ឧទាហរណ៍ ភ្នែកស្រលៀង)។

☐ មែន ☐ ទេ 10. ញ័រត្របកភ្នែក (ត្របកភ្នែករិលកម្រើកយ៉ាងទៀងទាត់ដោយខ្លួនឯង) ឬក្នុងប្រស្រីភ្នែកផ្លាតពន្លឺ។

## ការត្រៀមលក្ខណៈមុនពេលកុមារទទួលការពិនិត្យភ្នែក

- អាយុពី៣ ទៅ ៤ឆ្នាំ៖ មានបញ្ហាភ្នែកខ្លះ (ភ្នែកម្ខាងខ្សោយ) គ្មានអាការៈជាក់លាក់ឡើយ។ ជាទូទៅ អាយុ៣ឆ្នាំកន្លះ ទៅ ៤ឆ្នាំ គឺជាពេលពិនិត្យភ្នែកដ៏ប្រពៃបំផុត។ អាណាព្យាបាលគប្បីបង្រៀនឲ្យកូនចេះមើលទិសនៃផ្នែកផតអក្សរ "E" ឬ "C" ជាមុន ទើបនាំកូនទៅពិនិត្យនៅចក្ខុពេទ្យ។
- អាយុពី៣ ទៅ ៦ឆ្នាំ៖ «ស្វ៊េរីអូក្រាមចំណុចពង្រាយ» មានប្រសិទ្ធិភាពក្នុងការពិនិត្យកុមារដែលញាណបីវិមាត្រមិនល្អហើយក៏អាចជៀសវាងការលួចប្រើភ្នែកធម្មតាមើលពេលពិនិត្យភ្នែកម្ខាង។ ក្រៅពីបង្រៀនឲ្យកុមារចេះមើលទិសនៃផ្នែកផតរបស់អក្សរ អាណាព្យាបាលក៏ត្រូវបង្រៀនឲ្យកូនស្គាល់រូបរាងទាំងបួននេះ ●■▲◆ ក្នុងស្វ៊េរីអូក្រាមចំណុចពង្រាយ។

# 視力保健基本功

## 預防高度近視是全家運動

- 什麼是高度近視
  - 大部分高度近視定義都是以大於600度為主，往往肇始於學齡前，並持續惡化至高中畢業，缺乏戶外活動並大量近距離使用眼力常導致近視發生及惡化。
  - 幼兒一旦發生近視，度數會逐年增加，日後變成高度近視的機會很大，且產生併發症的機會也相對提高。
  - 目前高度近視已經成為臺灣、日本及中國大陸不可逆的失明原因第一位。
- 可怕的近視併發症

近視相關的併發症有：白內障、青光眼、網膜周邊變性、視網膜剝離、黃斑出血及黃斑退化、後極部退化，這些情況都不易治療，甚至導致失明。

- 幼兒的基本視力保健

建議孩子未滿2歲不要觀看螢幕，而大於2歲之幼兒每天看螢幕時，時間不超過1小時，避免讓幼兒過度近距離用眼，傷害視力。近年實證研究亦發現，戶外活動是近視發生和惡化的保護因素，每天戶外活動超過2-3小時，可能減緩兒童近視的發生和惡化。世界衛生組織（WHO）亦建議5歲至17歲兒童與青少年，每天累計至少60分鐘(1小時)中等費力至費力身體活動。



# មូលដ្ឋានគ្រឹះនៃសុខភាពភ្នែក

## ការបង្ការជម្ងឺមីញ៉ូបធ្ងន់ធ្ងរ  គឺជាចលនាពេញមួយគ្រួសារ

- តើជម្ងឺមីញ៉ូបធ្ងន់ធ្ងរគឺជាអ្វី
  - និយមន័យនៃជម្ងឺមីញ៉ូបភាគច្រើនគឺ ដឺក្រេភ្នែកខ្ពស់ជាង៦០០ ដែលតែងតែចាប់ផ្តើមនៅមុនអាយុសិក្សា និងបន្តវិវត្តន៍កាន់តែអាក្រក់រហូតដល់ថ្នាក់វិទ្យាល័យ។ កង្វះសកម្មភាពខាងក្រៅផ្ទះ និងប្រើភ្នែកមើលវត្ថុក្នុងចម្ងាយជិតច្រើនពេក តែងតែបណ្តាលឲ្យជម្ងឺមីញ៉ូបកើតមាននិងវិវត្តន៍កាន់តែអាក្រក់។
  - ពេលកុមារកើតជម្ងឺមីញ៉ូប ចំនួនដឺក្រេភ្នែកនឹងកើនឡើងជារៀងរាល់ឆ្នាំ ដែលមានឱកាសប្រែក្លាយជាមីញ៉ូបធ្ងន់ធ្ងរធំ ម្យ៉ាងទៀតឱកាសកើតមានជម្ងឺវិបាកក៏កាន់តែខ្ពស់ដែរ។
  - បច្ចុប្បន្ន ជម្ងឺមីញ៉ូបធ្ងន់ធ្ងរគឺជាមូលហេតុធំទី១ដែលបង្កឲ្យខ្វាក់ភ្នែកនៅតៃវ៉ាន់ ជប៉ុន និងចិនដីគោក។

- ជម្ងឺវិបាកនៃជម្ងឺមីញ៉ូបភ្នែក

ជម្ងឺវិបាកដែលទាក់ទងនឹងជម្ងឺមីញ៉ូបភ្នែកមាន៖ ជម្ងឺភ្នែកឡើងបាយ ជម្ងឺគ្លោកូមប៉ះពាល់បរិវេណស្រទាប់រ៉េទីន របេកស្រទាប់រ៉េទីន ម៉ាឃ្យូឡាចេញឈាមនិងម៉ាឃ្យូឡាចុះខ្សោយ និងប៉ូលក្រោយចុះខ្សោយ ជាជម្ងឺពិបាកព្យាបាល ដែលអាចបង្កឲ្យខ្វាក់ភ្នែក។

- មូលដ្ឋានគ្រឹះនៃសុខភាពភ្នែករបស់កុមារ

កុមារអាយុក្រោម២ឆ្នាំយល់ល្អកុំសម្លឹងមើលអេក្រង់ ចំណែកឯកុមារអាយុលើ២ឆ្នាំ ក្នុងមួយថ្ងៃមើលអេក្រង់មិនឲ្យលើសពី១ម៉ោងឡើយ ដើម្បីជៀសវាងកុំឲ្យកុមារប្រើភ្នែកសម្លឹងមើលក្នុងចម្ងាយខ្លីច្រើនហួសហេតុ ដែលបង្កឲ្យខូចភ្នែក។ ក្នុងការស្រាវជ្រាវថ្មីៗនេះក៏បានបង្ហាញឲ្យឃើញថា ការធ្វើសកម្មភាពនៅខាងក្រៅផ្ទះ គឺជាកត្តាការពារការកើតឡើងនិងការវិវត្តន៍កាន់តែអាក្រក់នៃជម្ងឺមីញ៉ូបភ្នែក។ ធ្វើសកម្មភាពនៅខាងក្រៅផ្ទះ២ ទៅ ៣ម៉ោងរៀងរាល់ថ្ងៃ អាចជួយពន្យាការកើតឡើងនិងការវិវត្តន៍កាន់តែអាក្រក់នៃជម្ងឺមីញ៉ូបភ្នែកកុមារ អង្គការសុខភាពពិភពលោក (WHO) ក៏បានណែនាំឲ្យកុមារនិងក្មេងជំទង់អាយុពី៥ឆ្នាំ ទៅ ១៧ឆ្នាំ ធ្វើចលនាខ្លួនប្រាណក្នុងកម្លាំងមធ្យមដល់កម្លាំងពេញលេញរយៈពេល៦០នាទី(១ម៉ោង) ជារៀងរាល់ថ្ងៃ។



# 視力保健基本功

## 小提示

**愛EYE秘笈，護眼行動備忘錄**

| | | |
|---|---|---|
| **第1招：眼睛休息不忘記** | 有做到 | 要改進 |
| 1. 每天戶外活動2-3小時以上，建議每週至少14小時。 | | |
| 2. 看電視或螢幕要遵守3010原則，每30分鐘休息10分鐘，每天總時數少於1小時。 | | |
| 3. 下課時間務必走出教室外活動，或讓眼睛望遠休息至少10分鐘。 | | |
| 4. 早睡早起，睡眠充足。 | | |

| | | |
|---|---|---|
| **第2招：均衡飲食要做到** | 有做到 | 要改進 |
| 5. 多攝取維生素A、B、C群，及深色蔬果。 | | |
| 6. 日常飲食種類多樣化、不偏食。 | | |

| | | |
|---|---|---|
| **第3招：閱讀習慣要養成** | 有做到 | 要改進 |
| 7. 每閱讀、寫字或其他近距離用眼30分鐘應休息10分鐘。 | | |
| 8. 看書或拿筆寫字，保持35-40公分的距離。 | | |
| 9. 不在搖晃的車上閱讀，也不要躺著看書 | | |

| | | |
|---|---|---|
| **第4招：讀書環境要注意** | 有做到 | 要改進 |
| 10.光線要充足，桌面照度至少350米燭光以上。 | | |
| 11.書桌高度要讓手肘自然下垂平放，椅面要讓臀部坐滿，雙腳要踩到地。 | | |

| | | |
|---|---|---|
| **第5招：拿筆、坐姿要正確** | 有做到 | 要改進 |
| 12.書桌光線不直接照射眼睛，習慣用右手寫字的人，檯燈放左前方，左撇子則在右前方。 | | |
| 13.姿勢端正，兩肩放輕鬆，腰打直，不歪頭、不趴著。 | | |
| 14.握筆由前三指來挺筆並帶筆運行，後二指要穩定。 | | |

| | | |
|---|---|---|
| **第6招：定期檢查要知道** | 有做到 | 要改進 |
| 15.每年固定1-2次視力檢查。 | | |
| 16.接到學校視力篩檢未達合格標準的通知，盡速至合格眼科醫師處接受複檢。 | | |
| 17.遵照醫師指示配合矯治，定期回診追蹤。 | | |

# មូលដ្ឋានគ្រឹះនៃសុខភាពភ្នែក

## រំលឹក

### រូបមន្តថែរក្សាEYE  កំណត់ហេតុការពារភ្នែក

| រូបមន្តទី១ ៖ កុំភ្លេចឲ្យភ្នែកសម្រាក | ធ្វើបាន | ត្រូវធ្វើឲ្យកាន់តែប្រសើរ |
|---|---|---|
| 1. រាល់ថ្ងៃធ្វើសកម្មភាពនៅខាងក្រៅឲ្យបានពី ២ ទៅ ៣ម៉ោងណែនាំឲ្យធ្វើយ៉ាងហោចណាស់១សប្តាហ៍១៤ម៉ោង។ | | |
| 2. មើលទូរទស្សន៍ឬអេក្រង់គួរគោរពតាមច្បាប់៣០១០ រាល់៣០នាទីគួរស្រមាក១០នាទី។ ពេលវេលាមើលសរុបប្រចាំថ្ងៃតិចជាង១ម៉ោង។ | | |
| 3. ពេលស្រមាកក្នុងម៉ោងរៀនគួរដើរចេញមកធ្វើសកម្មភាពនៅខាងក្រៅថ្នាក់ ឬមើលទៅឆ្ងាយឲ្យភ្នែកស្រមាក១០នាទី។ | | |
| 4. ឆាប់ដេកឆាប់ក្រោក ដេកឲ្យបានគ្រប់គ្រាន់។ | | |

| រូបមន្តទី២ ៖ បរិភោគអាហារឲ្យមានសមាមាត្រ | ធ្វើបាន | ត្រូវធ្វើឲ្យកាន់តែប្រសើរ |
|---|---|---|
| 5. ស្រូបយកអាហារក្រុមវីតាមីន A B C ឲ្យបានច្រើន និងបន្លែផ្លែឈើពណ៌ចាស់។ | | |
| 6. ម្ហូបអាហារប្រចាំថ្ងៃច្រើនបែបច្រើនយ៉ាង មិនរើសអាហារ។ | | |

| រូបមន្តទី៣ ៖ ត្រូវមានទម្លាប់អានសៀវភៅ | ធ្វើបាន | ត្រូវធ្វើឲ្យកាន់តែប្រសើរ |
|---|---|---|
| 7. រាល់ពេលអាននិងសរសេរ ឬសកម្មភាពដៃទៃដែលត្រូវប្រើភ្នែកក្នុងចម្ងាយជិត ត្រូវស្រមាក ១០នាទីរាល់៣០នាទីម្តង។ | | |
| 8. អានសៀវភៅ ឬកាន់ប៊ិចសរសេរអក្សរ រក្សាចម្ងាយ ៣៥ ទៅ ៤០សង់ទីម៉ែត្រ។ | | |
| 9. មិនអានសៀវភៅនៅលើរថយន្តដែលរង្គើរ និង មិនដេកអានសៀវភៅ | | |

| រូបមន្តទី៤ ៖ ប្រុងប្រយ័ត្នចំពោះបរិស្ថានអានសៀវភៅ | ធ្វើបាន | ត្រូវធ្វើឲ្យកាន់តែប្រសើរ |
|---|---|---|
| 10. ត្រូវមានពន្លឺគ្រប់គ្រាន់ ក្រមិតពន្លឺលើតុយ៉ាងហោចណាស់លើសពី ៣៥០Lux។ | | |
| 11. កម្ពស់តុត្រូវស្មើនឹងកែងដៃដាក់បញ្ឈរ ផ្ទៃកៅអីត្រូវឲ្យគូថអង្គុយពេញ ជើងទាំងពីរដាក់ដល់ដី។ | | |

| រូបមន្តទី៥ ៖ ត្រូវមានឥរិយាបថកាន់ប៊ិច និងអង្គុយត្រឹមត្រូវ | ធ្វើបាន | ត្រូវធ្វើឲ្យកាន់តែប្រសើរ |
|---|---|---|
| 12. ពន្លឺលើតុមិនគួរចាំងចំភ្នែកឡើយ។ អ្នកដែលទម្លាប់ប្រើដៃស្តាំសរសេរអក្សរ នោះអំពូលភ្លើងគួរដាក់នៅខាងឆ្វេង បើអ្នកប្រើដៃឆ្វេងគួរដាក់នៅខាងស្តាំ។ | | |
| 13. ឥរិយាបថត្រឹមត្រូវ បន្ទះស្មា ចង្កេះត្រង់ មិនរៀចក្បាល និងមិនក្រាប។ | | |
| 14. កាន់ប៊ិចដោយ ប្រើម្រាមពីរខាងមុខបញ្ឈរប៊ិចនិងនាំប៊ិចសរសេរ ចំណែកម្រាម២ខាងក្រោយត្រូវនៅនឹង។ | | |

| រូបមន្តទី៦ ៖ ត្រូវធ្វើការពិនិត្យជាទៀងទាត់ | ធ្វើបាន | ត្រូវធ្វើឲ្យកាន់តែប្រសើរ |
|---|---|---|
| 15. ធ្វើការពិនិត្យភ្នែក១ ទៅ ២ដងក្នុងមួយឆ្នាំ | | |
| 16. ពេលទទួលបានសេចក្តីជូនដំណឹងនៃការពិនិត្យភ្នែកនៅសាលាដែលលទ្ធផលមិនដល់កម្រិតស្តង់ដា ត្រូវប្រញាប់រួសរាន់ទៅធ្វើការពិនិត្យម្តងទៀតនៅមន្ទីរចក្ខុសាស្ត្រដែលមានអាជ្ញាប័ណ្ណ។ | | |
| 17. សហការព្យាបាលទៅតាមវេជ្ជបញ្ជារបស់គ្រូពេទ្យនិងត្រលប់មកធ្វើការពិនិត្យតាមដានឲ្យបានទៀតទាត់។ | | |

# 預防事故傷害

以下指標請家長核對，若答案為「否」，請儘速改善，以維護家中幼兒之安全。

## 燙傷的預防

□是，□否　1. 您是否避免在餐桌上放置桌巾，且端熱湯或菜上桌時，先看看幼兒是否在旁邊。

□是，□否　2. 您是否不讓幼兒接近熨斗及熱燈泡。

□是，□否　3. 您準備洗澡水時，是否永遠先放冷水，再放熱水；嬰兒進入浴盆前，先試過水溫。

## 跌落或摔倒的預防

□是，□否　4. 您是否知道2樓以上，必須禁止幼兒攀爬窗戶以策安全。

□是，□否　5. 您是否注意不在地板上放置會滑動的小地毯；地板很滑時，應讓幼兒穿著止滑襪或止滑拖鞋行走，並且避免奔跑。

□是，□否　6. 您是否在浴室或浴盆中設有防滑裝置。

□是，□否　7. 您是否使用桌角防撞套包裹傢俱尖銳角或邊緣，還是將傢俱暫時移開。

## 窒息、嗆到、噎到及中毒的預防

□是，□否　8. 您是否知道會形成密閉空間的家用品，如冰箱、烘衣機或洗衣機等，應選擇不易被幼兒開啟者，或加裝幼兒不易開啟的裝置，以免幼兒誤入造成窒息。

□是，□否　9. 您是否避免讓幼兒拿到小東西（如銅板、鈕扣、小珠子、別針、螺絲釘等）；選購玩具時，必定檢查玩具上的小零件是否可能脫落（如狗熊的眼珠等）。

□是，□否　10. 您是否會將所有的藥物（尤其是糖漿）、洗潔劑、殺蟲劑、洗髮精、沐浴乳、汽機油、化妝品及其他危險的東西都放到高處，或鎖在櫥櫃、抽屜內。

□是，□否　11. 您是否知道不慎吞食了不該吃的東西時，應保留容器，並立刻去電毒物諮詢中心**02-2871-7121**詢問緊急處理方法。

□是，□否　12. 您是否知道瓦斯熱水器應安裝於室外通風處，並隨時保持室內空氣流通，以減少一氧化碳中毒的可能性。

# ការពារការរងរបួសដោយចៃដន្យ

សូមអាណាព្យាបាលធ្វើការផ្ទៀងផ្ទាត់សន្ទស្សន៍ខាងក្រោមនេះ ប្រសិនបើមានចម្លើយ “ទេ” សូមប្រញាប់ធ្វើការកែខៃ ដើម្បីធានាសុវត្ថិភាពក្នុងផ្ទះដល់កុមារ។

## ការបង្ការការរលាកភ្លើង

☐ មែន ☐ ទេ 1. តើអ្នកជៀសវាងក្រាលក្រមាលតុនៅលើតុបាយដែរឬទេ? ពេលលើកម្ហូបឬម្ហូបក្ដៅមកលើតុ តើអ្នកមើលទារកថាតើនៅក្បែរដែរឬទេ?

☐ មែន ☐ ទេ 2. តើអ្នកហាមមិនឲ្យកុមារមកជិតឆ្នាំងអ៊ុតនិងអំពូលភ្លើងក្ដៅដែរឬទេ?

☐ មែន ☐ ទេ 3. ពេលអ្នករៀបចំទឹកស្រមាប់ងូតតើអ្នកជានិច្ចកាលតែងដាក់ទឹកត្រជាក់មុនរួចទើបដាក់ទឹកក្ដៅជាក្រោយមែនទេ? មុនពេលទារកចូលក្នុងអាងងូតទឹក អ្នកសាកកម្ដៅទឹកជាមុន។

## ការបង្ការការធ្លាក់ឬដួល

☐ មែន ☐ ទេ 4. តើអ្នកដឹងដែរឬទេថាចាប់ពីជាន់ទី២ឡើងលើ ហាមដាច់ខាតមិនឲ្យកុមារវារឡើងលើបង្អួច?

☐ មែន ☐ ទេ 5. តើអ្នកប្រុងប្រយ័ត្នមិនដាក់កម្រាលដែលងាយនឹងរអិលដែរឬទេ?ពេលផ្ទះរអិលខ្លាំង តើអ្នកឲ្យកុមារពាក់ស្រោមជើងឬស្បែកជើងការពាររអិលដែរឬទេ?

☐ មែន ☐ ទេ 6. តើអ្នកមានបំពាក់បរិក្ខារការពាររអិលនៅក្នុងបន្ទប់ទឹកឬអាងងូតទឹកដែរឬទេ?

☐ មែន ☐ ទេ 7. តើអ្នកមានប្រើស្រោមការពារជ្រុងស្រួចទៅលើសម្ភារៈក្នុងផ្ទះដែលមានជ្រុងស្រួចដែរឬទេ?ឬផ្លាស់ប្ដូរទីតាំងសម្ភារៈក្នុងផ្ទះជាបណ្ដោះអាសន្ន?

## ការបង្ការការថប់ដង្ហើម ឈ្លក់ ធ្លាក់ និងត្រូវថ្នាំពុល

☐ មែន ☐ ទេ 8. តើអ្នកដឹងទេថា សម្ភារៈប្រើប្រាស់ដែលអាចបង្កើតជាលំហរបិទជិតដូចជា ទូទឹកកក និងម៉ាស៊ីនបោកខោអាវជាដើម ត្រូវជ្រើសរើសយកមួយណាដែលកុមារមិនងាយបើកបាន ឬបំពាក់បរិក្ខារដែលទារកមិនងាយបើកបាន ដើម្បីជៀសវាងកុំឲ្យទារកច្រលំចូល និងបង្កឲ្យថប់ដង្ហើម។

☐ មែន ☐ ទេ 9. តើអ្នកជៀសវាងមិនឲ្យកុមារយកវត្ថុតូចៗ (ដូចជា កាក់ លេវអាវ កូនឃ្លី ម្ជុលខ្ទាស់ ឬកូនវ៉ីសជាដើម) ដែរឬទេ?ពេលទិញរបស់ក្មេងលេង ត្រូវពិនិត្យឲ្យបានច្បាស់ថាផ្នែកផ្គុំនៅលើរបស់នោះងាយនឹងជ្រុះចេញមកដែរឬទេ (ដូចជាគ្រាប់ភ្នែកតុក្កតាជាដើម)។

☐ មែន ☐ ទេ 10. តើអ្នកបានយកឱសថផ្សេងៗ(ជាពិសេសទឹកសេរ៉ូ) ទឹកបោកគក់ ថ្នាំសម្លាប់សត្វល្អិត សាប៊ូកក់សក់ សាប៊ូដុសខ្លួន ប្រេងសាំង គ្រឿងសម្អាង និងវត្ថុគ្រោះថ្នាក់ដទៃទៀតដាក់នៅលើទីខ្ពស់ ឬ ចាក់សោរក្នុងទូឬថតតុដែរឬទេ?

☐ មែន ☐ ទេ 11. តើអ្នកដឹងទេថា ពេលលេបរបស់ដែលមិនគួរលេបរួច ត្រូវរក្សាទុកកញ្ចប់ និងទូរស័ព្ទទៅមជ្ឈមណ្ឌលប្រឹក្សាថ្នាំពុល **02-2871-7121** ដើម្បីសួររកវិធីដោះស្រាយបន្ទាន់។

☐ មែន ☐ ទេ 12. តើអ្នកដឹងទេថា ម៉ាស៊ីនទឹកក្ដៅប្រើហ្គាស ត្រូវតម្លើងនៅកន្លែងមានខ្យល់ចេញចូលខាងក្រៅផ្ទះ ព្រមទាំងរក្សាខ្យល់អាកាសក្នុងផ្ទះឲ្យបានគ្រប់គាន់ ដើម្បីកាត់បន្ថយលទ្ធភាពនៃការពុលការបូនម៉ូណូស៊ីត។

# 預防事故傷害

## 車禍的預防

□是，□否 13. 您開車載幼兒前，是否會先固定好幼兒汽車安全座椅，再安置幼兒並繫好安全帶，且不讓幼兒坐在前座。並會避免用機車載幼兒。

□是，□否 14. 您是否知道開車前必須先安置幼兒上車，行車時按下兒童安全鎖，停車後讓幼兒最後下車。

□是，□否 15. 您是否知道不可將幼兒單獨留在車內。因為緊閉門窗的車子，在大熱天只需10分鐘的日曬，車內溫度就可能高達54-60度，對熱度比較敏感的嬰幼兒，即使只是短暫時間留置其中，也會受到嚴重熱傷害。

□是，□否 16. 您是否會禁止幼兒在馬路邊嬉戲。

□是，□否 17. 您倒車時，是否先確認幼兒不在車子後面，避免倒車造成傷害、死亡。

## 溺水的預防

□是，□否 18. 您是否會注意避免讓幼兒獨自留在浴盆、小池塘邊、河邊、游泳池邊或海邊，即使只是幾秒鐘也不行。

□是，□否 19. 您家中的任何儲水容器使用完畢後，是否會將水倒掉、放乾或將容器加蓋，以免幼兒栽入窒息。

□是，□否 20. 您是否知道池塘或魚池應加裝柵欄，避免幼兒不慎跌落而溺斃。

## 防墜的預防

□是，□否 21. 窗戶有裝設護欄或安全鎖且窗戶之窗臺高度不得小於110公分，10層以上不得小於120公分。

□是，□否 22. 窗戶旁不放置床、椅子、桌子或矮櫃等可攀爬之傢俱以防幼童墜落。

□是，□否 23. 陽臺上沒有可當腳凳東西。

□是，□否 24. 陽臺欄杆高度設計不易幼童攀爬。

□是，□否 25. 陽臺欄杆高度設計至少110公分以上，10層以上者，不得小於120公分且間距小於10公分。陽臺欄杆高度設計至少120公分以上，且間距小於10公分。

## 其他

□是，□否 26. 繩索長度及收線器位置應收置幼童無法碰觸的高度(如窗簾繩、電線、延長線…)。

□是，□否 27. 您是否知道塑膠袋、尿布、鈕扣等易引起幼童窒息，應收納於幼童無法碰觸的地方。

□是，□否 28. 您是否知道幼兒與寵物接觸時，應有大人在旁監督。

□是，□否 29. 您是否知道電動捲門可能將幼兒壓傷，所以最好加裝碰觸物體自動停止裝置，否則也應將開關設在幼兒無法觸及的地方。

□是，□否 30. 您房間中是否設置煙霧偵測器，平時即設想好火災時的應變措施及逃生途徑。廚房中並且備有滅火器。

# ការពារការរងរបួសដោយចៃដន្យ

## ការបង្ការគ្រោះថ្នាក់ចរាចរណ៍

☐ មែន ☐ ទេ 13. មុនពេលអ្នកបើកឡានដឹកកុមារ តើអ្នកដាក់កៅអីសុវត្ថិភាពកុមារឲ្យនៅនឹងជាមុន បន្ទាប់មកដាក់ខ្សែក្រវ៉ាត់សុវត្ថិភាពឲ្យកុមារ និងមិនឲ្យកុមារអង្គុយនៅកៅអីមុខដែរឬទេ? និងជៀសវាងឱបកុមារដោយម៉ូតូ។

☐ មែន ☐ ទេ 14. តើអ្នកដឹងទេថា មុនពេលបើកទ្វារត្រូវឲ្យកុមារឡើងឡានមុនគេ ពេលកំពុងបើកឡាត្រូវចុចសោរសុវត្ថិភាពកុមារ និងពេលឈប់ឡាត្រូវឲ្យកុមារចុះក្រោយគេ?

☐ មែន ☐ ទេ 15. តើអ្នកដឹងទេថាមិនត្រូវឲ្យកុមារនៅក្នុងឡានតែម្នាក់ឯង? ព្រោះពេលឡានបិទកញ្ចក់ជិត ដាក់នៅក្រោមមេឃក្តៅរយៈប្រហែល ១០នាទី កម្តៅក្នុងឡានអាចនឹងកើនឡើងដល់ ៥៤ ទៅ ៦០អង្សារ។ ទារកមានប្រតិកម្មរហ័សចំពោះកម្តៅ នាំឲ្យបើទោះបីស្ថិតនៅក្នុងនោះរយៈពេលខ្លី ក៏អាចនឹងទទួលគ្រោះថ្នាក់ពីកម្តៅដែរ។

☐ មែន ☐ ទេ 16. តើអ្នកហាមឃាត់មិនឲ្យកុមារលេងនៅមាត់ផ្លូវដែរឬទេ?

☐ មែន ☐ ទេ 17. ពេលអ្នកថយឡាន តើអ្នកបញ្ជាក់ជាមុនទេថាកុមារមិននៅក្រោយឡាន ដើម្បីជៀសវាងកុំឲ្យមានគ្រោះថ្នាក់បង្កជារបួសស្នាម ឬស្លាប់ដោយសារការថយឡាន?

## ការបង្ការការលង់ទឹក

☐ មែន ☐ ទេ 18. តើអ្នកជៀសវាងមិនឲ្យកុមារនៅក្នុងអាងងូតទឹក ក្បែរមាត់ស្រះ មាត់ស្ទឹងទន្លេ មាត់អាងហែលទឹក ឬមាត់សមុទ្រតែម្នាក់ឯងដែរឬទេ ទោះបីជាប៉ុន្មាននាទីក៏ដោយ?

☐ មែន ☐ ទេ 19. សម្ភារៈផ្ទុកទឹកក្នុងផ្ទះរបស់អ្នកពេលប្រើប្រាស់រួច តើអ្នកចាក់ទឹកចោល រំហូត ឬបិទគំរបដែរឬទេ ដើម្បីជៀសវាងកុំឲ្យកុមារធ្លាក់ចូលថប់ដង្ហើម?

☐ មែន ☐ ទេ 20. តើអ្នកដឹងទេថាទីស្រះ ឬអាងត្រីត្រូវធ្វើរបងហ៊ុមព័ទ្ធ ដើម្បីជៀសវាងកុំឲ្យលង់ទឹក?

## ការបង្ការការធ្លាក់

☐ មែន ☐ ទេ 21. បង្អួចត្រូវមានដាក់បរិក្ខារការពារបង្អួច ឬសោរសុវត្ថិភាព ម្យ៉ាងទៀតកម្ពស់ធ្នើបង្អួចត្រូវខ្ពស់ជាង១១០សង់ទីម៉ែត្រ បើកម្ពស់១០ជាន់មិនត្រូវទាបជាង១២០សង់ទីម៉ែត្រឡើយ។

☐ មែន ☐ ទេ 22. នៅជិតបង្អួចមិនត្រូវដាក់គ្រែ កៅអី តុ ឬទូដែលអាចវារឡើងបាននៅក្បែរនោះទេ ជៀសវាងកុំឲ្យទារកធ្លាក់ពីលើបង្អួច។

☐ មែន ☐ ទេ 23. នៅរានហាលមិនត្រូវមានរបស់អាចជាន់បាននោះទេ។

☐ មែន ☐ ទេ 24. កម្ពស់របងនៅរានហាលត្រូវធ្វើឲ្យខ្ពស់កុំឲ្យកុមារងាយឡើង។

☐ មែន ☐ ទេ 25. របងរានហាលមានកម្ពស់យ៉ាងតិចចាប់ពី១១០សង់ទីម៉ែត្រឡើងលើ បើកម្ពស់ចាប់ពី១០ជាន់ឡើងលើ មិនត្រូវទាបជាង១២០សង់ទីម៉ែត្រឡើយ ម្យ៉ាងទៀតមានកម្លាតតូចជាង១០សង់ទីម៉ែត្រ។ របងរានហាលមានកម្ពស់យ៉ាងតិចចាប់ពី១២០សង់ទីម៉ែត្រឡើងលើ ម្យ៉ាងទៀតមានកម្លាតតូចជាង១០សង់ទីម៉ែត្រ។

## ផ្សេងទៀត

☐ មែន ☐ ទេ 26. ប្រវែងខ្សែ និងប្រដាប់បម្លៃខ្សែត្រូវដាក់នៅកន្លែងដែលកុមារឈោងចាប់មិនដល់ (ដូចជា ខ្សែវាំងនន ខ្សែភ្លើង...)

☐ មែន ☐ ទេ 27. តើអ្នកដឹងទេថា ថង់ផ្លាស្ទិច កន្ទបទឹកនោម ឬលេះអាវជាដើម ងាយធ្វើឲ្យកុមារថប់ដង្ហើម ត្រូវប្រមូលទុកនៅកន្លែងដែលកុមារឈោងមិនដល់។

☐ មែន ☐ ទេ 28. តើអ្នកដឹងទេថា ពេលកុមារប៉ះពាល់ជាមួយសត្វចិញ្ចឹម ត្រូវមានមនុស្សធំនៅក្បែរ?

☐ មែន ☐ ទេ 29. តើអ្នកដឹងទេថា ទ្វារបិទស្វ័យប្រវត្តិអាចកិនឲ្យកុមាររបួស ដូចនេះត្រូវតម្លើងបរិក្ខារដែលឈប់ដោយស្វ័យប្រវត្តិពេលប៉ះវត្ថុទាំងឡាយ បើពុំនោះទ្រូវតម្លើងកុងតាក់បិទបើកនៅកន្លែងដែលកុមារឈោងមិនដល់។

☐ មែន ☐ ទេ 30. តើក្នុងបន្ទប់របស់អ្នកមានម៉ាស៊ីនពិនិត្យផ្សែងដែរឬទេ និងបានគិតទុកពីមធ្យោបាយទប់ទល់និងផ្លូវរត់ចេញពេលមានអគ្គីភ័យ?

# 燒燙傷及瓦斯事故傷害緊急處理

常見燒燙傷及瓦斯外洩意外，在第一時間有其正確處理步驟。平日熟悉這些步驟，能在緊急時刻將傷害降到最低，所以請家長務必要牢記。

## 燙傷急救五步驟『沖、脫、泡、蓋、送』

**沖：** 迅速以流動的自來水沖洗傷口15-30分鐘，或將受傷部位浸泡於冷水內，以快速降低皮膚表面熱度。

**脫：** 充分泡濕後，再小心除去衣物；必要時用剪刀剪開衣服，並暫時保留黏住的部分。儘量避免將傷口水泡弄破。

**泡：** 繼續浸泡於冷水15-30分鐘，可減輕疼痛及穩定情緒。但若燙傷面積廣大，或幼童年齡較小，則不必浸泡過久，以免體溫下降過度，或延誤治療時機。

**蓋：** 用清潔乾淨的床單或布單、紗布覆蓋。勿任意塗上外用藥或民間偏方，這些東西可能無助於傷口的復原，並且容易引起傷口感染，及影響醫護人員的判斷和緊急處理。

**送：** 除極小之燙傷可以自理之外，應送往鄰近的醫療院所做進一步的處理。若傷勢較大，則最好轉送到設置有燙傷中心的醫院治療。

## 瓦斯外洩處理四步驟『禁、關、推、離』

**禁：** 禁止開或關任何電器用品，如抽油煙機、電燈等，也不可以插拔電插頭。

**關：** 先關閉瓦斯總開關，但不可碰觸瓦斯爐開關，以免產生火花。

**推：** 輕輕緩緩推開（打開）門窗，讓空氣流通。

**離：** 離開現場，疏散至屋外安全場所，再打電話通知當地瓦斯公司，請求檢測外洩情形，或通報**119**消防局求助。

# ដំណោះស្រាយបន្ទាន់ពេលមានរបួសរលាកនិងរបួសដោយសារហ្គាស

ឧបទ្ទវហេតុទូទៅនៃរបួសរលាកនិងធ្លាយហ្គាស មានជំហានដោះស្រាយត្រឹមត្រូវក្នុងពេលទី១ បើស្គាល់ច្បាស់ជំហានទាំងនេះ អាចជួយបន្ធូរគ្រោះថ្នាក់ឲ្យនៅទាបបំផុត ដូច្នេះសូមអាណាព្យាបាលត្រូវចងចាំ។

## សង្គ្រោះបន្ទាន់៥ជំហានពេលមានរបួសរលាក "លាង ដោះ ត្រាំ គ្រប បញ្ជូន"

**លាង ៖** ប្រើទឹកដែលហូរក្នុងល្បឿនលាងជ្រមះមុខរបួសពី ១៥ ទៅ ៣០នាទី ឬយកមុខរបួសត្រាំក្នុងទឹកត្រជាក់ ដើម្បីបញ្ចុះកម្តៅស្បែកជាបន្ទាន់។

**ដោះ ៖** ពេលត្រាំគ្រប់គ្រាន់ហើយ ទើបដោះខោអាវដោយប្រយ័ត្ន។ ពេលចាំបាច់ត្រូវប្រើកាំបិតឬកន្ត្រៃកាត់ខោអាវចេញ និងបន្សល់ទុកកន្លែងដែលស្អិតជាប់ជាបណ្តោះអាសន្ន។ ជៀសវាងធ្វើឲ្យបែកខ្ទុះមុខរបួស។

**ត្រាំ ៖** បន្តត្រាំក្នុងទឹកត្រជាក់ពី ១៥ ទៅ ៣០នាទី អាចកាត់បន្ថយការឈឺចាប់ និងធ្វើឲ្យអារម្មណ៍នឹងនរ។ ប្រសិនបើមុខរបួសរលាកមានបរិវេណធំ ឬកុមារមានអាយុតូច នោះមិនចាំបាច់ត្រាំក្នុងទឹកយូរនោះទេ ជៀសវាងកុំឲ្យកម្តៅខ្លួនធ្លាក់ចុះហួសហេតុ ឬពន្យាពេលព្យាបាល។

**គ្រប ៖** រុំដោយសំឡីស្ប ក្រណាត់ ឬក្រមាលពូកដែលស្អាត។ ហាមលាបមុខរបួសដោយថ្នាំលាបឬថ្នាំបុរាណផ្តេសផ្តាស ព្រោះរបស់ទាំងនេះអាចនឹងគ្មានផលប្រយោជន៍ក្នុងការជួយឲ្យមុខរបួសជាសះស្បើយឡើយ ម្យ៉ាងទៀតវាអាចងាយនឹងបង្កឲ្យមុខរបួសឆ្លងមេរោគ និងប៉ះពាល់ដល់ការវិភាគនិងព្យាបាលមុខរបួសរបស់គ្រូពេទ្យ។

**បញ្ជូន ៖** ក្រៅពីរបួសរលាកតូចៗដែលអាចដោះស្រាយដោយខ្លួនឯងបាន គប្បីត្រូវទៅព្យាបាលនៅមន្ទីរពេទ្យដែលនៅជិត។ ប្រសិនបើរបួសធំ ត្រូវទៅព្យាបាលនៅមន្ទីរពេទ្យដែលមានមណ្ឌលព្យាបាលរបួសរលាកជាពិសេស។

## ដំណោះស្រាយការធ្លាយហ្គាស៤ជំហាន "ហាម បិទ រុញ ចាកចេញ"

**ហាម ៖** ហាមបើកឬបិទឧបករណ៍អគ្គិសនីទាំងឡាយ ឧទាហរណ៍ ម៉ាស៊ីនបឺតផ្សែង និងអំពូលភ្លើងជាដើម ហើយក៏មិនត្រូវដោតឬដកដុយភ្លើង។

**បិទ ៖** ត្រូវបិទកន្លែងបិទបើកហ្គាសរួមជាមុន តែហាមប៉ះពាល់កន្លែងបិទបើកចង្ក្រានហ្គាស ជៀសវាងកុំឲ្យមានផ្កាភ្លើង។

**រុញ ៖** រុញ (បើក) ទ្វារបង្អួច យឺតៗសន្សឹមៗ ឲ្យខ្យល់ចេញចូល។

**ចាកចេញ ៖** ចាកចេញពីកន្លែងកើតហេតុទៅកន្លែងសុវត្ថិភាពខាងក្រៅផ្ទះទើបទូរស័ព្ទទៅកាន់ក្រុមហ៊ុនឧស្ម័នហ្គាស្របចាំទីនោះដើម្បីសុំជំនួយត្រួតពិនិត្យស្ថានភាពនៃការធ្លាយ ឬទូរស័ព្ទរាយការណ៍ទៅមន្ទីរពន្លត់អគ្គីភ័យ 119។

# 保貝!寶貝!113保護專線

每個孩子都是家庭的寶貝、社會的希望。孩子就像脆弱的幼苗，大人的一時情緒失控、不當體罰管教，或是心存僥倖而疏忽，就有可能在一瞬間造成無法補救的傷害。讓我們一起來寶貝孩子，讓他們都能在「免於恐懼、沒有傷害」的安全環境下，健康快樂地長大。

## 別讓憤怒情緒主宰您的行動

- 責打並不能教導孩子做好事情，它只會使孩子變得暴力並且失去控制。
- 憤怒的父母一時失控，可能造成孩子重大傷害，如腦部受傷、身體內出血，或終身殘障甚至死亡。當孩子因而傷亡，父母會被依刑法和兒童及少年福利與權益保障法加重其刑1/2，嚴重者判處無期徒刑！
- 孩子大部分是被憤怒的父母所傷害，不要讓憤怒主宰了您的行動，如果您害怕自己會傷害孩子，請立即尋求以下幫助：
  - 當您覺得很生氣的時候，離開現場，不要接近孩子。
  - 打電話給您的朋友或親戚，說出自己的憤怒。
  - 向家庭教育中心，請教並學習正確管教孩子的要領。

## 父母心存僥倖將使自己觸法

- 兒童意外喪生不幸事件的原因包括墜樓、悶死車內、火災及意外災害；兒童安全是父母的責任，不要心存僥倖，就算只是一分鐘也別讓寶貝單獨在家或留置車上。
- 「兒童及少年福利與權益保障法」中明文規定，不可以將6歲以下或需要特別看護之兒童及少年單獨放在危險的環境中，例如讓孩子一個人在家或是在車內，或是由不適當的人照顧（比如孩子，或精神疾病、酗酒、吸毒的人等）。
- 違反以上規定，將會遭到罰款（3,000元以上，15,000元以下），或是強制接受親職教育輔導（4小時以上，50小時以下）。若拒絕參加輔導，將遭到累積罰款，一直罰到參加為止。

### 小提示

1. 兒少的基本資料（姓名、年齡、電話、地址等）
2. 受傷情形
3. 受虐史
4. 家庭狀況
5. 生活照顧情形

## 協助通報人人有責

- 如果發現鄰居孩子被責打、不當對待或單獨留在家裡，您可以幫忙打電話到**113**或報警**110**請求協助，這樣可以避免孩子發生危險。
- 通報時請盡量蒐集相關資訊，如兒少的基本資料(姓名、年齡、電話、地址等)、受傷情形、受虐史、家庭狀況、生活照顧情形等。
- 通報資訊越完整，越有助於社工員及時、有效判斷案件之危急程度，給予適當處遇。

# ខ្សែទូរស័ព្ទការពារកូនសម្លាញ់113!

បុត្រធីតាប្រៀបបាននឹងពន្លកខ្ចី ប៉ុន្តែការគ្រប់គងអារម្មណ៍មិនបានរបស់មនុស្សធំ ការអប់រំមិនដិតដល់ ឬការធ្វេសប្រហែស អាចបង្កជាការឈឺចាប់ដែលមិនអាចប៉ះប៉ូវបានក្នុងមួយប្រ៉ព័ថ្ងៃភ្នក។ សូមយើងទាំងអស់គ្នាស្រលាញ់ថ្នាក់ថ្នមបុត្រធីតារបស់ខ្លួន ដើម្បីឲ្យពួកេគធំលូតលាស់ដោយសប្បាយរីករាយក្នុងមជ្ឈដ្ឋាន "គ្មានការភ័យខ្លាច និងគ្មានការឈឺចាប់" ។

## កុំឲ្យកំហឹងរបស់អ្នកគ្រប់គ្រងលើសកម្មភាពរបស់អ្នក

- ការស្តីបន្ទោសនិងការវាយដំ មិនអាចអប់រំឲ្យកូនធ្វើកិច្ចការនានាឲ្យបានល្អនោះទេ តែវាបែរជាធ្វើឲ្យកូនក្លាយទៅជាហិង្សា និងមិនចេះគ្រប់គ្រងខ្លួនឯង។
- ពេលម្តាយឪពុកបាត់បង់សតិពេលមានកំហឹង អាចបង្កជារបួសធ្ងន់ធ្ងរដល់កូន ដូចជា របួសក្បាល ចេញឈាមក្នុងខ្លួន ឬពិការមួយជីវិត រហូតដល់ស្លាប់។ ប្រសិនបើកូនរបួសឬស្លាប់ដោយមូលហេតុនេះ ម្តាយឪពុកនឹងត្រូវបានដាក់បន្ថែមទោស១/២ ឬជាប់ពន្ធនាគារមួយជីវិត យោងតាមច្បាប់ព្រហ្មទណ្ឌនិងច្បាប់ការពារសិទ្ធិនិងសុខុមាលភាពរបស់កុមារនិងក្មេងជំទង់។
- កូនភាគច្រើនត្រូវបានបង្ករបួសស្នាមដោយសារឪពុកម្តាយ។ កុំឲ្យកំហឹងគ្រប់គ្រងលើសកម្មភាពរបស់អ្នក។ប្រសិនបើអ្នកខ្លាចខ្លួនឯងបង្ករបួសស្នាមដល់កូន សូមស្វែងរកជំនួយខាងក្រោមនេះជាបន្ទាន់៖
  - ពេលអ្នកខឹងខ្លាំង សូមចាកចេញឲ្យឆ្ងាយ កុំទៅជិតកូន។
  - ទូរស័ព្ទទៅកាន់សាច់ញាតិឬមិត្តភ័ក្តិ ដើម្បីរៀបរាប់ពីកំហឹងរបស់ខ្លួន។
  - រៀនពីរបៀបអប់រំកូនដោយត្រឹមត្រូវពីមជ្ឈមណ្ឌលអប់រំគ្រួសារ។

## គំនិតរួចខ្លួនរបស់ឪពុកម្តាយ នឹងធ្វើឲ្យខ្លួនឯងល្មើសច្បាប់

- មូលហេតុនៃការស្លាប់ដោយឧបទ្ទវហេតុរបស់កុមាររួមមាន ធ្លាក់ពីលើអគារ ហប់ស្លាប់ក្នុងឡាន អគ្គីភ័យ និងគ្រោះថ្នាក់ឧបទ្ទវហេតុដទៃសុទ្ធតែជាទំនួលខុសត្រូវរបស់ឪពុកម្តាយ។ សូមកុំគិតថារួចខ្លួន បើទោះបីជាត្រឹម១នាទី ក៏មិនត្រូវឲ្យកូននៅផ្ទះ ឬនៅក្នុងឡានតែម្នាក់ឯងដែរ។
- "ច្បាប់ការពារសិទ្ធិនិងសុខុមាលភាពកុមារនិងក្មេងជំទង់" បានចែងថា មិនត្រូវទុកកុមារអាយុក្រោម៦ឆ្នាំ ឬកុមារនិងក្មេងជំទង់ដែលត្រូវការមើលថែទាំពិសេស ចោលនៅក្នុងមជ្ឈដ្ឋានដែលគ្រោះថ្នាក់តែម្នាក់ឯងនោះទេ ឧទាហរណ៍ ទុកកូនចោលនៅក្នុងផ្ទះឬឡានតែម្នាក់ឯង ឬត្រូវបានមើលការថែទាំដោយមនុស្សមិនសមស្រប(ដូចជា កុមារ ឬអ្នកជម្ងឺសសៃប្រសាទ មនុស្សញានស្រានិងញៀនថ្នាំជាដើម)។
- បើល្មើសមាត្រាខាងលើ នឹងត្រូវបានផាកពិន័យជាប្រាក់ (លើ៣.០០០យេន ក្រោម១៥.០០០យេន)ឬត្រូវទទួលការណែនាំស្តីអំពីការអប់រំបុត្រធីតា (លើ៤ម៉ោង ក្រោម៥០ម៉ោង)។ ប្រសិនបើបដិសេធមិនចូលរួមការបង្រៀនណែនាំ នោះនឹងត្រូវបានបង្គប្រាក់ពិន័យរហូតដល់ពេលចូលរួម។

### រំលឹក

1. ពត៌មានមូលដ្ឋានរបស់កុមារ (ឈ្មោះ អាយុ ទូរស័ព្ទ អាស័យដ្ឋាន)
2. ស្ថានភាពរងរបួស
3. ប្រវត្តិត្រូវបានេគធ្វើបាប
4.. ស្ថានភាព្រគួសារ
5. ស្ថានភាពៃនការេមើលែថទាំក្នុងការរស់េនៅ

## ជួយរាយការណ៍ គ្រប់គ្នាមានទំនួលខុសត្រូវ

- ប្រសិនបើប្រទះឃើញកូនអ្នកជិតខាងត្រូវបានវាយដំ ធ្វើបាប ឬត្រូវបានទុកចោលនៅផ្ទះតែម្នាក់ឯង អ្នកអាចទូរស័ព្ទទៅកាន់ 113 ឬរាយការណ៍ទៅសមត្ថកិច្ច 110 ដើម្បីសុំជំនួយ នោះអាចជួយបញ្ចៀសគ្រោះថ្នាក់ដែលអាចកើតមានចំពោះកុមារ។
- ពេលរាយការណ៍ សូមប្រមូលទិន្នន័យដែលពាក់ព័ន្ធឲ្យបានច្រើនទៅតាមលទ្ធភាព ដូចជា ពត៌មានមូលដ្ឋានរបស់កុមារ (ឈ្មោះ អាយុ ទូរស័ព្ទ អាស័យដ្ឋាន) ស្ថានភាពរងរបួស ប្រវត្តិត្រូវបានគេធ្វើបាប ស្ថានភាពគ្រួសារ និងស្ថានភាពនៃការមើលថែទាំក្នុងការរស់នៅ។
- រាយការណ៍កាន់តែពេញលេញ កាន់តែជួយដល់បុគ្គលិកការងារធ្វើការវិភាគពីកម្រិតនៃគ្រោះថ្នាក់បានកាន់តែឆាប់ និងជួយដោះស្រាយបានត្រឹមត្រូវ។

# 親親・寶貝-協助孩子遠離家庭暴力

## 親親・寶貝-協助孩子遠離家庭暴力

孩子出生後，夫妻間易因角色轉換、子女照顧及教養議題出現許多衝突，甚至出現家庭暴力行為。根據國內外相關研究及實務經驗顯示，長期目睹父母激烈爭吵或暴力行為，將對孩子產生許多負面影響。

## 目睹家庭暴力可能對孩子的影響

- 許多父母常認為孩子年紀小，不清楚父母之間發生什麼事，或即便孩子看到或聽到父母激烈爭吵或暴力行為，也不會有任何不良影響，但事實上，不論孩子年紀多小，不論孩子是否看到或聽到父母間的激烈爭吵或暴力行為，都會使孩子的生理與心理發展產生負面影響。
- 長期目睹父母激烈衝突或暴力行為，孩子會出現以下反應：
  - 嬰幼兒及學齡前階段
    - 生理層面出現發展遲緩現象
    - 出現嚴重的分離焦慮
    - 因恐懼、不安而影響孩子探索及遊戲能力
    - 在遊戲中可能模仿父母的暴力行為
    - 不敢表達情緒，或用激烈的方式表達憤怒與攻擊
    - 認為暴力是自己所導致的
    - 出現退化（如：已會自己上廁所後，突然變成經常尿在褲子上）
  - 學齡期階段
    - 恐懼、害怕、無力、憤怒、覺得都是自己的錯、缺乏安全感
    - 攻擊行為、焦慮（如：咬指甲、拔頭髮）、沮喪、退縮
    - 頭痛、胃痛、厭食、嗜睡、注意力不集中等
    - 對父母說相愛卻彼此傷害的行為，感到困惑、混淆
    - 認為暴力可以解決問題

## 如何幫助孩子遠離家庭暴力

- 家庭應是提供孩子穩定及安全成長的場所，保護孩子免於遭受家庭暴力的傷害更是父母的責任，因此，如果您和伴侶有意見上的爭執時，應冷靜地想辦法解決，切勿以暴力行為來逼迫對方屈服，或是藉由傷害孩子來報復對方，應尊重每個孩子的生命權。
- 如果您和伴侶的衝突已無法自行解決，甚至已經出現暴力行為，便應向專業人員尋求協助，或撥打113保護專線諮詢，才能真正改善彼此的關係，並讓孩子在安全、穩定及健康的關係中成長。

# ថើប•កូនសម្លាញ់-ជួយឲ្យកូនចាកឆ្ងាយពីអំពើហិង្សាក្នុងគ្រួសារ

## ថើប•កូនសម្លាញ់-ជួយឲ្យកូនចាកឆ្ងាយពីអំពើហិង្សាក្នុងគ្រួសារ

ក្រោយពេលកូនចាប់កំណើត ស្វាមីភរិយាតែងងាយនឹងមានទំនាស់គ្នា រហូតដល់មានអំពើហិង្សាក្នុងគ្រួសារ ដោយសារ ការផ្លាស់ប្ដូរតួអង្គ ការមើលថែទាំកូន និងការអប់រំកូន។ យោងទៅតាមការស្រាវជ្រាវនិងការពិសោធជាក់ស្ដែងក្នុងបែទស់បានបង្ហាញឲ្យឃើញថា ការមើលឃើញម្ដាយឪពុកឈ្លោះប្រកែកគ្នា ឬប្រើអំពើហិង្សាលើគ្នារយៈពេលយូរ នឹងមានផលប៉ះពាល់អវិជ្ជមានជាច្រើនដល់កូន។

## ការមើលឃើញអំពើហិង្សាក្នុងគ្រួសារមានផលប៉ះពាល់អវិជ្ជមានដល់កូន

- ឪពុកម្ដាយភាគច្រើនតែងគិតថាកូនមានអាយុតិច មិនយល់ច្បាស់ថាមានរឿងអ្វីកើតឡើងរវាងឪពុកម្ដាយឡើយ ឬយល់ថាទោះបីកូនស្ដាប់ឬមើលឃើញឪពុកម្ដាយឈ្លោះប្រកែកគ្នាឬប្រើហិង្សាលើគ្នាក៏គ្មានឥទ្ធិពលអ្វីដែរ ប៉ុន្តែតាមការពិត មិនថាអាយុកូនតិចយ៉ាងណា ឬមិនថាស្ដាប់ឬមើលឃើញឪពុកម្ដាយឈ្លោះប្រកែកគ្នាឬប្រើហិង្សាលើគ្នានោះទេ សុទ្ធតែអាចបង្កឲ្យមានឥទ្ធិពលអវិជ្ជមានចំពោះការរីកចម្រើនផ្នែកសរីរៈនិងចិត្តសាស្ត្ររបស់កូន។
- មើលឃើញការឈ្លោះប្រកែកគ្នាឬការប្រើអំពើហិង្សាលើគ្នារវាងឪពុកម្ដាយក្នុងរយៈពេលយូរ កូននឹងមានប្រតិកម្មដូចខាងក្រោម៖
    - ដំណាក់កាលទារក និងកុមារមុនវ័យសិក្សា
        - ផ្នែកសរីរៈមានការរីកចម្រើនយឺត
        - មានការអន្ទះអន្ទែងធូន់ធូន់ពេលបែកគ្នា
        - ដោយសារតែភាពភ័យខ្លាចនិងមិនសុខ ប៉ះពាល់ទៅដល់សមត្ថភាពលេងល្បែងកម្សាន្តនិងការរុករករបស់កូន។
        - ក្នុងល្បែងកម្សាន្តអាចនឹងធ្វើត្រាប់តាមអំពើហិង្សារបស់ឪពុកម្ដាយ
        - មិនហ៊ានបញ្ចេញអារម្មណ៍ ឬបញ្ចេញអារម្មណ៍ខឹងសម្បារនិងការវាយប្រហារដោយទង្វើជ្រុលជ្រួស
        - យល់ថាអំពើហិង្សាកើតឡើងដោយសារខ្លួន
        - លេចចេញអាការៈចុះខ្សោយ (ឧទាហរណ៍៖ ចេះទៅបង្គន់ដោយខ្លួនឯង ប៉ុន្តែស្រាប់តែតែងតែនោមដាក់ខោ)
    - ដំណាក់កាលកុមារវ័យសិក្សា
        - តក់ស្លុត ភ័យខ្លាច គ្មានកម្លាំង ខឹងសម្បារ យល់ថាសុទ្ធតែជាកំហុសរបស់ខ្លួន ខ្វះអារម្មណ៍សុវត្ថិភាព
        - ទង្វើវាយប្រហារ អន្ទះអន្ទែង(ដូចជា៖ ខាំក្រចកដៃ ឈ្លីសក់) បាក់ទឹកចិត្ត រំញ័រ
        - ឈឺក្បាល ឈឺក្រពះ ខ្ជិមអាហារ ងងុយដេក អារម្មណ៍មិនមូល
        - មានមន្ទិលសង្ស័យនិងច្របូកច្របល់ ចំពោះទង្វើដែលឪពុកម្ដាយថាស្រលាញ់គ្នាតែបែរជាធ្វើទុក្ខទោសគ្នា
        - យល់ថាអំពើហិង្សាអាចដោះស្រាយបញ្ហាបាន

## ជួយឲ្យកុមារចាកឆ្ងាយពីអំពើហិង្សាក្នុងគ្រួសារដោយវិធីណា

- គ្រួសារ គប្បីជាទីកន្លែងដែលជួយឲ្យបុត្រធីតាធំលូតលាស់ដោយមានស្ថេរភាពនិងសុវត្ថិភាព។ ការការពារបុត្រធីតាពីអំពើហិង្សាក្នុងគ្រួសារគឺជាទំនួលខុសត្រូវរបស់ឪពុកម្ដាយ។ ដូចនេះ ប្រសិនបើអ្នកនិងដៃគូអ្នកឈ្លោះប្រកែកគ្នា ត្រូវដោះស្រាយដោយត្រជាក់ចិត្ត ហាមប្រើអំពើហិង្សាដើម្បីឲ្យភាគីម្ខាងទៀតចុះញ៉ម ឬធ្វើបាបកូនដើម្បីសងសឹកភាគីម្ខាងទៀត។ ត្រូវគោរពសិទ្ធិជីវិតរបស់កុមារគ្រប់រូប។
- ប្រសិនបើទំនាស់រវាងអ្នកនិងដៃគូអ្នកមិនអាចដោះស្រាយបានដោយខ្លួនឯង ឬកើតមានអំពើហិង្សាឡើងរួចត្រូវទៅសុំជំនួយពីអ្នកជំនាញ ឬទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទគាំពារ113 ទើបអាចកែប្រែទំនាក់ទំនងអ្នកទាំងពីរឲ្យប្រសើរឡើងវិញ ព្រមទាំងអាចឲ្យបុត្រធីតាធំដឹងក្ដីនៅក្នុងមជ្ឈដ្ឋានដែលមានសុវត្ថិភាព ស្ថេរភាព និងសុខភាព។

# 親子共讀

## 閱讀的重要性

在少子化的年代，每個孩子都是父母的寶貝。根據研究發現，及早養成閱讀習慣且喜歡閱讀的孩子，能夠從閱讀中獲得想像力的啟發與創造力的培養，不但對於孩子的腦力、語言等發展都很有助益，甚至在長大之後，各方面的表現多半也較為優異。因此，身為父母，都應該正視閱讀的重要性，尤其要養成孩子的閱讀習慣。建議父母要參與孩子的閱讀歷程，陪孩子一同領略閱讀的樂趣，在與孩子分享閱讀帶來的新奇體驗之際，也讓孩子深刻感受到父母的愛護與關懷，進而健康快樂地成長、茁壯。

## 寶寶的閱讀起步走

3-6個月大的寶寶，認知能力已慢慢發展到可受紅、黃、藍、綠等鮮豔色彩吸引；語言溝通發展方面，已經開始牙牙學語，甚至對自己的名字產生反應；生理動作發展方面，藉由抓、丟、推、拉等動作，慢慢發展出使用小肌肉的能力。在這個時候，父母可以將孩子抱在懷裡，使用柔軟的布書或可以發出聲音的童書，用溫柔的聲音教導寶寶認識書本上的顏色與形狀，從而刺激寶寶各方面的學習與成長。

7-9個月大的寶寶，生理動作已經發展到會自己坐著、使用雙手操作物品；認知能力發展到重複出現覺得有趣的探索行為（例如覺得鈴噹會發出聲音就一直去搖）、瞭解臉部表情所代表的意涵；語言溝通發展方面，會開始模仿與學習他人的說話及聲音，對簡單的指令性語彙（例如「再見」）有反應。在這個時候，父母可以鼓勵寶寶自己動手翻閱書本，輔以從旁向寶寶說明書本內容或圖片呈現的意涵，及試著用簡單的語彙與寶寶溝通互動，以激發寶寶對於閱讀的興趣。

10個月大以後的寶寶，父母可以就寶寶發展的情形，漸進加深親子共讀的方式與時間，總之，陪伴孩子閱讀的習慣與時間是不能減少的，相信身為父母的您，一定能從中發現不一樣的育兒樂趣。




សម្គាល់៖ ការអភិវឌ្ឍន៍របស់កុមារម្នាក់ៗសុទ្ធតមែានភាពមិនប្រក្រតី។ ដំណាក់កាលប្រក្រតីមានកុមារ៥០%អាចឈានដល់ការអភិវឌ្ឍន៍របស់ដំណាក់កាលនេះ។ ដំណាក់កាលសញ្ញាអាសន្នមានកុមារ៩០%អាចឈានដល់ការអភិវឌ្ឍន៍របស់ដំណាក់កាលនេះ។ ប្រសិនបើហួសដំណាក់កាលសញ្ញាអាសន្ន កុមារនៅតមែិនទាន់សម្រេចសមត្ថភាពនេះ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិត ស្វែងរកជំនួយពីអ្នកជំនាញ។

| ដំណាក់បុរុគ្គតី | ១ឆ្នាំកន្លះ | ២ឆ្នាំ | ៣ឆ្នាំ | ៤ឆ្នាំ | ៥ឆ្នាំ | ៦ឆ្នាំ |
|---|---|---|---|---|---|---|

## សកម្មភាពគ្រាតគ្រាត

- ចេះឡើងកាំជណ្ដើរដោយខ្លួនឯង
- ចេះគោងចុះពីកៅអីដោយខ្លួនឯង
- ចេះទាត់បាល់ (ជើងម្ខាងឈរនឹង ជើងម្ខាងទៀតទាត់បាល់)
- ចេះបោះបាល់ឬវត្ថុដោយហោដក្បៀរឡើងចុះក្រោម
- អាចលោតឲ្យជើងទាំងពីរលោតពីដីដោយមិនចាំបាច់ទប់
- អាចឡើងកាំជណ្ដើរដោយខ្លួនឯងដោយមិនចាំបាច់គេដឹកដៃ ឬកាន់បង្កាន់ដៃ
- អាចលោតជើងម្ខាងដោយមិនចាំបាច់ទប់
- អាចឈរនឹងជើងម្ខាងរយៈពេល១០វិនាទីដោយមិនចាំបាច់ទប់
- អាចដើរទៅមុខ២ឬ៣ជំហានដោយម្រាមជើងជាប់នឹងកែងជើង
- អាចលោតបន្តបន្ទាប់គ្នាលើសពី៥ដងដោយជើងម្ខាងដោយមិនចាំបាច់ទប់
- 45cm
- អាចលោតដោយផ្ដុំបជើងទាំងពីរលើសពីចម្ងាយ៤៥សង់ទីម៉ែត្រ

ដំណាក់កាលសញ្ញាអាសន្ន: ៣ឆ្នាំ, ៥ឆ្នាំ, ៦ឆ្នាំ

## សកម្មភាពល្អិត

- តម្រួតឈើបង្គរពីរដុំ
- ចេះបើកសៀវភៅគូរម្ដងមួយទំព័រៗ
- ចេះចាក់ទឹកពីកែវមួយទៅកែវមួយទៀត
- ចេះគូរខ្សែបញ្ឈរតាមរូបគំរូឬធ្វើតាមតាម
- អាចធ្វើតាមបត់ក្រដាសតាមអ្នកដទៃ
- ចេះគូររង្វង់តាមរូបគំរូឬធ្វើតាមតាម
- ចេះប្រើម្រាមដៃបើកាន់ប៊ិច
- ចេះគូរកាកបាទតាមរូបគំរូឬធ្វើតាមតាម
- ចេះប៉ះមេដៃម្រាមដៃមេឬម្រាមដៃផ្សេងទៀតជាមួយគ្នា
- ចេះគូរត្រីកោណសម័ង្សតាមរូបគំរូឬធ្វើតាមតាម
- ចេះគូររូបមនុស្ស (យ៉ាងហោចណាស់មានផ្នែកទាំង៦ដែលអាចស្គាល់បាន)

ដំណាក់កាលសញ្ញាអាសន្ន: ១ឆ្នាំ៨ខែ, ៣ឆ្នាំ៦ខែ, ៤ឆ្នាំ៦ខែ, ៥ឆ្នាំ៦ខែ

## ភាសានិងការយល់ដឹង

- អាចចង្អុលបង្ហាញផ្នែកមួយនៃរាងកាយ
- យ៉ាងហោចណាស់ចេះនិយាយ១០ពាក្យ
- អាចប្រាប់ឈ្មោះផ្នែកទាំង៦នៃរាងកាយដោយត្រឹមត្រូវអាចប្រាប់ឈ្មោះផ្នែកទាំង៦នៃរាងកាយដោយត្រឹមត្រូវ
- កុមារតូចនិយាយសុដីមានពាក់កណ្ដាលអាចឲ្យគេស្ដាប់បាន
- អាចប្រាប់ដោយខ្លួនឯងថាចង់ទៅបង្គន់
- ចេះនិយាយត្រកូលនិងឈ្មោះរបស់ខ្លួន
- អាចប្រាប់ពីសារៈប្រយោជន៍ប្រើប្រាស់នៃវត្ថុផងដែលឃើញពីរប្រភេទបានត្រឹមត្រូវ
- អាចបញ្ជាក់ថា “របស់អ្នក” “របស់ខ្ញុំ” បានត្រឹមត្រូវ
- អាចប្រាប់ពីភេទបានត្រឹមត្រូវ
- អាចស្គាល់ពណ៌ក្រហម លឿង និងបៃតង
- អាចយកវត្ថុតាមបញ្ជាបានត្រឹមត្រូវ (ក្នុងចំនួន៣)
- អាចតម្រាប់តាមលេខពី ១ ទៅ ១០ បានត្រឹមត្រូវ
- អាចសូត្រតាមលេខអារ៉ាប់ចំនួន៥ ឧទាហរណ៍ ៥៦២៥៧
- អាចប្រាប់ពីមុខងាររបស់អវយវៈរាងកាយ ឧទាហរណ៍ ភ្នែក មាត់...

ដំណាក់កាលសញ្ញាអាសន្ន: ២ឆ្នាំ, ៣ឆ្នាំ៦ខែ

## ជំនាញសុវាយជើញខ្លួន និងលក្ខណៈសង្គម

- ចេះដោះខោអាវដោយខ្លួនឯង
- ចេះបកសំបកស្ករគ្រាប់
- ចេះពាក់និងដោះស្បែកជើងគ្មានខ្សែដោយខ្លួនឯង
- អាចប្រើស្លាបព្រាញ៉ាំអាហារ
- ចេះលាងដៃនិងជូតសម្អាតដោយខ្លួនឯង
- ចេះស្លៀកពាក់ខោអាវដោយខ្លួនឯង
- អាចលេងល្បែងកម្សាន្តជាមួយគ្នានិងគ្នា
- ពេលថ្ងៃឈប់នោមដាក់ខោ
- ចេះពាក់ស្រោមជើងដោយខ្លួនឯង
- ចេះប្រើច្រាសដុសធ្មេញដុសធ្មេញ
- ចេះរឹតឡើងឬរឹតចេញខ្សែដៃ
- ចេះលេងល្បែងកម្សាន្តដែលមានច្បាប់ងាយៗ ឧទាហរណ៍ បិទពួន

ដំណាក់កាលសញ្ញាអាសន្ន: ២ឆ្នាំ, ៣ឆ្នាំ, ៣ឆ្នាំ, ៣ឆ្នាំ៦ខែ, ៣ឆ្នាំ៦ខែ, ៦ឆ្នាំ

សម្គាល់៖ ការអភិវឌ្ឍន៍របស់កុមារម្នាក់ៗសុទ្ធតែមានភាពមិនប្រក្រតី។ ដំណាក់កាលប្រក្រតីមានកុមារ៥០%អាចឈានដល់ការអភិវឌ្ឍន៍របស់ដំណាក់កាលនេះ។ ដំណាក់កាលសញ្ញាអាសន្នមានកុមារ៩០%អាចឈានដល់ការអភិវឌ្ឍន៍របស់ដំណាក់កាលនេះ។ ប្រសិនបើហួសដំណាក់កាលសញ្ញាអាសន្ន កុមារនៅតែមិនទាន់សម្រេចសមត្ថភាពនេះ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិត ស្វែងរកជំនួយពីអ្នកជំនាញ។

# អំណានគ្រួសារ

## សារៈសំខាន់នៃការអាន

ក្នុងសម័យកាលកូនតិច កូនម្នាក់ៗសុទ្ធតែជាសំណព្វចិត្តរបស់ឪពុកម្ដាយ។ យោងតាមការស្រាវជ្រាវបានឃើញថា កុមារដែលធ្លាប់មានទម្លាប់អានឬចូលចិត្តអាន អាចទទួលបានការបំភ្លឺប្រាជ្ញាញាណនិងបណ្ដុះបណ្ដាលគំនិតច្នៃប្រឌិតតាមរយៈការអាននេះ ដែលវាមិនត្រឹមតែមានប្រយោជន៍ចំពោះការរីកចម្រើននៃខួរក្បាលនិងភាសារបស់កូនប៉ុណ្ណោះទេ វាថែមទាំងជួយឲ្យកុមារមានលទ្ធផលល្អគ្រប់ផ្នែកពេលធំដឹងក្ដី។ ដូច្នេះ ក្នុងនាមជាឪពុកម្ដាយត្រូវយកចិត្តទុកដាក់ទៅលើសារៈសំខាន់នៃការអានជាពិសេសទម្លាប់អានរបស់កូន។ ណែនាំឲ្យម្ដាយឪពុកចូលរួមក្នុងការអានជាមួយកូន កំដរកូនស្វែងយល់ពីភាពសប្បាយរីករាយនៃការអាន។ ពេលចែករំលែកពីបទពិសោធន៍ការអានដ៏គួរឲ្យចាប់អារម្មណ៍ជាមួយកូន ក៏ជួយឲ្យកូនដឹងពីក្ដីស្រលាញ់និងការយកចិត្តទុកដាក់របស់ម្ដាយឪពុកមកលើខ្លួន នាំឲ្យគេធំធាត់ដោយភាពសប្បាយរីករាយ។

## ជំហាននៃការអានរបស់ទារក

ទារកអាយុពី ៣ ទៅ ៦ខែ សមត្ថភាពយល់ដឹងបានរីកចម្រើនដល់អាចទទួលការទាក់ទាញរបស់ពណ៌ឆើតឆាយដូចជា ក្រហម លឿង ខៀវ និងបៃតងជាដើម។ ផ្នែកភាសា ពួកគេចាប់ផ្ដើមរៀននិយាយ និងមានប្រតិកម្មចំពោះឈ្មោះខ្លួនឯង។ ផ្នែកចលនាសរីរៈរីកចម្រើនពី ចាប់ បោះ រុញ និងទាញ មកការប្រើប្រាស់កូនសាច់ដុំ។ ក្នុងដំណាក់កាលនេះ ឪពុកម្ដាយអាចឱបកូនជាប់ដើមទ្រូង រួចបង្រៀនឲ្យកូនស្គាល់ពណ៌និងរាងក្នុងសៀវភៅដោយសម្លេងទន់ភ្លន់ ដោយប្រើសៀវភៅក្រណាត់ទន់ឬសៀវភៅកូនក្មេងដែលចេះបញ្ចេញសម្លេង ដើម្បីភ្ញោចការសិក្សានិងការលូតលាស់គ្រប់ផ្នែករបស់ទារក។

ទារកអាយុ៧ ទៅ ៩ខែ ចលនាសរីរៈរីកចម្រើនដល់ចេះអង្គុយដោយខ្លួនឯង និងប្រើដៃទាំងសងខាងទៅលើវត្ថុនានា។ សមត្ថភាពយល់ដឹងរីកចម្រើនដល់ កើតមានទេង្វើរុករកចង់ដឹងម្ដងហើយម្ដងទៀតពេលមានចំណាប់អារម្មណ៍ទៅលើអ្វីមួយ (ដូចជា យល់ថាកណ្ដឹងចេះបញ្ចេញសម្លេង ក៏ទៅយោលកណ្ដឹងរហូត) ដឹងពីអត្តន័យនៃទឹកមុខ។ ផ្នែកទំនាក់ទំនងភាសារីកចម្រើនដល់ ចាប់ផ្ដើមចេះធ្វើត្រាប់និងរៀននិយាយពាក្យនិងសម្លេងរបស់អ្នកដទៃ និងមានប្រតិកម្មចំពោះពាក្យបញ្ជាដែលងាយ (ដូចជា “លាហើយ” )។ ក្នុងដំណាក់កាលនេះ ឪពុកម្ដាយអាចលើកទឹកចិត្តឲ្យកូនប្រើដៃបើកអានសៀវភៅដោយខ្លួនឯង ហើយធ្វើការបកស្រាយអំពីខ្លឹមសារនិងរូបភាពនៅក្នុងសៀវភៅទៅដល់កូន និង សាកល្បងប្រើពាក្យងាយៗទំនាក់ទំនងជាមួយកូន ដើម្បីភ្ញោចឲ្យកូនមានចំណាប់អារម្មណ៍ចំពោះការអាន។

ទារកអាយុ១០ខែ ឪពុកម្ដាយអាចបន្ថែមវិធីនិងពេលវេលាអានសៀវភៅជាមួយបុត្រធីតាដោយផ្អែកទៅលើការរីកចម្រើនរបស់ពួកគេ។ សរុបមក ទម្លាប់និងពេលវេលាកំដរកូនអានសៀវភៅមិនអាចកាត់បន្ថយបានទេ ជឿជាក់ថាក្នុងនាមអ្នកជាឪពុកម្ដាយ នឹងស្វែងរកឃើញភាពសប្បាយរីករាយក្នុងការអប់រំកូនតាមរយៈការអាននេះ។

# 和尿布說掰掰～如廁訓練

嬰兒的大小便是靠反射動作，完全無法自己控制；2至3歲間，生理上已成熟到可以隨意控制大小便的肌肉，幼兒就能學會在內急時，不需要提醒，自己走向馬桶，脫下褲子大小便，之後再穿好褲子，這就是所謂完成「如廁訓練」了。能夠揮別尿布，真是孩子人生中的一大步！

## 順利完成如廁訓練的正確心態

- 孩子揮別尿布是遲早的事，家長不必太急躁，應保持輕鬆愉快的態度，像是跟孩子玩遊戲似的完成訓練。
- 如果遇到阻力，勿跟孩子硬拗，可包回尿布等一、兩個星期後再試，如廁訓練終會成功的。
- 孩子失誤時，以有點惋惜的態度，告訴他下次想尿或解便的時候，趕快告訴大人，大人會幫助他。然後幫他清理乾淨，並請他幫點小忙，例如把髒尿布丟進垃圾桶等，勿責罵或體罰孩子。家長強烈的情緒反應常常是訓練失敗的主要原因。
- 即使已經成功的達成訓練，孩子仍會有幾個月的時間偶有「意外」發生，這是正常現象。勿苛責孩子，冷靜、淡然處理即可。

## 開始訓練的良好時機

- 1歲半至2歲之間，通常男孩會較女孩慢一些。
- 以下現象表示孩子已準備好了:
  - 感覺得到膀胱脹和便意（例如突然安靜下來、臉部表情改變、跳腳、蹲下、拉扯褲子或用語言、手勢告訴大人）。
  - 尿濕了或解便了，會有所表示或讓大人知道。
  - 喜歡換上乾淨的尿布。
  - 瞭解「尿尿」、「嗯嗯」、「臭臭」、「便便」、「馬桶」、「乾的」、「乾淨」、「濕的」、「髒」的意思。
  - 看過同性別的大人或孩子（如手足）使用馬桶，知道馬桶是做什麼用的。
  - 會自己拉下及拉上褲子。

# លាកន្ទបទឹកនោម ហ្វឹកហាត់ចូលបង្គន់

ការបេន្ទារបង់របស់កុមារផ្អែកទៅលើចលនារ៉េផ្លិច មិនអាចគ្រប់គ្រងដោយខ្លួនឯងបានទេ។ ចន្លោះអាយុ២ ទៅ ៣ឆ្នាំ ផ្នែកសរីរៈរីកចម្រើនដល់អាចគ្រប់គ្រងសាច់ដុំបន្ទោរបង់បាន នោះកុមារអាចទៅបង្គន់ដោយខ្លួនឯងបានដោយមិនចាំបាច់ធ្វើការរំលឹកដល់អ្នកពេលគេចង់បន្ទោរបង់ ដោះខោបន្ទោរបង់រួច ស្លៀកខោវិញដោយខ្លួនឯង នេះហៅថាការសម្រេច □ការហ្វឹកហាត់ចូលបង្គន់□។ អាចលាចាកពីកន្ទបទឹកនោម គឺជាការឈានជំហានដ៏ធំមួយក្នុងជីវិតរបស់កុមារ។

## សម្រេចបានអាកប្បកិរិយាត្រឹមត្រូវក្នុងការហ្វឹកហាត់ចូលបង្គន់

- ការលាចាកពីកន្ទបទឹកនោមរបស់កុមារគឺជារឿងមុននឹងក្រោយ អាណាព្យាបាលមិនចាំបាច់អន្ទះសារពេកឡើយ ត្រូវរក្សាឥរិយាបថធូរស្រាលសប្បាយរីករាយ និងជួយបញ្ចប់ការហ្វឹកហាត់របស់ពួកគេដូចកំដរពួកគេលេងល្បែងកម្សាន្ត។
- ប្រសិនបើជួបឧបសគ្គ កុំបង្ខំកូន អាចប្រើកន្ទបវិញប្រមាណ១ទៅ២សប្តាហ៍ចាំសាកល្បងម្តងទៀត។ ការហ្វឹកហាត់ចូលបង្គន់គង់តែសម្រេច។
- ពេលកូនមានកំហុស ត្រូវប្រាប់គេដោយភាពសោកស្តាយខ្លះៗថា ពេលចង់ជុះនោមឬលាមកលើកក្រោយត្រូវប្រញាប់ប្រាប់មនុស្សធំ មនុស្សធំនឹងជួយដល់គេ។ បន្ទាប់មកជួយសម្អាតដល់គេ ព្រមទាំងសូមឲ្យគេជួយការងារបន្តិចបន្តួច ឧទាហរណ៍យកកន្ទបទឹកនោមដែលកខ្វក់ទៅបោះចោលក្នុងធុងសម្រាម។ ហាមស្តីបន្ទោសឬដាក់ពិន័យកូន។ អារម្មណ៍ជ្រុលជ្រួសរបស់អាណាព្យាបាល តែងតែក្លាយជាមូលហេតុចម្បងនៃបរាជ័យក្នុងការហ្វឹកហាត់។
- ទោះបីជាការហ្វឹកហាត់ធ្វើបានសម្រេច កុមារនៅតែអាចកើតមាន "ចៃដន្យ" ម្តងម្កាល នេះគឺជាបាតុភូតទូទៅ។ ហាមស្តីបន្ទោសកុមារ ដោះស្រាយដោយត្រជាក់ចិត្ត។

## ពេលវេលាល្អក្នុងការចាប់ផ្តើមហ្វឹកហាត់

- ចន្លោះពីអាយុ១ ទៅ ២ឆ្នាំ ជាទូទៅកុមារាយឺតជាងកុមារី។
- បាតុភូតខាងក្រោមនេះបញ្ជាក់ថាកុមារបានត្រៀនលក្ខណៈរួចរាល់ហើយ៖
  - មានអារម្មណ៍ថាប៉ោងតម្រងនោម និងចង់បន្ទោរបង់ (ឧទាហរណ៍ ស្រាប់តែស្ងាត់ ទឹកមុខប្រែប្រួល លោត អង្គុយបញ្ឈរជង្គង់ចុះ ទាញខោ ឬប្រើភាសា និងកាយវិការប្រាប់ដល់មនុស្សធំ)។
  - ពេលនោមទទឹក ឬជុះលាមក ចេះប្រាប់ឲ្យមនុស្សធំដឹង។
  - ចូលចិត្តផ្លាស់ប្តូរកន្ទបទឹកនោមដែលស្អាត។
  - យល់ពាក្យ "នោម" "អឺអឹស" "ស្អុយស្អុយ" "អាចម៍" "ចានបង្គន់" "ស្ងួត" "ស្អាត" "ទទឹក" និង "កខ្វក់" ។
  - ធ្លាប់ឃើញមនុស្សធំឬកុមារភេទដូចគ្នាប្រើប្រាស់ចានបង្គន់ ដឹងថាចានបង្គន់មានមុខងារអ្វី។
  - ចេះទាញខោចុះ និងទាញខោឡើងដោយខ្លួនឯង។

# 和尿布說掰掰～如廁訓練

## 訓練成功的訣竅

- 買了小馬桶後，先將它放在孩子常遊戲的地方，鼓勵他常常坐在上面，時間長短不拘，讓孩子逐漸熟悉它，視它為所有物。
- 注意孩子想小便或大便的跡象，或利用午睡剛睡醒或是飯後20-30分鐘的好時機，帶他到小馬桶處，鼓勵他脫下尿布坐上去，尿（或便）在裡面。
- 當孩子已經有一半的機率成功時，可以開始不穿尿布，改穿寬鬆的褲子，讓他練習自己拉下、拉上褲子。尿布只在午睡或夜裡才使用。

## 小技巧幫大忙

- 唸一、兩本有關如廁訓練的故事書給孩子聽。
- 讓孩子跟1、2位已經達成訓練的孩子一起玩，並看著別的孩子使用小馬桶。
- 不要選擇孩子正處於反抗期或生病時開始訓練。
- 不要一直嘮嘮叨叨的提醒、催促孩子，只有在他顯示出有尿意或便意時才帶他去坐小馬桶。
- 不要強制孩子坐上小馬桶；孩子不想坐了，就應該讓他起來；即使孩子未抗拒，坐了5分鐘還解不出來，也應該讓他起來。
- 孩子肯合作就應該誇獎他，如果解出，更應同時給予精神鼓勵和實質上的獎勵（如外出散步、貼紙等），可以有效的提高成功機率，不要怕物質獎勵寵壞孩子。

# លាកន្ទបទឹកនោម ហ្វឹកហាត់ចូលបង្គន់

## រូបមន្តជោគជ័យនៃការហ្វឹកហាត់

- ក្រោយទិញកន្ថោរួច ត្រូវទុកវានៅកន្លែងដែលកូនតែងលេងកម្សាន្ត លើកទឹកចិត្តឲ្យកូនអង្គុយលើវាជាញឹកញាប់ មិនកំណត់ពេលវេលាវែងខ្លី ដើម្បីឲ្យកូនស្លាប់ជាមួយវា ចាត់ទុកវាជារបស់ខ្លួន។
- ចាប់អារម្មណ៍ទៅលើសញ្ញាពេលកូនចង់បន្ទោរបង់ ឬនាំកូនទៅកន្លែងកន្ថោក្រោយពេលភ្ញាក់ពីដេកថ្ងៃ ឬក្រោយពេលបាយ២០ទៅ៣០នាទីលើកទឹកចិត្តឲ្យគេដោះកន្ទបជុះនោម (ឬលាមក) នៅក្នុងនោះ។
- ពេលកូនមានឱកាសជោគជ័យពាក់កណ្តាល អាចចាប់ផ្តើមឈប់ប្រើកន្ទបទឹកនោម ដោយកែមកប្រើខោរលុងៗដើម្បីឲ្យគេរៀនទាញខោចុះនិងឡើង។ កន្ទបទឹកនោមប្រើតែពេលដេកថ្ងៃ និងពេលយប់។

## តិចនិចបន្តិចបន្តួចជួយបានច្រើន

- និទានរឿងទាក់ទងនឹងការហ្វឹកហាត់ចូលបង្គន់១ ឬ២រឿងឲ្យកូនស្តាប់។
- ឲ្យកូនលេងជាមួយកុមារដែលបានបញ្ចប់ការហ្វឹកហាត់១ឬ២នាក់ និងមើលពួកគេប្រើប្រាស់ចានកន្ថោ។
- កុំជ្រើសរើសធ្វើការហ្វឹកហាត់ក្នុងដំណាក់កាលប្រឆាំងឬពេលមានជម្ងឺ។
- កុំក្រើនរំលឹកឬបន្ទាន់កូនញឹកញយពេល ពេលគេបង្ហាញថាចង់ទៅបន្ទោរបង់ ចាំនាំគេទៅកន្ថោ។
